ក្រសួងអប់រំ យុវជន និងកីឡា




# ក្របខណ្ឌ មត្តេយ្យសិក្សាជំនាន់ថ្មី

## សៀវភៅសណ្ដែនាំសម្រាប់ការបង្កើតមត្តេយ្យសិក្សាសតវត្សរ៍ទី២១នៅប្រទេសកម្ពុជា

ឧបត្ថម្ភដោយមូលនិធិហ្វូនីក

ខែកញ្ញា ឆ្នាំ២០២០

រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា ផ្ទះលេខ ៨០ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារកណ្ដាល រាជធានីភ្នំពេញ
ទូរសព្ទលេខ: ០២៣ ២១៩ ២៨៥ អ៊ីមែល: info@moeys.gov.kh / webmaster@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# មាតិកា


អារម្ភកថា ........................................................ ១

**សារបាន** ........................................................ ២

**អក្សរកាត់** ........................................................ ៤

**ជំពូកទី១. ស្វែងយល់អំពីការអភិវឌ្ឍរបស់កុមារតូច** ........................................................ ៥

**១.១** ក្របខ័ណ្ឌទ្រឹស្តី និងគោលការណ៍ ........................................................ ៥

**១.២** គោលការណ៍របស់សាលាមត្តេយ្យជំនាន់ថ្មី........................................................ ៧

**១.៣** ការអភិវឌ្ឍរបស់កុមារតូច........................................................ ៧

**១.៤** សាលាមត្តេយ្យជំនាន់ថ្មី (NGPS) និងការអភិវឌ្ឍកុមារតូច ........................................................ ១១

**១.៥** ទស្សនៈវិស័យលើការសិក្សាតាមរយៈវិធីសាស្ត្រដោយផ្អែកលើសមត្ថភាព........................................................ ១២

**ជំពូកទី២. បរិយាកាសសិក្សានាពេលអនាគត**........................................................ ១៤

**២.១** ប្លង់លំហ - គំរូសាលាមត្តេយ្យជំនាន់ថ្មី (NGPS) ........................................................ ១៥

២.២ ទីធ្លាខាងក្នុង ........................................................ ១៥

២.១.១ **រចនាបថខាងក្នុងបន្ទប់រៀន** ........................................................ ២០

**២.៣ ទីធ្លាខាងក្រៅ** ........................................................ ២៣

២.៣.១ **ការណែនាំលម្អិតសម្រាប់ឧបករណ៍ និងសម្ភារៈសិក្សា** ........................................................ ២៥

៣.១ ការសិក្សាបែបសហការ ........................................................ ៣២

៣.២ សេចក្តីណែនាំពីរបៀនរៀនប្លែកៗគ្នា ........................................................ ៣៥

៣.៣ ការដាក់បញ្ចូល ICT នៅក្នុងថ្នាក់រៀន........................................................ ៣៨

៣.៤ ការសិក្សាដោយផ្អែកលើគម្រោង ........................................................ ៤១

**៣.៥ ការរៀនតាមរយៈការលេងល្បែង**........................................................ ៤៤

**៣.៦ ការអភិវឌ្ឍជំនាញទន់ និងការរៀបចំកិច្ចតែងបង្រៀន**........................................................ ៤៧

**ជំពូកទី ៤. ការវាយតម្លៃ** ..... ៥១

4.3.2 ការប្រើប្រាស់ការសន្ទនាក្នុងដំណើរការវាយតម្លៃ ..... ៦២

4.3.3. តេស្តដំណាក់ជាផ្លូវការ -តេស្តជាបុគ្គល(តេស្តរបស់ក្រសួងអប់រំ) ..... ៦៤

**4.4.** ឯកសារៈរបៀបរៀបចំព័ត៌មានដែលបង្កើតឡើងដោយការវាយតម្លៃ ..... ៦៦

**ជំពូកទី ៥. សាលារៀន អ្នកថែទាំ និងសហគមន៍** ..... ៦៩

**៥.១** មាតាបិតា សហគមន៍ និងការអភិវឌ្ឍរបស់កុមារតូច ..... ៦៩

**៥.២** ការទំនាក់ទំនងរវាងសាលារៀន និងមាតាបិតា (ឬអាណាព្យាបាល) ..... ៧០

**៥.៣** ការចូលរួមចំណែករបស់មាតាបិតា និងសហគមន៍នៅក្នុងសាលា ..... ៧២

ការចូលរួមចំណែករបស់មាតាបិតានៅតាមផ្ទះ ..... ៧៥

**ឧបសម្ព័ន្ធ** ..... ៧៧

ឯកសារយោង ..... ៩១

## អារម្ភកថា

គ្រប់ប្រទេសទាំងអស់ត្រូវការធនធានមនុស្សដែលមានគុណភាពខ្ពស់ សម្រាប់ជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច និងសង្គម។ តាមការស្រាវជ្រាវមួយបានបង្ហាញពីការអប់រំនៅកម្រិតមត្តេយ្យសិក្សាដែលមានគុណភាពខ្ពស់ វាជះឥទ្ធិពលយ៉ាងធំធេងទៅលើការអភិវឌ្ឍទូទៅរបស់កុមារតូច តាមរយៈការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយដែលនឹងជួយក្នុងការធ្វើឱ្យកូនសិស្សក្លាយទៅជាពលរដ្ឋដែលមានសមត្ថភាព និងជំនាញច្បាស់លាស់។

សៀវភៅណែនាំមួយក្បាលនេះមានគោលបំណងក្នុងការណែនាំអំពីស្តង់ដារទំនើបៗ សម្រាប់ការអប់រំកុមារតូចនៅកម្ពុជា បានស្នើឡើងនូវគំរូមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS)។ គំរូថ្មីនេះត្រូវបានបំផុសគំនិតឡើងតាមរយៈការពិសោធន៍នៅក្នុងកម្មវិធីមត្តេយ្យជំនាន់ថ្មី (NGPS) ដែលត្រូវបានអនុវត្តដោយក្រសួងអប់រំយុវជន និងកីឡានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។

មួយផ្នែកនៃការបង្កើតគំរូសាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នេះបានមកពីតម្រូវការក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែល *សិស្សកម្រិតបឋមសិក្សាស្ទើរតែពីរភាគបីដែលមិនអាចឆ្លើយតប*តាមស្តង់ដារ[1]នៅពេលបញ្ចប់ការសិក្សានៅឆ្នាំដំបូង នៃថ្នាក់ទី១។ តាមរយៈការស្នើសុំគំរូសិក្សាដែលមានគុណភាពខ្ពស់ សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) សង្ឃឹមថានឹងអាចគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញចន្លោះដែលខ្វះខាតនេះ។

សៀវភៅណែនាំសម្រាប់សាលាមត្តេយ្យសិក្សាជំនាន់ថ្មីនេះ (NGPS) នឹងណែនាំអ្នកសិក្សាទាំងឡាយឱ្យស្វែងយល់កាន់តែច្បាស់អំពីការរៀនបែបស្ថាបនា និងកម្មវិធីសិក្សារបស់វា ដោយទទួលយកការបំផុសគំនិតពីវិធីសាស្ត្រអប់រំដែលមានស្រាប់ល្អបំផុតមួយចំនួនដូចជា ម៉ុងតេសសូរី (Montessori) និងរីជីអូ-អេមីលៀ (Reggio-Emilia) រួមផ្សំជាមួយការអនុវត្តល្អបំផុតនៅអាស៊ីប៉ាស៊ីហ្វិកក្នុងការអប់រំកុមារតូច និងការដាក់បញ្ចូលឱ្យត្រូវទៅនឹងបរិបទវប្បធម៌ និងសង្គមកម្ពុជា។ សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ក៏នឹងគូសបញ្ជាក់ពីសារៈសំខាន់នៃបរិយាកាសសិក្សារូបវន្ត ដោយស្នើលើកឡើងនូវលក្ខណៈវិនិច្ឆ័យមួយដែលអ្នកសិក្សា និងស្ថាបត្យករនឹងត្រូវពិចារណារួមគ្នា ខណៈពេលដែលរៀបចំកន្លែងសិក្សាដែលអាចឆ្លើយតបបានកាន់តែប្រសើរឡើងចំពោះតម្រូវការនៃការសិក្សារបស់កុមារ។

[1] "វិធីសាស្ត្រសរុបការអាននៅក្នុងប្រទេសកម្ពុជា", TRAC III, EGRA លទ្ធផលវាយតម្លៃឆ្នាំសិក្សា ២០១៨/១៩។

## សារបាន

ឯកសារគោលរបស់សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ទាំងប្រាំជំពូកនេះរួមនឹងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ គឺមានគោលបំណងផ្តល់ឱ្យអ្នកសិក្សា និងអ្នកបង្កើតគោលនយោបាយ នូវគោលគំនិតជាមូលដ្ឋាន សម្រាប់ការបង្កើតគំរូមត្តេយ្យសិក្សាជំនាន់ថ្មីនៅកម្ពុជា។

**ជំពូកទី១** (ការស្វែងយល់អំពីការអភិវឌ្ឍកុមារតូច) ពន្យល់អំពីគោលការណ៍ ទ្រឹស្តីដែលរៀបរាប់អំពីវិធីសាស្ត្របង្រៀនដែលបានដាក់ស្នើឡើង។ លើសពីនេះទៀត វាក៏ពន្យល់អំពីការបង្កើតប្រព័ន្ធអេក្កូរួមមួយដែលជួយសម្រួលដល់ការផ្តល់សេវាក្នុងការអប់រំប្រកបដោយគុណភាពខ្ពស់។ ជំពូកនេះក៏ណែនាំផងដែរនូវរបកគហើញសំខាន់ៗ នៅក្នុងវិទ្យាសាស្ត្រនៃប្រព័ន្ធសរសៃប្រសាទដែលជាកកត្តាទ្រទ្រង់សារៈសំខាន់នៃការធ្វើអន្តរាគមន៍របស់ រដ្ឋាភិបាលក្នុងការវិនិយោគលើការអប់រំកុមារតូច ដែលជាដំណាក់កាលដ៏សំខាន់សម្រាប់ការអភិវឌ្ឍខួរក្បាលមនុស្ស និងការអភិវឌ្ឍជំនាញ។

**ជំពូកទី២** *(បរិយាកាសសិក្សាសម្រាប់ពេលអនាគត)* កំណត់លក្ខណៈវិនិច្ឆ័យសំខាន់ៗ សម្រាប់សាលាមត្តេយ្យសិក្សាគំរូ រួមទាំងការរចនាទាំងក្នុង និងក្រៅបន្ទប់រៀន ស្របតាមជំនឿដែលការប្រែប្រួលនៃការរចនាបរិយាកាសរូបវន្តនេះអាចជះឥទ្ធិពលយ៉ាងធំធេងដល់ការរីកចម្រើននៃការសិក្សារបស់សិស្សតាំងពីកុមារភាព។

នៅក្នុង**ជំពូកទី៣** (យុទ្ធសាស្ត្រសិក្សា) សៀវភៅណែនាំនេះផ្តោតជាពិសេសទៅលើយុទ្ធសាស្ត្រអប់រំចំនួនប្រាំដែល សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ធានាថាអាចគាំទ្រដល់ការរៀនសូត្ររបស់កុមារតូចឱ្យកាន់តែប្រសើរឡើង។ យុទ្ធសាស្ត្រទាំងនេះរួមមាន ការសិក្សាបែបសហការ (CL) ការណែនាំអំពីការសិក្សាតាមរបៀបរៀនផ្សេងគ្នា ការសិក្សាពឹងផ្អែកលើគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន (ICT) និងការសិក្សាតាម រយៈការលេងល្បែង។ គោលការណ៍សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ស្នើលើកឡើងនូវវិធីសាស្ត្រចម្រុះដែលគ្រូនឹងរៀនប្រើអាស្រ័យតាមតម្រូវការបង្រៀន និងការរៀនខុសៗគ្នា ដែលពួកគាត់ជួបប្រទះក្នុងអំឡុងពេលបង្រៀនរបស់ពួកគាត់។

ដំណើរការការវាយតម្លៃគឺស្ថិតនៅផ្នែកកណ្តាលនៃ **ជំពូកទី៤** *(ការវាយតម្លៃ)* ដោយមានការយកចិត្តទុកដាក់ដាក់លាក់ចំពោះការវាយតម្លៃជាទម្រង់ ការសង្កេតជាបន្តបន្ទាប់ និងការរៀបចំឯកសារ។ នៅក្នុងជំពូកនេះ សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ធ្វើការណែនាំអំពីគោលគំនិតនៃការវាយតម្លៃផ្អែកលើសមត្ថភាព ដែលភ្ជាប់ជាមួយនឹងការអភិវឌ្ឍជំនាញទន់របស់សិស្ស។

ជំពូកទី**៥** គឺជាជំពូកចុងក្រោយនៃសៀវភៅណែនាំនេះ (សាលារៀន អ្នកថែទាំ និងសហគមន៍) ពិពណ៌នាអំពី តួនាទីរបស់គ្រូបង្រៀន មាតាបិតា និងសហគមន៍នៅក្នុងកិច្ចដំណើរការការសិក្សារបស់កុមារតូច។

# អក្សរកាត់

| | |
|---|---|
| ARNEC | បណ្តាញតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់កុមារតូច |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBO | អង្គការដែលផ្អែកលើសហគមន៍ |
| CL | កិច្ចសហប្រតិបត្តិការលើការសិក្សា |
| DCD | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| DOE | ការិយាល័យអប់រំស្រុក |
| ECD | ការអភិវឌ្ឍកុមារតូច |
| ECED | នាយកដ្ឋានអប់រំកុមារតូច |
| EGRA | ការវាយតម្លៃលើការអានសម្រាប់ថ្នាក់ដំបូង |
| ESP | ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យអប់រំ |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង |
| IDELA | ការអភិវឌ្ឍអន្តរជាតិ និងការវាយតម្លៃការសិក្សាថ្នាក់ដំបូង |
| KAPE | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NGPS | សាលាមត្តេយ្យជំនាន់ថ្មី |
| NGS | សាលារៀនជំនាន់ថ្មី |
| PBL | ការសិក្សាផ្អែកលើគម្រោង |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNICEF | មូលនិធិកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (អង្គការយូនីសេហ្វ) |
| TRAC | បូកសរុបវិធីសាស្ត្រការអានសម្រាប់កុមារតូច |

# ជំពូកទី១. ស្វែងយល់អំពីការអភិវឌ្ឍរបស់កុមារតូច

*"គរុកោសល្យមួយ 'ដែលប្រកបដោយភាពច្នៃប្រឌិត' នៅក្នុងបរិបទជាក់លាក់ណាមួយ ត្រូវការការប្រកួតប្រជែង ឬយ៉ាងហោចណាស់ក៏ត្រូវការការសម្របខ្លួនតាមវិធីសាស្ត្រណាមួយដែលលេចធ្លោ ដើម្បីបង្កើតបានជាបទពិសោធន៍សម្រាប់អ្នកចូលរួម ដែលអនុញ្ញាតផ្តល់ឱ្យ និងគាំទ្រវិធីសាស្ត្រនៅក្នុងបណ្តុំជាក់លាក់មួយនៃបទពិសោធន៍ក្នុងជីវិតប្រចាំថ្ងៃ"។*

## ១.១ ក្របខ័ណ្ឌទ្រឹស្តី និងគោលការណ៍

សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ត្រូវបានរចនាឡើងដើម្បីផ្តល់នូវការរៀនសូត្រប្រកបដោយគុណភាពដល់សិស្សមត្តេយ្យសិក្សា។ វិធីសាស្ត្រអប់រំល្បីៗ ដូចជាក្របខ័ណ្ឌទ្រឹស្តីនៃសាលាមត្តេយ្យជំនាន់ថ្មី (NGPS) ត្រូវបានបំផុសគំនិតដោយវិធីសាស្ត្រអប់រំល្បីៗ ដូចជា ម៉ុងតេសសូរី (Montessori) ហាយស្កូប (HighScope), និង រីជីអូ-អេមីលៀ (Reggio Emilia[2]) មនុស្សម្នាក់ៗ មានឫសគល់ក្នុងការគិតរបស់អ្នកប្រាជ្ញដូចជា ហ្សង់ ភីអាហ្កេត (Jean Piaget), ឡេវ វីហ្គោតស្គី (Lev Vygotsky), និងចនឌូវេយ(John Dewey)។ ទោះជាយ៉ាងណាក៏ដោយក្របខ័ណ្ឌទ្រឹស្តីនេះក៏បានពិនិត្យមើលការអនុវត្តការអប់រំប្រកបដោយភាពច្នៃប្រឌិតថ្មីៗ បំផុត នៅកម្រិតមត្តេយ្យសិក្សា ពីបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិកផងដែរ។




ក្របខ័ណ្ឌទាំងអស់ដែលបានរៀបរាប់ខាងលើបង្ហាញពីធាតុទូទៅសំខាន់ៗចំនួន ៤ ដែលជាមូលដ្ឋានគ្រឹះនៃវិធីសាស្ត្រគរុកោសល្យរបស់សាលាមត្តេយ្យជំនាន់ថ្មី (NGPS)៖

១. បរិយាកាសសិក្សាដែលផ្តោតសំខាន់ទៅលើសិស្ស
២. ទស្សនវិជ្ជាបែបស្ថាបនា
៣. បទពិសោធន៍ ការសិក្សាដែលផ្អែកលើគម្រោង
៤. ការសិក្សាតាមរយៈការលេងល្បែង

**បរិយាកាសសិក្សាដែលផ្តោតសំខាន់ទៅលើសិស្ស (ធាតុទី១)**។ នៅក្នុងសាលារៀនបែបប្រពៃណី សិស្សមានតួនាទីអកម្មនៅក្នុងដំណើរការសិក្សា ដែលជារឿយៗ ត្រូវបានរៀបចំឡើងជុំវិញការអនុវត្តការរៀន និងការបង្រៀនតាមបែបទម្លាប់ ខណៈដែលសាលាមត្តេយ្យជំនាន់ថ្មី (NGPS) ទទួលយកគំនិតមួយដែលគិតថាកុមារតូចគឺជាអ្នកសិក្សាដែលចង់ដឹង ចង់ឃើញ សកម្ម និងមានសមត្ថភាព។ គ្រូនឹងមានតួនាទីក្នុងការសង្កេតមើល និងណែនាំសិស្សក្នុងការរៀនសូត្ររបស់ពួកគាត់ តាមរយៈការផ្តល់

[2] សូមមើលឧបសម្ព័ន្ធ ១.១ ទ្រឹស្តី សាលាមត្តេយ្យជំនាន់ថ្មី NGPS

នូវបទពិសោធន៍សិក្សាជាច្រើនផ្សេងៗ ទៀត ដែលកុមារតូចនឹងចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការសិក្សា។

**បង្កើតការយល់ដឹងតាមរយៈបទពិសោធន៍ក្នុងពិភពពិត (ធាតុ២ និង ៣)**។ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ត្រូវបានបំផុសគំនិតដោយគំនិតរបស់ ហ្សង់ ភីអាហ្ចេត (Jean Piaget) ដែលយល់ថា អន្តរកម្ម និងការស៊ើបអង្កេតរបស់កុមារតូច ដែលស្ថិតនៅខាងក្នុងរាងកាយរបស់ពួកគាត់ អនុញ្ញាតឱ្យពួកគាត់បង្កើតបាននូវការស្វែងយល់អំពីពិភពលោក និងបង្កើតឱ្យមានការយល់ដឹងមួយប្រកបដោយអត្ថន័យ។ ចំពោះជំនឿនេះ ឡេវ វីហ្គោតស្គី (Lev Vygotsky) បានបន្ថែមថា ការរៀនសូត្រគឺជាដំណើរការសង្គមមួយ (ដូចជាការរៀនបែបសហការ) អញ្ចឹងដែរ ដែលការសហការគ្នាជាមួយមិត្តភ័ក្តិដែលមានចំណេះដឹង និងជាមួយមនុស្សពេញវ័យផ្សេងទៀតអនុញ្ញាតឱ្យសិស្សអភិវឌ្ឍ ហើយការរៀនតាមរបៀបនេះប្រហែលជាមិនអាចទៅរួចឡើយ ប្រសិនបើទុកសិស្សឱ្យរៀនដោយឯករាជ្យ។ នៅផ្នែកនេះដែរ វាត្រូវបានគូសបញ្ជាក់ពីរបៀបដែលអន្តរកម្មសង្គមរវាងសិស្ស និងមិត្តភ័ក្តិ គ្រូបង្រៀន និងមាតាបិតារបស់ពួកគេ ដើរតួយ៉ាងសំខាន់ក្នុងការអប់រំរបស់កុមារតូច។ ការស្រាវជ្រាវខាងប្រព័ន្ធសរសៃប្រសាទក៏ពង្រឹងគោលគំនិតនេះផងដែរ ដោយកំណត់អត្តសញ្ញាណទំនាក់ទំនង "បម្រើ និងត្រឡប់មកវិញ" រវាងកុមារ និងមាតាបិតា ឬអាណាព្យាបាលរបស់ពួកគាត់ដែលជាធាតុផ្សំដ៏សំខាន់នៅក្នុងដំណើរការអភិវឌ្ឍរបស់កុមារតូច[3]។ ជាចុងក្រោយ ឌូវេយ (Dewey) បានស្នើឱ្យនិស្សិតជាអ្នកស្រាវជ្រាវដែលរៀនតាមរយៈបទពិសោធន៍ពិភពលោកពិត ដែលតម្រូវឱ្យពួកគេចូលរួមក្នុងដំណើរការសិក្សា ដោយការសាកសួរ ការស៊ើបអង្កេត និងការឆ្លុះបញ្ចាំង។ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ក៏ដូចជាវិធីសាស្ត្រទ្រឹស្តីដែលបានរៀបរាប់ខាងលើផងដែរភាគច្រើនមានទស្សនៈដូចទស្សនៈរបស់អ្នកស្រាវជ្រាវទាំងបីនេះ។

**ធាតុទីបួនគឺជាការរៀនតាមរយៈការលេងល្បែង (ធាតុទី៤)**។ អ្នកស្រាវជ្រាវបានសង្កត់ធ្ងន់ថា ការលេងគឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៅក្នុងបទពិសោធន៍សិក្សាមុនបឋមសិក្សា។ការលេងអាចជាមធ្យោបាយដ៏សំខាន់បំផុតមួយ ដែលធ្វើឱ្យកុមារតូចទទួលបាននូវចំណេះដឹង និងជំនាញសំខាន់ៗ[4]។ សម្រាប់ហេតុផលនេះផងដែរ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងផ្តល់ឱកាស និងបរិយាកាសសិក្សាមួយដែលលើកកម្ពស់បទពិសោធន៍សិក្សាផ្អែកលើការលេង និងល្បែងលេងផ្សេងៗ សម្រាប់កុមារតូច។ ទន្ទឹមនឹងនោះការពិនិត្យបែបស៊ីជម្រៅមួយអំពីវិធីសាស្ត្រដែលមានភាពច្នៃប្រឌិតមួយចំនួនក្នុងការអភិវឌ្ឍកុមារតូចហៅកាត់ថា (ECD) នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជាពិសេសពីក្នុងចំណោមរដ្ឋសមាជិក ដែលហៅកាត់ថា ARNEC[5]បានជូនដំណឹងបន្ថែមទៀតផងដែរអំពីវិធីសាស្ត្រគរុកោសល្យរបស់សាលាមត្តេយ្យជំនាន់ថ្មី (NGPS)។ ការពិនិត្យនេះបានធ្វើឱ្យអ្នកសរសេរកម្មវិធី អាចនាំយកទ្រឹស្តីនៃគរុកោសល្យអប់រំ ដ៏ល្បីល្បាញជាមួយនឹងការអនុវត្តជាក់ស្តែងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកបញ្ចូលទៅក្នុងគោលការណ៍អនុវត្តសម្រាប់បច្ចុប្បន្ន។ ជាលទ្ធផល សាលាមត្តេយ្យជំនាន់ថ្មី (NGPS)

3.មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ សាកលវិទ្យាល័យហាវ៉ាដ (២០០៧) "វិទ្យាសាស្ត្រនៃការអភិវឌ្ឍកុមារតូច"

៤.មូលនិធិ Lego/UNICEF (2018) ។ "ការរៀនតាមរយៈការលេង ការពង្រឹងការសិក្សាតាមរយៈការលេងក្នុងកម្មវិធីអប់រំកុមារតូច

៥.បណ្តាញអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំកុមារតូច។ កម្ពុជាគឺជាប្រទេសសមាជិកសកម្មនៃបណ្តាញ

ក៏នឹងប្តេជ្ញាចំពោះ៖

- ភាពខុសគ្នានៃការណែនាំអំពីការសិក្សា។
- កែសម្រួលកម្មវិធីសិក្សាផ្លូវការដើម្បីជាក់បញ្ចូលក្នុងការសិក្សានៅថ្នាក់មូលដ្ឋាន។
- លើកឡើងការលេងល្បែងដោយសេរី សកម្មភាពទាំងឡាយដែលផ្តួចផ្តើមឡើងដោយកុមារតូច និងការប្រើប្រាស់សំណួរបើកក្នុងការចូលរួមរបស់កុមារតូច។
- ជំរុញការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។
- ផ្សាភ្ជាប់ទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍ក្នុងដំណើរការការសិក្សារបស់កុមារតូច។

## ១.២ គោលការណ៍របស់សាលាមត្តេយ្យជំនាន់ថ្មី

មធ្យោបាយសម្រាប់ក្របខ័ណ្ឌទ្រឹស្តី និងការអនុវត្តដែលល្អបំផុតខាងលើនឹងបំផុសគំនិតអំពីគោលការណ៍អប់រំរបស់មត្តេយ្យសិក្សា (NGPS) ដូចខាងក្រោម៖

- យើងជឿជាក់ថាកុមារតូចម្នាក់ៗ មានលក្ខណៈពិសេសនិងមានរបៀបរៀនខុសៗគ្នា
- យើងជឿថាកុមារតូចគឺជាអ្នកសិក្សាវ័យក្មេងសកម្ម និងមានសមត្ថភាព
- យើងជឿជាក់ថាការមានគ្រូដែលមានសមត្ថភាពនិងការគ្រប់គ្រងមួយដែលពោរពេញទៅដោយការលើកទឹកចិត្ត គឺជាធាតុសំខាន់បំផុតសម្រាប់គរុកោសល្យប្រកបដោយភាពច្នៃប្រឌិត
- យើងជឿថាបរិយាកាសសិក្សាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលសិក្សារបស់កុមារតូច
- យើងមើលឃើញថា ICT ជាឧបករណ៍ដ៏មានឥទ្ធិពលមួយ ក្នុងការបង្កើនបទពិសោធន៍សិក្សារបស់កុមារតូច
- យើងជឿជាក់លើតួនាទីសំខាន់របស់មាតាបិតា និងសហគមន៍ ដែលធ្វើឱ្យយើងអាចឈានទៅរកសក្តានុពលខ្ពស់បំផុតរបស់សិស្ស។

## ១.៣ ការអភិវឌ្ឍរបស់កុមារតូច

សាលាមត្តេយ្យជំនាន់ថ្មី (NGPS) មានបំណងធ្វើឱ្យការអភិវឌ្ឍកុមារតូច ទៅជាដំណើរការរួមមួយដែលពាក់ព័ន្ធនឹងផ្នែកផ្សេងៗ ទៀតនៃការអភិវឌ្ឍ ដែលសុទ្ធតែមានទំនាក់ទំនងគ្នាទៅវិញទៅមក និងលើកកម្ពស់ដល់ការរៀនសូត្រទាំងមូល។ការអភិវឌ្ឍរបស់កុមារតូចត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍនៃខួរក្បាល (ទំនាក់ទំនងហ្សែន និងបទពិសោធន៍) និងអាយុ។ តាមពិតទៅកាលដែលកុមារតូច ធំធាត់ឡើង ជំនាញរបស់ពួកគេក៏កាន់តែស្មុគស្មាញ។នៅសាលារៀន និងនៅផ្ទះកុមារតូចទទួលបានចំណេះដឹង ជំនាញ និងសមត្ថភាពបន្តិចម្តងៗ នៅក្នុងផ្នែកផ្សេងៗ នៃការរៀន និងពិសោធន៍ ដើម្បីប្រើប្រាស់ចំណេះដឹងបែបនេះក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ដូច្នេះហើយ តួនាទីចម្បងរបស់គ្រូគឺគួរតែផ្តល់បទពិសោធន៍សិក្សាលើគ្រប់វិស័យដែលកំណត់ពីការអភិវឌ្ឍរបស់កុមារតូច។

**វិទ្យាសាស្ត្រនៃការអភិវឌ្ឍកុមារតូច**

ការសិក្សាផ្នែកប្រព័ន្ធសរសៃប្រសាទបានបង្ហាញពីរបៀបដែលប្រព័ន្ធខួរក្បាលត្រូវបានបង្កើតឡើង ជាពិសេសក្នុងអំឡុងពេលឆ្នាំដំបូងនៃជីវិត។ បទពិសោធន៍ដំបូងនេះមានផលប៉ះពាល់ដល់គុណភាពនៃប្រព័ន្ធបែបនេះ ដែលជាហេតុបង្កឱ្យមានមូលដ្ឋានគ្រឹះរឹងមាំ ឬទន់ខ្សោយសម្រាប់ការរៀនសូត្រទាំងអស់ដែលនឹងកើតឡើងជាបន្តបន្ទាប់។ ការស្រាវជ្រាវខាងប្រព័ន្ធសរសៃប្រសាទនេះក៏បានបង្ហាញថា វិធីសាស្ត្រប្រកបដោយតុល្យភាពចំពោះការអភិវឌ្ឍផ្លូវចិត្ត សង្គម ការយល់ដឹង ព្រមទាំងភាសា នឹងរៀបចំឱ្យកុមារតូចទាំងអស់ទទួលបានជោគជ័យក្នុងសាលារៀន និងនៅពេលក្រោយបន្តទៀតនៅក្នុងពិភពការងារ ក៏ដូចជានៅក្នុងសហគមន៍ផងដែរ។ តាមការពិត សុខុមាលភាពផ្លូវអារម្មណ៍ និងសមត្ថភាពសង្គមអាចជួយដល់ការអភិវឌ្ឍសមត្ថភាពចំណេះដែលនឹងកំពុងលេចចេញមក។ ហេតុដូច្នេះ តួនាទីចម្បងរបស់គ្រូបង្រៀន គឺគួរតែផ្តល់បទពិសោធន៍សិក្សាលើគ្រប់វិស័យដែលជួយដល់ការអភិវឌ្ឍកុមារតូច ដោយផ្តោតលើអក្ខរកម្មដំបូង និងការគណនាលេខផងដែរ បូករួមទាំងលើជំនាញ និងអាកប្បកិរិយាសំខាន់ៗ ផ្សេងទៀត ដូចជា ទំនុកចិត្តលើខ្លួនឯង ឬសមត្ថភាពក្នុងការធ្វើការជាក្រុម ឬការដោះស្រាយវិវាទ **ព្រោះក្នុងដំណាក់កាលមួយនៃជីវិតមួយនេះ ហើយដែលធ្វើឱ្យកុមារតូចអាចបង្កើតមូលដ្ឋានគ្រឹះនៃជំនាញ និងអាកប្បកិរិយាសំខាន់ៗ ទាំងនោះ ដែលវាមានសារៈសំខាន់ក្នុងជីវិតមនុស្សពេញវ័យ។**

សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ចាប់យកជាតុ អភិវឌ្ឍនចំនួន ៥ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រួមមានៈ

១ ការអភិវឌ្ឍការយល់ដឹង
២ ការអភិវឌ្ឍសង្គម អារម្មណ៍
៣ ការអភិវឌ្ឍភាសាវិទ្យា និងអក្ខរកម្ម
៤ ការអភិវឌ្ឍរាងកាយ និងសុខភាព
៥ ការអភិវឌ្ឍវប្បធម៌ និងសីលធម៌

តារាងខាងក្រោមផ្តល់នូវការពិពណ៌នាសង្ខេបអំពីតំបន់អភិវឌ្ឍន៍នីមួយៗ និងសកម្មភាពមួយចំនួនដែលគ្រូអាចធ្វើដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍បែបនេះ។



រូបភាពទី15 តំបន់អភិវឌ្ឍន៍កុមារតូចកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា

| វិស័យសិក្សា | និយមន័យ | អ្វីខ្លះដែលគ្រូអាចធ្វើបាន (ឧទាហរណ៍) |
|---|---|---|
| ការអភិវឌ្ឍការយល់ដឹង | ការអភិវឌ្ឍការយល់ដឹង សំដៅលើដំណើរការនៃការលូតលាស់ និងការផ្លាស់ប្តូរសមត្ថភាពបញ្ញា និងផ្លូវចិត្ត ដូចជាការគិត ការវែកញែក ឬការយល់ដឹងផ្សេងៗ។ | • បង្រៀនពីទំនាក់ទំនង ហេតុ-ផល<br>• រៀន និងអនុវត្តយុទ្ធសាស្ត្រដោះស្រាយបញ្ហាបែបសាមញ្ញៗ<br>• ជំរុញឱ្យមានការច្នៃប្រឌិត<br>• លើកទឹកចិត្តឱ្យលេងបែបជានិមិត្តសញ្ញា/ធ្វើពុតជាលេង<br>• ជំរុញការចងចាំ ការគ្រប់គ្រងការរារាំងភាពបត់បែនផ្លូវចិត្ត និងការគ្រប់គ្រងខ្លួនឯង។<br>• ជំរុញការឆ្លុះបញ្ចាំងជាបន្តបន្ទាប់ (របៀបដែលកុមារតូចមានអារម្មណ៍ និងមកពីមូលហេតុអ្វី ដែលកំណត់គោលដៅរយៈពេលខ្លី ពិចារណាចំណុចជាច្រើនទៀតនៃទិដ្ឋភាព)។ |

| វិស័យសិក្សា | និយមន័យ | អ្វីខ្លះដែលគ្រូអាចធ្វើបាន (ឧទាហរណ៍) |
|---|---|---|
| ការអភិវឌ្ឍសង្គម-អារម្មណ៍ | ការអភិវឌ្ឍសង្គម-អារម្មណ៍រួមមានបទពិសោធន៍ ការបញ្ចេញមតិ និងការគ្រប់គ្រងអារម្មណ៍របស់កុមារតូច និងសមត្ថភាពក្នុងការបង្កើតទំនាក់ទំនងវិជ្ជមាន និងបង្កើនទំនាក់ទំនងជាមួយអ្នកដទៃ (Cohen et al. 2005) | • លើកកម្ពស់ការគ្រប់គ្រងខ្លួនឯងនិងស្វ័យភាពដោយបង្កើតទម្លាប់និងប្រើប្រាស់យុទ្ធសាស្ត្រសិក្សាដែលសកម្ម<br>• លើកកម្ពស់ការយល់ដឹងអំពីអារម្មណ៍ អាកប្បកិរិយាយល់ចិត្តនិងការយល់ដឹងពីអារម្មណ៍របស់អ្នកដទៃ<br>• លើកកម្ពស់អន្តរកម្មរវាងមិត្តភក្តិដោយប្រើសកម្មភាពការងារជាក្រុម និងយុទ្ធសាស្ត្រសិក្សាតាមរយៈការសហការ<br>• ណែនាំការអនុវត្តដំណោះស្រាយជម្លោះសាមញ្ញៗ |
| ការអភិវឌ្ឍភាសា | ការអភិវឌ្ឍភាសាសំដៅលើដំណើរការសិក្សាដែលកុមារតូចទទួលបានទម្រង់ អត្ថន័យ និងការប្រើប្រាស់ពាក្យ។<br>គ្រួសារ និងសហគមន៍មានឥទ្ធិពលខ្លាំងលើការអភិវឌ្ឍភាសា។ | • ណែនាំកុមារតូចឱ្យបង្កើនវាក្យសព្ទរបស់ពួកគេ និងលើកទឹកចិត្តឱ្យពួកគេប្រើពាក្យថ្មីក្នុងបរិបទ និងស្ថានភាពផ្សេងៗគ្នា<br>• អានរឿងឱ្យឮៗ (ជាផ្នែកនៃទម្លាប់ក្នុងថ្នាក់រៀន) លើកកម្ពស់ជំនាញស្តាប់<br>• លើកកម្ពស់ការយល់ដឹងអំពីការបោះពុម្ព និងការកំណត់អត្តសញ្ញាណសំឡេង |
| ការអភិវឌ្ឍរាងកាយនិងសុខភាព | វិស័យនេះសំដៅលើវឌ្ឍនភាពក្នុងការអភិវឌ្ឍការលូតលាស់ និងសមត្ថភាពរបស់កុមារតូចក្នុងការប្រើប្រាស់រាងកាយ ស្របតាមអាយុរបស់កុមារតូច។ តាមនិយមន័យរបស់ប្រទេសកម្ពុជាចំពោះក្រុមអភិវឌ្ឍសុខភាពរបស់កុមារតូចជាមួយនឹងការអភិវឌ្ឍជំនាញសមត្ថភាពរបស់កុមារតូចក្នុងការប្រើប្រាស់រាងកាយរបស់ពួកគេ យើងអាចមើលឃើញបានពីភាព | • ផ្សព្វផ្សាយសកម្មភាពទាំងខាងក្រៅនិងក្នុងផ្ទះដែលរួមមានការដើរលំនឹង ការបោះជំហាន និងចាប់វត្ថុ ការរត់ ឬលោត ខណៈដែលជំនាញសមត្ថភាពរបស់កុមារតូចក្នុងការប្រើប្រាស់រាងកាយ<br>រួមមាន ការគូររូប ធ្វើការដោយប្រើម្រាមដៃ រៀបចំវត្ថុតូចៗ កាន់ខ្មៅដៃ និងបិទ។ ការលេងជាមួយឧបករណ៍ផ្សេងៗ គឺជាឧទាហរណ៍នៃ |

| វិស័យសិក្សា | និយមន័យ | អ្វីខ្លះដែលគ្រូអាចធ្វើបាន (ឧទាហរណ៍) |
|---|---|---|
| | ជាប់ទាក់ទងគ្នារវាងសុខភាព និងអាហារូបត្ថម្ភ និងការអភិវឌ្ឍរាងកាយរបស់កុមារតូច។ | សមត្ថភាពរបស់កុមារតូចក្នុងការប្រើប្រាស់ផ្នែកណាមួយនៃរាងកាយរបស់ពួកគេ។ |
| ការអភិវឌ្ឍវប្បធម៌ និងសីលធម៌[6] | វិស័យនេះរួមបញ្ចូលទាំងចំណេះដឹងអំពីវប្បធម៌ខ្មែរ តម្លៃស្នូល និងទំនៀមទំលាប់ ក៏ដូចជាការលើកកម្ពស់ការចែករំលែកការយល់ដឹងរួមអំពីសីលធម៌ យុត្តិធម៌ និងសមធម៌។ | • ដើរតួជាមនុស្សគំរូ<br>• ឱ្យតម្លៃប្រពៃណី និងវប្បធម៌<br>• លើកកម្ពស់ការឆ្លុះបញ្ចាំងអំពីអាកប្បកិរិយារបស់កុមារតូច និងអ្វីដែលត្រូវចាត់ទុកថាត្រូវ និងខុស |

វិស័យអភិវឌ្ឍន៍ទាំងនេះត្រូវសម្រេចបានតាមរយៈមុខវិជ្ជាសិក្សាផ្សេងៗ ដូចជា ចិត្តវិទ្យា គណិតវិទ្យា ភាសាខ្មែរ វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាអង់គ្លេស។ យុទ្ធសាស្ត្រនេះនឹងអាចដំណើរការបានពេញលេញក្នុងប្រទេសកម្ពុជានៅពេលដែលកម្មវិធីសិក្សាថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់ពេញលេញ[7]។ មាតាបិតា និងសហគមន៍នឹងត្រូវសម្របសម្រួលជាមួយគ្រូ ដើម្បីពង្រឹងការងារនៅសាលា នៅតាមផ្ទះរបស់ពួកគាត់។

## ១.៤ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) និងការអភិវឌ្ឍកុមារតូច

ការបង្កើតគំរូសាលាមត្តេយ្យជំនាន់ថ្មី (NGPS) នេះជាផ្នែកមួយដែលបានមកពីតម្រូវការក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលសិស្សបឋមសិក្សាស្ទើរតែពីរភាគបីមិនបានអានស្របតាមស្តង់ដារ[8] នៅពេលបញ្ចប់ការសិក្សាឆ្នាំទី១ ។ ដូច្នេះការធ្វើការប្រកបដោយភាពច្នៃប្រឌិត ដើម្បីអភិវឌ្ឍជំនាញភាសា និងជំនាញត្រៀមក្លាយជាអាទិភាពនៅក្នុងគំរូសាលាមត្តេយ្យជំនាន់ថ្មី NGPS រួមផ្សំជាមួយនឹងមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍ ការយល់ដឹង។ ជាពិសេសសាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងផ្តោតទៅលើទិដ្ឋភាព ៣ ផ្សេងគ្នានៅក្នុងដំណើរការបង្រៀន និងការរៀន ដែលការស្រាវជ្រាវបានបង្ហាញឱ្យឃើញពីផលប៉ះពាល់ដល់ដំណើរការសិក្សារបស់សិស្ស ពោលគឺ៖

- **បរិស្ថានសិក្សាខាងក្រៅ(ជំពូកទី២)៖** វាត្រូវបានបង្ហាញអោយឃើញថាមានជាតុជាច្រើននៅក្នុងបរិយាកាសខាងក្រៅរបស់សាលាអាចជះឥទ្ធិពលជាវិជ្ជមានដល់ការរៀនសូត្ររបស់កុមារតូច។ដូច្នេះ ការរចនាសាលានឹងត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់កុមារតូច។

[6] នេះជាផ្នែកបន្ថែមនៃការអភិវឌ្ឍកុមារតូច ត្រូវបានកំណត់ជាពិសេសនៅក្នុងប្រទេសកម្ពុជា ដែលវប្បធម៌ សីលធម៌ និងប្រពៃណីត្រូវបានចាត់ទុកយ៉ាងខ្ពស់នៅក្នុងសង្គម។

[7] ក្របខណ្ឌកម្មវិធីសិក្សានៃការអប់រំទូទៅ និងបច្ចេកទេសឆ្នាំ 2015។ ភាសាអង់គ្លេសគឺជាផ្នែកមួយនៃកំណែទម្រង់កម្មវិធីសិក្សាថ្មី។ បច្ចុប្បន្ននេះ សាលារៀនភាគច្រើននៅតែប្រើប្រាស់កម្មវិធីសិក្សាចាស់ដដែល ដោយសារតែខ្វះធនធានមនុស្ស។

[8] "វិធីសាស្ត្រសរុបការអានរបស់កុមារតូច",TRAC III, EGRA លទ្ធផលដែលទទួលបានពីការវាយតម្លៃ 2018/19

- **យុទ្ធសាស្រ្តក្នុងការសិក្សា (ជំពូកទី៣)៖** គ្រូត្រូវប្រើភាសាល្អបំផុតសម្រាប់កុមារម្នាក់ៗហើយស្នើវិធីសាស្រ្តបង្រៀនផ្សេងៗគ្នាទៅតាមនោះ។បទពិសោធន៍ពិពិតកម្មពិភពលោកនឹងក្លាយជាគន្លឹះក្នុងការសិក្សា។
- **ការចូលរួមពីមាតាបិតា និងសហគមន៍ (ជំពូកទី៥)៖** ដោយពិចារណាថាការអភិវឌ្ឍរបស់កុមារតូចត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើបរិយាកាសសង្គមនិងវប្បធម៌ដែលពួកគេរស់នៅ ធាតុចូលនៃកម្មវិធីអប់រំនេះក៏នឹងមានសារៈសំខាន់ផងដែរ។

ធាតុចូលនីមួយៗ នឹងត្រូវបានបង្ហាញយ៉ាងលម្អិតនៅក្នុងជំពូកខាងក្រោម៖ ជំពូកទី២ ទី៣ និងទី៥។

## ១.៥ ទស្សនៈវិស័យលើការសិក្សាតាមរយៈវិធីសាស្រ្តដោយផ្អែកលើសមត្ថភាព

ក្រសួងអប់រំ យុវជន និងកីឡា ផ្ដល់ឯកសារល្អៗ ទៅលើអ្វីដែលកុមាររំពឹងថានឹងសម្រេចបានទាក់ទងនឹងចំណេះដឹង ជំនាញ និងអាកប្បកិរិយា នៅពេលបញ្ចប់កម្រិតបឋមសិក្សា។ លទ្ធផលសិក្សាជាក់លាក់ក៏ត្រូវបានដាក់បញ្ចូលដោយមុខវិជ្ជាសិក្សា រួមជាមួយនឹងសមត្ថភាពចំនួន ៨ ដែលកុមារតូចគ្រប់រូបត្រូវបានគេរំពឹងថានឹងមាននៅពេលបញ្ចប់ការសិក្សារបស់ពួកគេ។ ចាប់ផ្ដើមពីការរំពឹងទុកនៃការសិក្សាទាំងនេះ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងរៀបចំឧបករណ៍មួយដើម្បីតាមដានការអភិវឌ្ឍសមត្ថភាពសំខាន់ៗ ដែលមានអត្ថប្រយោជន៍ជាពិសេសពីការរចនាគំរូ ហើយនៅខណៈពេលនេះមិនត្រូវបានគេត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធទេ។ ការធ្វើដូច្នេះសម្រាប់សមត្ថភាពនីមួយៗ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងកំណត់បណ្ដុំនៃសកម្មភាព និងអាកប្បកិរិយាដែលអាចសង្កេតបានសម្រាប់គ្រូបង្រៀនដើម្បីត្រួតពិនិត្យ ដែលនឹងបង្ហាញពីការអនុវត្តជំនាញទន់ និងជាចំណុចកណ្ដាលក្នុងការអភិវឌ្ឍសមត្ថភាព ក៏ដូចជាចំណុចកណ្ដាលនៅក្នុងយុទ្ធសាស្រ្តបង្រៀន និងរៀនរបស់សាលាមត្តេយ្យជំនាន់ថ្មី (NGPS)។ ទាំងនេះមានន័យថា ទោះបីជាសមត្ថភាពគឺជាការរួមបញ្ចូលគ្នាមិនត្រឹមតែជំនាញប៉ុណ្ណោះទេ ប៉ុន្តែក៏មានចំណេះដឹង បទពិសោធន៍ ឬសមត្ថភាពផ្ទាល់ខ្លួនផងដែរ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងផ្ដោតសំខាន់ទៅលើការអភិវឌ្ឍ និងការត្រួតពិនិត្យជំនាញទន់ជាចម្បង។បណ្ដុំនៃជំនាញទន់ពាក់ព័ន្ធ និងសមត្ថភាពដែលត្រូវបានជ្រើសរើសត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

*តារាង1 សេចក្តីសង្ខេបនៃសមត្ថភាពគោលដៅ និងជំនាញទន់*

| សមត្ថភាព | គោលដៅជំនាញទន់ |
|---|---|
| ទំនាក់ទំនង និងការងារជាក្រុម | ១. ទំនាក់ទំនង<br>២. កិច្ចសហប្រតិបត្តិការ |
| ការវិភាគ និងការច្នៃប្រឌិត | ៣. ការត្រិះរិះពិចារណា<br>៤. ការដោះស្រាយបញ្ហា<br>៥. ការច្នៃប្រឌិត |
| កុមារ គ្រួសារ និងសហគមន៍ | ៦. ការគ្រប់គ្រងខ្លួនឯង<br>៧. ការអាណិតអាសូរ |

ការទទួលបាននូវជំនាញទន់តាំងពីក្មេងនឹងមានសារសំខាន់សម្រាប់ការកសាងជំនាញរឹងបន្ថែមទៀតនាពេលអនាគតហើយក៏មានឥទ្ធិពលដោយផ្ទាល់មិនត្រឹមចំពោះតែការរៀនសូត្ររបស់កុមារតូចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសមត្ថភាពរួមរបស់ពួកគេក្នុងការឈានដល់កម្រិតកំពូលរបស់ពួកគេនៅក្នុងជីវិតពេញវ័យនាពេលអនាគតផងដែរ។

**តើសម្ថភាពគឺជាអ្វី?**

ចង្កោមនៃសមត្ថភាព បទពិសោធន៍ ចំនេះដឹង និងជំនាញដែលពាក់ព័ន្ធ ដែលអាចឱ្យបុគ្គល (ឬអង្គការ) ធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពក្នុងការងារ ឬស្ថានភាពណាមួយ។

**សមត្ថភាពទាំង ៨ ដែលកំណត់ដោយ ក្រសួងអប់រំយុវជន និងកីឡា**

| | |
|---|---|
| ៤.១ អក្ខរកម្ម និងមូលដ្ឋានគ្រឹះគណិតវិទ្យា<br>៤.២ ភាសាបរទេស<br>៤.៣ បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT)<br>៤.៤ ការទំនាក់ទំនង និងការងារជាក្រុម | ៤.៥ ការវិភាគ និងការច្នៃប្រឌិត<br>៤.៦ ការអនុវត្តចំណេះដឹង និងជំនាញ<br>៤.៧ ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម<br>៤.៨ ភាពជាសហគ្រិន និងភាពជាអ្នកដឹកនាំ |

## ជំពូកទី២. បរិយាកាសសិក្សានាពេលអនាគត

ការសិក្សាថ្មីៗបានបង្ហាញពីរបៀបដែលការប្រែប្រួលនៃការរចនាបរិយាកាសរូបវ័ន្តបុគ្គលអាចជះឥទ្ធិពលដល់ដំណើរការការសិក្សារបស់សិស្ស។ ការសិក្សាដ៏ល្បីមួយដែលបានធ្វើឡើងនៅចក្រភពអង់គ្លេសក្នុងឆ្នាំ២០១៥[9] បានបង្ហាញថា បរិយាកាសរូបវ័ន្តបុគ្គលបានផលជះឥទ្ធិពល ១៦% ពីការប្រែប្រួលនៃដំណើរការសិក្សារបស់សិស្ស។

កត្តាមួយចំនួនដូចជា កត្តាធម្មជាតិ (រួមទាំងសីតុណ្ហភាព ពន្លឺ សូរស័ព្ទ ឬគុណភាពខ្យល់) ត្រូវបានបង្ហាញថាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសិស្ស ក៏ដូចជាភាពបត់បែននៃប្លង់ថ្នាក់រៀន ឬភាពស្មុគស្មាញដែលមើលឃើញនៅក្នុងថ្នាក់រៀន។ ទោះបីជាវាជាការពិតដែលកត្តាទាំងអស់ត្រូវតែសមស្របជាមួយនឹងបរិបទនៅក្នុងលក្ខខណ្ឌអាកាសធាតុ និងវប្បធម៌ក្នុងតំបន់ក៏ដោយ ក៏ពួកគេនៅតែផ្តល់នូវចំណុចសំខាន់ដែលអាចជាការយោងដើម្បីផ្តល់ជាព័ត៌មានឱ្យកាន់តែប្រសើរឡើងអំពីការរចនា និងការរៀបចំបរិយាកាសសិក្សានៅកម្ពុជា។

> The classroom design needs to reflect the teaching methodology teachers will apply. If not, a change in the environment that is not supported by a change in the teaching, can bring to opposite results.

ការរចនាសាលាមត្តេយ្យជំនាន់ថ្មី (NGPS) រួមបញ្ចូលធាតុរូបវន្តដែលធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់គ្រូបង្រៀនក្នុងការប្រើប្រាស់យុទ្ធសាស្ត្រសិក្សាដែលផ្តោតលើកុមារតូច និងការសិក្សាបែបកិច្ចសហប្រតិបត្តិការ ដែលជួយលើកកម្ពស់ស្វ័យភាព និងឯករាជ្យភាពរបស់កុមារតូចដោយការលើកកម្ពស់ឱ្យមានការប្រើប្រាស់ ICT ក្នុងការបង្រៀន និងរៀនផងដែរ។ តារាងខាងក្រោមនេះនឹងសង្ខេបអំពីរបៀបដែលយុទ្ធសាស្ត្របង្រៀនសំខាន់ៗអាចបញ្ជាក់ពីការរចនាបរិយាកាសសិក្សាបាន៖

***តារាង២ យុទ្ធសាស្ត្របង្រៀនសំខាន់ៗ ដែលបញ្ជាក់អំពីការរចនាក្នុងបន្ទប់សិក្សា***

| យុទ្ធសាស្ត្របង្រៀន | របៀបដែលវាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងប្លង់ |
|---|---|
| ការសិក្សាបែបកិច្ចសហប្រតិបត្តិការ | បង្កើតកន្លែងទំនេរក្នុងបន្ទប់រៀនដែលអនុញ្ញាតឱ្យកុមារតូចអាចធ្វើការជាក្រុម បុគ្គល និងជាគូបាន។ |
| ការផ្តោតលើកុមារតូច | គ្រឿងសង្ហារឹមទំហំសម្រាប់កុមារតូច បង្អួចមានកម្ពស់សម្រាប់កុមារតូច បង្គន់ដែលមានភាពងាយស្រួលសម្រាប់កុមារតូចប្រើប្រាស់។ បើអាចដកតុគ្រូចេញដើម្បីបង្កភាពងាយស្រួលនៅក្នុងថ្នាក់រៀនឱ្យកាន់តែទូលាយ ដែលជាវាតម្រូវការ និងសកម្មភាពរបស់សិស្ស។ |
| លើកកម្ពស់ស្វ័យភាព និងឯករាជ្យភាព | ស្នើជម្រើសកន្លែងអង្គុយដែលអាចបត់បែនបានក្នុងថ្នាក់រៀន ដើម្បីឱ្យកុមារតូចជ្រើសរើស។ សម្ភារៈសិក្សាមានភាពងាយស្រួលក្នុងការចូលរៀនសម្រាប់សិស្សដោយមិនចាំបាច់មានការអន្តរាគមន៍ពីគ្រូ (ឧ. គិតដល់កម្ពស់កុមារតូច ងាយស្រួលមើល។ |

[9] Barrett et al.2015.

| | |
|---|---|
| | ល។)។ កំណត់ទីតាំងសិក្សានៅក្នុងថ្នាក់រៀន ដែលសិស្សអាចផ្លាស់ទីដោយសេរី។ ផ្នែកខាងក្នុង និងខាងក្រៅត្រូវភ្ជាប់គ្នា។ |
| សមាហរណកម្ម ICT | បញ្ចូលកម្មវិធីទូរទស្សន៍ឆ្លាតវៃ និងការប្រើប្រាស់ថេបប្លេតទៅក្នុងវិស័យអប់រំ និងការរៀនរបស់កុមារតូច។ |

## ២.១ ប្លង់លំហ - គំរូសាលាមត្តេយ្យជំនាន់ថ្មី (NGPS)

នៅក្នុងប្រទេសកម្ពុជាសាលាមត្តេយ្យសាធារណៈជាទូទៅមានទីតាំងនៅក្នុងបរិវេណសាលាបឋមសិក្សាក្នុងបន្ទប់ស្តង់ដារទំហំ 7x8 ម៉ែត្រ។ ការរចនានេះធ្វើតាមការរចនាស្តង់ដាររបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចបង្ហាញក្នុងរូបភាពទី២ ហើយសាលាទាំងអស់បង្ហាញប្លង់ដូចគ្នាទាំងគ្រឿងសង្ហារឹម និងការតុបតែងជញ្ជាំង។



*រូបភាព២ គំរូថ្នាក់រៀនដែលបានស្នើឡើងដោយ MoEYS*

សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ស្វែងរកការផ្លាស់ប្តូរគំរូសាលាមត្តេយ្យបែបប្រពៃណី និងតស៊ូមតិសម្រាប់ការរចនាប្រកបដោយភាពច្នៃប្រឌិតបន្ថែមទៀតដើម្បីបំពេញតាមតម្រូវការនៃសេដ្ឋកិច្ចសតវត្សទី២១។ការតស៊ូមតិនេះត្រូវបានបំផុសគំនិតឡើងដោយបទពិសោធន៍របស់សាលាជំនាន់ថ្មី និងបទពិសោធន៍ស្រដៀងគ្នាផ្សេងទៀតនៅក្នុងបណ្តាប្រទេសផ្សេងៗ គ្នា។

សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ស្វែងរកការផ្លាស់ប្តូរការយកចិត្តទុកដាក់ពីគ្រូទៅកាន់កុមារតូចដើម្បីឆ្លើយតបឱ្យបានកាន់តែប្រសើរឡើង ចំពោះយុទ្ធសាស្ត្រសិក្សាដែលផ្តោតលើកុមារតូច ដោយស្នើសុំកន្លែងសិក្សាដែលមានសុវត្ថិភាព និងផាសុកភាព និងអនុញ្ញាតឱ្យកុមារតូចមានអារម្មណ៍ធូរស្រាល និងមានទំនុកចិត្តក្នុងការផ្លាស់ទីដោយសេរី។ នៅពេលដែលកន្លែងសិក្សាត្រូវបានរៀបចំយ៉ាងល្អ ឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូ និងសិស្ស នោះទីធ្លារនេះនឹងជួយសម្រួល ក៏ដូចជាគាំទ្រដល់ការសិក្សារៀនសូត្រ។

## ២.២ ទីធ្លារខាងក្នុង

ពេលរចនាបរិយាកាសសិក្សាសាលាមត្តេយ្យជំនាន់ថ្មី(NGPS)ពិចារណាលើធាតុសំខាន់ៗចំនួន៣៖

I. **សុវត្ថិភាព ភាពងាយស្រួល និងផាសុកភាព**: កន្លែងសិក្សាត្រូវតែមានសុវត្ថិភាព មានភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់ទាំងអស់គ្នា និងមានផាសុកភាព។ គោលដៅចុងក្រោយគឺបង្កើតកន្លែងសម្រាកលំហែ ដែលកុមារតូចទាំងអស់មានអារម្មណ៍ជឿជាក់ និងមានសុវត្ថិភាពក្នុងការផ្លាស់ទី និងធ្វើអន្តរកម្មដោយសេរី។ការពិចារណាពីទស្សនៈរបស់អ្នកដែលនឹងប្រើប្រាស់ទីធ្លារក្នុងការរចនា (កុមារតូច)។ប្រើសម្ភារៈទំនើបនិងសម្ភារៈដែលមានភាពទន់សម្រាប់ប្រើធ្វើគ្រឿងសង្ហារឹមនិងកម្រាលឥដ្ឋ។ ដាក់កម្រិតពណ៌នៅក្នុងបន្ទប់ ហើយព្យាយាមកាត់បន្ថយពណ៌ចម្រុះមកត្រឹម

១ពណ៌ជាគោល ដើម្បីកុំឱ្យមើលទៅជ្រាលភ្នែក[10]។ ការកំណត់ចំនួនសិស្សរហូតដល់អតិបរមាចាប់ពី ២០-២៥នាក់ ដើម្បីធានាថាគ្រូអាចតាមដាន និងគាំទ្រដល់ការសិក្សារបស់កុមារម្នាក់ៗ។

II. **ការរៀបចំទីធ្លា។** ការរៀបចំទីធ្លារឱ្យបានល្អ ដើម្បីជួយសម្រួលដល់សកម្មភាពសិក្សាដែលបានគ្រោងទុក ដោយចាប់ផ្ដើមពីប្រភេទ និងទំហំនៃគ្រឿងសង្ហារឹម រហូតដល់ប្លង់។ ធានាឱ្យបាននូវការបង្កើតរៀបចំមួយ**ដែលអាចបត់បែនបាន**សម្រាប់បរិស្ថានសិក្សាដែលអាចកែប្រែបានយ៉ាងងាយស្រួលក្នុងអំឡុងឆ្នាំសិក្សាដើម្បីឆ្លើយតបឱ្យកាន់តែប្រសើរឡើងចំពោះតម្រូវការសិក្សាដែលផ្ដល់ភាពរីកចម្រើន។

III. **ការបង្កើត៖** រំពឹងគិតថាតើសម្ភារៈសិក្សាណាដែលត្រូវប្រើ និងរបៀបរៀបចំវាដើម្បីជំរុញដល់ការរៀនសូត្រ។ ធានាថាកន្លែងសិក្សាត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ។ ជ្រើសរើសសម្ភារៈដែលលើកទឹកចិត្តដល់ការរៀនសូត្រក្នុងកម្រិតរីកចម្រើននៃភាពស្មុគស្មាញ ហើយវាជាសម្ភារៈដែលងាយស្រួលប្រើប្រាស់នៅក្នុងទីធ្លារសាលា។ ធានាបានថាសម្ភារៈទាំងអស់អាចមើលឃើញ និងអាចចូលប្រើប្រាស់បានសម្រាប់កុមារតូច[11]។




## I. សុវត្ថិភាព ភាពងាយស្រួល និងផាសុកភាព

| កត្តា | **គោលដៅ:** ផ្ដល់កន្លែងសិក្សាប្រកបដោយផាសុកភាព ងាយស្រួលចូលប្រើប្រាស់ និងជាកន្លែងដែលជួយគាំទ្រដល់កាសិក្សា |
|---|---|
| ផាសុកភាព | • រចនាបន្ទប់ដែលរួមបញ្ចូលធាតុដែលស្រដៀងនឹងការរៀបចំនៅក្នុងផ្ទះ (ឧ. ការរៀបចំកន្លែងអង្គុយ ពណ៌ សម្ភារៈ) ដើម្បីធ្វើឱ្យសិស្សមានអារម្មណ៍ស្រស់ស្រាយ។ |
| សុវត្ថិភាព | • ផ្ដល់ការការពារចំពោះភាពងាយរងគ្រោះចំពោះគ្រោះថ្នាក់នានា ជំងឺ ការប៉ះទង្គិចរាងកាយ ឬរបួស។ ធានាបានថាតំបន់មត្តេយ្យសិក្សាត្រូវបានការពារ និងហ៊ុំព័ទ្ធដោយរបង។ វត្ថុគ្រោះថ្នាក់គួរតែដាក់នៅឱ្យឆ្ងាយ។ គួរតែមានទឹកស្អាត និងអនាម័យគ្រប់គ្រាន់។<br>• ជៀសវាងការប្រើប្រាស់ការ៉ូសេរ៉ាមិច បើសិនជាអាចធ្វើទៅបានសម្រាប់កំរាលឥដ្ឋ។ ជ្រើសរើសសម្ភារៈទន់សម្រាប់កម្រាលឥដ្ឋដែលមិនរអិល (ឧ. កម្រាល ប្រភេទ PVC)<br><br>រូបភាពទី៣ ឧទាហរណ៍នៃកម្រាល PVC |

[10] ស្ថាបត្យកម្មសាលាសម្រាប់សតវត្សថ្មី ឆ្នាំ2020 ទំព័រ។ ។ . . ដូច្នេះ 'ការយល់ឃើញលើសចំណុះ' គឺជាអ្វីដែលការកំណត់អប់រំគួរព្យាយាមជៀសវាង។ នេះជាការលើកឡើងថា ការរចនាផ្នែកអប់រំតិចតួចមិនត្រឹមតែមានសោភ័ណភាពទាក់ទាញប៉ុណ្ណោះទេ ប៉ុន្តែក៏មានលក្ខណៈគរុកោសល្យផងដែរ»

[11] ការណែនាំអំពីការរចនាថែទាំកុមារតូច។ Rui Olds, A. (2000) McGraw-Hill

| | |
|---|---|
| លក្ខណៈងាយស្រួល | • លុបបំបាត់ចោលនូវឧបសគ្គដែលរារាំងដល់ការចូលទៅកាន់ទីធ្លាសាលារបស់កុមារតូច |
| កត្តាធម្មជាតិ | • *សីតុណ្ហភាព៖* ត្រូវធានាថាបន្ទប់មិនក្តៅពេក។ |
| | • *ពន្លឺធម្មជាតិ៖* ពន្លឺថ្ងៃនឹងជួយសម្រួលដល់ការសិក្សារបស់កុមារតូច និងជំរុញដល់ការផ្តោតអារម្មណ៍ ព្រមទាំងការច្នៃប្រឌិត |
| | • *គុណភាពខ្យល់៖* បង្អួចធំៗ សម្រាប់ឱ្យមានខ្យល់ចេញចូលបានល្អ។ |
| | • សូរស័ព្ទ៖ ត្រូវធានាថាថ្នាក់រៀនមិនស្ថិតនៅជាប់នឹងកន្លែងដែលមានសំឡេងរំខាន។ |
| | • *ការផ្សាភ្ជាប់ជាមួយធម្មជាតិ៖* ទិដ្ឋភាពខាងក្រៅ បើសិនជាអាចគួរតែអាចចូលទៅបានដោយផ្ទាល់ពីខាងក្រៅ។ ប្រើផ្ទាំងគំនូរលើជញ្ជាំង និងពិដានបែបធម្មជាតិ។ កត្តាទាំងនេះមិនត្រឹមតែអាចផ្តល់ជាការបន្ធូរអារម្មណ៍ទេ ប៉ុន្តែក៏អាចជួយជំរុញឱ្យមានការច្នៃប្រឌិតផងដែរ។ |
| ការផ្សាភ្ជាប់ & ការមើលឃើញ | • ត្រូវធានាថាថ្នាក់រៀនអាចចូលទៅកាន់ទីធ្លាខាងក្រៅដោយផ្ទាល់បាន ហើយមានបង្គន់នៅក្បែរនោះផងដែរ ដូច្នេះគ្រូអាចសង្កេតមើលកុមារតូច ក្នុងការផ្លាស់ទីនៅក្នុងបរិវេនសាលាបានយ៉ាងងាយស្រួល។ |

## II. ការរៀបចំទីធ្លា

| **គ្រឿងសង្ហារឹម** | **គោលដៅ:** លើកទឹកចិត្តឱ្យមានការស្រាវជ្រាវដោយខ្លួនឯង ឯករាជ្យ ការងារជាក្រុម ការគ្រប់គ្រងដោយខ្លួនឯង និងការស្វែងរករបៀបនៃការសិក្សាដោយផ្ទាល់ខ្លួន។ |
|---|---|
| ទំហំតម្រូវកុមារតូច | • គ្រឿងសង្ហារឹមដែលមានទំហំសមស្របសម្រាប់កុមារតូច [12]<br>• បង្អួចដែលមានទំហំសមស្របនឹងកម្ពស់កុមារតូច<br>• ទ្វារ, កន្លែងលាងដៃ និងបង្គន់ដែលរៀបចំឡើងបែប "កុមារមេត្រី" ដែលមានទំហំមាត់និងកម្ពស់សមស្របសម្រាប់កុមារតូច |
| ភាពបត់បែន | • ប្រើប្រាសសម្ភារៈស្រាលៗ សម្រាប់តុ និងកៅអីដើម្បីឱ្យសិស្សមានភាពងាយស្រួលក្នុងការផ្លាស់ទីគ្រឿងសង្ហារឹម នៅពេលដែលពួកគេត្រូវការដោយមិនចាំបាច់មានការអន្តរាគមន៍ពីសំណាក់គ្រូ<br>• កៅអី/គ្រឿងសង្ហារឹមត្រូវមានកង់ដើម្បីជួយក្នុងការផ្លាស់ទី។<br><br>*រូបទី៤ឧទាហរណ៍សម្រាប់គ្រឿសង្ហារឹមដែលមានកង់* |

[12] ឧបសម្ព័ន្ធ 2.1 ព័ត៌មានលម្អិតអំពីគ្រឿងសង្ហារឹម

| | |
|---|---|
| | • ផ្តល់**ការរៀបចំកន្លែងអង្គុយផ្សេងៗ គ្នា** គុ, កម្រាល, ជ្រុងមួយផ្ទាល់ខ្លួន, ខ្នើយ) និងអនុញ្ញាតិអោយសិស្សជ្រើសរើសកន្លែងដែលពួកគេចង់អង្គុយ តាមចំណង់ចំណូលចិត្ត និងតម្រូវការរបស់ពួកគេ។  *រូបទី៥ ឧទាហរណ៍នៃកន្លែងអង្គុយមានផាសុកភាព ប្រើក្នុងសាលា NGS* |
| **ប្លង់** | **គោលដៅ**: ផ្គុំប្លង់បន្ទប់ជាមួយនឹងយុទ្ធសាស្ត្របង្រៀន និងការរៀនរបស់គ្រូ និងតម្រូវការរបស់សិស្ស។ |
| ទីតាំងផ្សេងៗ | • គួរពិចារណាក្នុងការបង្កើតកន្លែងមួយបែបជាសាច់រឿងនៅក្នុងថ្នាក់រៀន។ ឧទាហរណ៍៖ MoEYS កំណត់ជ្រុងសម្រាប់ការអាន សិល្បៈ និងតន្ត្រី អក្ខរកម្ម និងលេខ វិទ្យាសាស្ត្រសង្គម និងអនាម័យ។  គួរពិចារណាក្នុងការដកតុរបស់គ្រូចេញ ដើម្បីឱ្យមានកន្លែងទំនេរច្រើនសម្រាប់សិស្ស (ផ្តល់ទូដាក់សម្ភារៈ) *រូបភាពទី៦ ឧទាហរណ៍នៃទូដាក់សម្ភារៈ* |
| | • កំណត់កន្លែងដាក់លាក់ណាមួយសម្រាប់ការងារជាក្រុម ការបើកអង្គប្រជុំពេញ ការងារជាបុគ្គល ឬជ្រុងលំហែកាយ |
| ភាពស្មុគស្មាញដែលអាចមើលឃើញ | • សូមកុំដាក់ព័ត៌មានច្រើនហួសប្រមាណនៅលើជញ្ជាំងដាក់តាំងអ្វីមួយនៅក្នុងផ្ទៃខាងក្រោយដែលអនុញ្ញាតឱ្យកុមារមានអារម្មណ៍ថាមានទំនាក់ទំនងជាមួយមរតកបុព្វបុរសរបស់ពួកគេ និងលិខិតសសើរផ្សេងៗ ក្នុងចំណោមមិត្តភក្តិរបស់ពួកគេ |
| ពណ៌ | **គោលការណ៍បង្រួម៖** បំភ្លឺជញ្ជាំង និងគ្រឿងសង្ហារឹមជាមួយនឹងពណ៌ភ្លឺៗ។ រក្សាពណ៌ចម្បង ១ កុំលាយពណ៌ និង/ឬបែបក្រឡេក្រឡាផ្សេងៗ។ នៅក្នុងសាលាមត្តេយ្យជំនាន់ថ្មី NGPS យើងបានសម្រេចចិត្តប្រើពណ៌ភ្លឺ ហើយរំលឹកឡើងវិញនូវពណ៌ដែលលេចចេញជាពណ៌ធម្មជាតិនៅតំបន់ជនបទ ឧ. ពណ៌បៃតង និងលឿង។ |

សូមមើលឧបសម្ព័ន្ធ2.1 ព័ត៌មានលម្អិតអំពីគ្រឿងសង្ហារឹមដែលបានណែនាំ។



*រូបភាពទី៧ ឧទាហរណ៍នៃធ្នើ របស់ម៉ុងតេសសូរីដែលសិស្សអាចចូលប្រើសម្ភារៈបានយ៉ាងងាយស្រួល*

## III. ការបង្កើត

**គោលដៅ** ជ្រើសរើសសម្ភារៈដែលលើកទឹកចិត្តដល់ការសិក្សា និងការស្រាវជ្រាវ។

## វិធីសាស្ត្រ

- ដាក់បង្ហាញសម្ភារៈតាមរបៀបដែលងាយស្រួលមើលនិងអាច យកមកប្រើបាន (ឧ. កម្ពស់គ្រឿងសង្ហារឹម ការរៀបចំស្អាត)។
- ធានាបានថាអ្នកមានសម្ភារៈគ្រប់គ្រាន់ ប៉ុន្តែមិនច្រើនពេកនោះទេ ព្រោះអ្នកចង់ឱ្យកុមារតូចរៀនអនុវត្តការចរចាជាមូលដ្ឋាន និងអាកប្បកិរិយាក្នុងការចែករំលែក។
- ជ្រើសរើសរវាងសម្ភារៈថ្មីៗ និងមានគេស្គាល់ ដើម្បីធ្វើឱ្យកុមារតូចមានការប្រកួតប្រជែង និងធ្វើឱ្យពួកគេមានអារម្មណ៍ថាវាស្ថិតក្នុងការគ្រប់គ្រងរបស់ពួកគេ។ ផ្សាំប្រកួតប្រជែងជាមួយកុមារតូចជាបណ្ដើរៗ នៅពេលដែលពួកគេទទួលបានការយល់ដឹងដោយការបន្ថែម ឬជំនួសសម្ភារៈដែលធ្លាប់ស្គាល់ជាមួយនឹងធាតុថ្មីៗ ទៀត។
- អនុញ្ញាតឱ្យកុមារតូចស្វែងយល់ដើម្បីទទួលបានការយល់ដឹងខណៈពេលដែលគ្រូធ្វើការសង្កេត និងណែនាំពួកគេនៅពេលចាំបាច់។
- ជ្រើសរើសសម្ភារៈផ្សេងៗដោយកំណត់គោលដៅសិក្សា។

  ឧទាហរណ៍:

  - **ណែនាំឱ្យមានការប្រើប្រាសសម្ភារៈជាក់ស្ដែង**ដូចជាគូបដែលជាប់គ្នា រូបរាង ពណ៌ ប៊ិច ជីស ថ្នាំលាប និងហ្គេមណាដែលអាចលើកទឹកចិត្តដល់ការអភិវឌ្ឍសមត្ថភាពរបស់កុមារតូចក្នុងការប្រើប្រាស់រាងកាយបានល្អ និងផ្ដល់ឱកាសសម្រាប់ការរៀនសូត្រពហុញ្ញាណ (ឧ. ការប៉ះ ការមើលឃើញ ។ល។)
  - **ប្រើការនិទានរឿង វីដេអូ និងរូបភាព**ដែលអាចណែនាំពីប្រធានបទនៃមេរៀននិង/ឬពង្រឹងអក្ខរកម្ម និងការអភិវឌ្ឍជំនាញភាសា។ តាមរយៈការដាក់បញ្ចូល ICT នៅក្នុងថ្នាក់រៀន គ្រូបង្រៀនអាចបង្ហាញសម្ភារៈនេះដល់កុមារតូចដោយប្រើទូរទស្សន៍ឆ្លាតវៃ និងថេបប្លេត ដើម្បីធ្វើឱ្យថ្នាក់រៀនកាន់តែមានអន្តរកម្ម និងគួរឱ្យចាប់អារម្មណ៍។
  - **ផ្ដល់ជាហ្គេមដែលអាចបង្កើតជាការអភិវឌ្ឍ**ដល់ការយល់ដឹងផ្សេងៗទៀត ដូចជាហ្គេមចងចាំ ល្បែងផ្គុំរូប និងសកម្មភាពដែលលើកទឹកចិត្តដល់ការតម្រៀប និងចាត់ថ្នាក់របស់របរជាដើម (ឧ. តម្រៀបប្រដាប់ក្មេងលេងតាមពណ៌ ប្រភេទ ឬទំហំ)។
  - **ប្រើសម្ភារៈដែលជួយសម្រួលដល់ការលេងជានិមិត្តសញ្ញា និងបង្ហាញឱ្យមានការលេង**ទាំងខាងក្នុងនិងខាងក្រៅថ្នាក់រៀន។នេះរាប់បញ្ចូលទាំងការប្រើប្រាស់វត្ថុដែលមានក្នុងជីវិតប្រចាំថ្ងៃ (ឧទាហរណ៍ ស្លាបព្រា ឬពែង ឬថ្មធម្មតា ឬបំណែកឈើដែលកុមារអាចបំប្លែងដោយការស្រមើលស្រមៃរបស់ពួកគេបាន)។



*រូបទី៨ ឧទាហរណ៍នៃសម្ភារៈជាក់ស្ដែង។*
*ប្រភព៖ TTO*

## ២.១.១ រចនាបថខាងក្នុងបន្ទប់រៀន

នៅក្នុងផ្នែកនេះ យើងបានលើកឡើងនូវឧទាហរណ៍មួយនៃការរចនាខាងក្នុងបន្ទប់រៀន ដែលអាចប្រាប់អំពីប្លង់បរិយាកាសរូបវន្តរបស់សាលាមត្តេយ្យជំនាន់ថ្មី NGPS ។ ស្ថាបត្យករ និងអ្នកជំនាញផ្នែកអប់រំ គួរប្រជុំរួមគ្នា និងរៀបចំដំណោះស្រាយដ៏ល្អបំផុតមួយដែលអាស្រ័យលើបរិស្ថាន តម្រូវការរបស់សិស្ស និងធនធានដែលមាន។

<table>
<tr>
<td></td>
<td>គ្រោងនេះបង្ហាញពីឧទាហរណ៍នេះ<br>ក) ការរចនាឱ្យតិចតួចបំផុត (១ពណ៌ចម្បង)<br>ខ)កន្លែងអង្គុយដែលអាចបត់បែនបាន (៥ ប្រភេទផ្សេងគ្នា)<br>គ) ការកំណត់តំបន់<br>ឃ)ការដាក់បញ្ចូលICT<br>(ឧ. កម្មវិធីទូរទស្សន៍ឆ្លាតវៃ)<br>ង)គ្រឿងសង្ហារឹមដែលផ្តោតលើកុមារតូច (កម្ពស់ទាប សម្ភារៈងាយស្រួលយកមកប្រើ)<br>ច) ការរៀបចំដែលអាចបត់បែនបាន (មានកង់រុញ និងគ្រឿងសង្ហារឹមទម្ងន់ស្រាល)<br>ឆ) ការចូលទៅទីធ្លាខាងក្រៅលក្ខណៈឯកជន<br>សូមមើលការបរិយាយខាងក្រោមសម្រាប់ការពន្យល់លម្អិតបន្ថែមទៀតនៃការរៀបរាប់ទាំងអស់ខាងលើ។</td>
</tr>
</table>

ក) <u>ការរចនាតិចតួចបំផុត។</u> ដោយទទួលបានការបំផុសគំនិតពីសៀវភៅដៃស្ថាបត្យកម្មសាលាជំនាន់ថ្មី (NGS)[13] សាលាមត្តេយ្យជំនាន់ថ្មី NGPS លើកកម្ពស់ "ការប្រើប្រាស់ពណ៌តែមួយ ដោយស្នើឱ្យប្រើប្រាស់ពណ៌ចម្បងតែមួយប៉ុណ្ណោះ" នៅក្នុងថ្នាក់រៀន ឬកន្លែងសិក្សា។ យោងទៅតាមទស្សនវិជ្ជានៃការរចនានេះ មានតែពណ៌មួយប៉ុណ្ណោះ (ឬការប្រែប្រួលដែលអាចកើតមាននៃពណ៌នោះ) គួរតែមាននៅក្នុងបន្ទប់ រួមជាមួយនឹងពណ៌ដែលស៊ីគ្នានឹងពណ៌ឯទៀត (ឧទាហរណ៍ ស ប្រផេះ និងខ្មៅត្រូវបានចាត់ទុកថាជាពណ៌ដែលស៊ីគ្នានឹងពណ៌ឯទៀត។ នៅក្នុងឧទាហរណ៍ដែលបានផ្តល់ជូនខាងលើ ពណ៌ស និងពណ៌ប្រផេះត្រូវបានប្រើប្រាស់)។ ឧទាហរណ៍នៃការរចនា សាលាមត្តេយ្យជំនាន់ថ្មី NGPS យើងមានបំណងជ្រើសរើសពណ៌បៃតង និងការប្រែប្រួលនៃស្រមោលរបស់វា ព្រោះវាជាពណ៌ដែលលេចធ្លោនៅ

[13] MoEYS (2020), ស្ថាបត្យកម្មសាលាសម្រាប់សតវត្សថ្មី៖ ការរចនាសាលាជំនាន់ថ្មី និងគោលការណ៍ណែនាំសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាភ័ណភ្ព"ភ្នំពេញ: អ្នកនិពន្ធ.

ក្នុងទីជនបទនៃប្រទេសកម្ពុជា ហើយយើងចង់នាំចូលទៅក្នុងថ្នាក់រៀននូវធាតុដែលកុមារធ្លាប់ស្គាល់នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍកុមារតូច។

| | |
|---|---|
| ខ) កន្លែងអង្គុយដែលអាចបត់បែនបាន។ ការរចនាដែលបង្ហាញពីការរៀបចំកន្លែងអង្គុយចំនួន ៥ ផ្សេងៗគ្នា៖<br>១. រៀបជ្រុងមួយខ្ពស់សម្រាប់ការអានដោយមានរួមជាមួយខ្នើយផងដែរ<br>២. មានកម្រាលនៅកណ្ដាលបន្ទប់សម្រាប់សកម្មភាពពេញលេញ<br>៣. កៅអីអង្គុយមានផាសុខភាពសម្រាប់ការធ្វើការងារផ្ទាល់ខ្លួន ឬការឆ្លុះបញ្ចាំង<br>៤. តុ និងកៅអីអង្គុយដែលមានកម្ពស់ទាប<br>៥.ខ្នើយដែលមានផាសុកភាពនិងកម្រាលឥដ្ឋនៅជិតទូរទស្សន៍ឆ្លាតវៃ | <br> |
| គ) ការកំណត់តំបន់។ ការរចនានេះផ្ដល់នូវលទ្ធភាពនៃការរៀបចំកន្លែងសិក្សាទៅជាតំបន់មួយៗ ដោយកំណត់ជ្រុងផ្សេងៗគ្នា សម្រាប់សកម្មភាពផ្សេងៗគ្នា។ ដូចរូបភាពបង្ហាញ៖<br>• កន្លែងសម្រាប់ការសិក្សាអំពីសង្គម និងវិទ្យាសាស្ត្រ (វាត្រូវបានណែនាំឱ្យជ្រុងមួយនេះនៅជិតបង្អួច ក្នុងករណីដែលកុមារតូចត្រូវការពន្លឺសម្រាប់ការពិសោធន៍ ឧ. គ្រាប់ពូជដែលកំពុងលូតលាស់)<br>• កន្លែងសម្រាប់ការសិក្សាអំពីការអាន (អាចប្រើសម្រាប់ការសិក្សាតន្ត្រី និងសិល្បៈផងដែរ)<br>• កន្លែងសម្រាក់សម្រាក (ជាកន្លែងដែលកុមារតូចអាចប្រើនៅពេលពួកគេត្រូវការពេលតែម្នាក់ឯងដើម្បីធ្វើការឆ្លុះបញ្ចាំង ឬធ្វើការងារបុគ្គល)<br>• កន្លែងសម្រាប់ការសិក្សាលេខនិងអក្ខរកម្ម(សម្ភារៈសម្រាប់មុខវិជ្ជាទាំងនេះត្រូវបានបង្ហាញ)<br>• កន្លែងសម្រាប់ការងារជាក្រុម នៅចំកណ្ដាលបន្ទប់<br>• កន្លែងសម្រាប់កាសិក្សា ICT នៅជាប់ទូរទស្សន៍ឆ្លាតវៃ | <br> |

| | |
|---|---|
| • កន្លែងអនាម័យ ត្រូវមានតម្រងទឹក ពែង និងឧបករណ៍សង្គ្រោះបន្ទាន់។ | |
| ឃ) ការដាក់បញ្ចូល ICT ។ បន្ទប់នេះត្រូវបានបំពាក់ដោយទូរទស្សន៍ឆ្លាតវៃ។ គ្រូបង្រៀនត្រូវបានណែនាំឱ្យប្រើថេបប្លេតដើម្បីបង្ហាញព័ត៌មាននៅលើកញ្ចក់ទូរទស្សន៍។ |  |
| ង) គ្រឿងសង្ហារិមដែលផ្តោតលើកុមារ។ គ្រឿងសង្ហារិម កៅអី និងតុទាំងអស់ត្រូវបានរចនាឡើងដើម្បីប្រើប្រាស់សម្រាប់កុមារតូច។ សម្ភារៈទាំងអស់នឹងត្រូវបានដាក់បង្ហាញដែលវាមានកម្ពស់សមស្របសម្រាប់កុមារតូចក្នុងការប្រើប្រាស់ (គ្រឿងសង្ហារឹម និងតុត្រូវបានណែនាំប្រើកម្ពស់ ៦០០ មីលីម៉ែត្រ កៅអីខ្ពស់ ៣០០-៣៥០ ម.ម)។ |   |
| ច) ការរៀបចំដែលអាចបត់បែនបាន៖ ប្រើកង់ និងគ្រឿងសង្ហារឹមដែលមានទម្ងន់ស្រាលដើម្បីសម្រេចគោលបំណងនេះ។ អ្នករៀបចំផែនការ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) លើកទឹកចិត្តឱ្យប្រើប្រាស់សម្ភារៈដែលមិនប៉ះពាល់ដល់បរិស្ថាន (ឧ. ឈើ ឫស្សី សម្ភារៈកែច្នៃ)។ ទូដែលមានកង់នឹងធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការផ្លាស់ទីនៃទីតាំងគ្រឿងសង្ហារឹម និងផ្លាស់ប្តូរប្លង់បន្ទប់បានយ៉ាងងាយស្រួលអាស្រ័យលើសកម្មភាព។ |  |

| | |
|---|---|
| ឆ) ប្រកចូលទៅកាន់ទីធ្លាខាងក្រៅដោយផ្ទាល់។<br>ប្រកចូលទៅកន្លែងទំនេរនៅខាងក្រោយថ្នាក់រៀន (ដែលអាចចូលទៅបានដោយការបើកទ្វារធំ ឬបំបាត់ជញ្ជាំងមួយផ្នែក ឬក៏ទាំងស្រុង) នឹងអនុញ្ញាតឱ្យគ្រូប្រើកន្លែងខាងក្រៅជាផ្នែកបន្ថែមនៃកន្លែងរៀនក្នុងទីធ្លា។ ការមានទីធ្លាខាងក្រៅដាច់ដោយឡែកពីកន្លែងក្មេងលេងនៃសាលាបឋមសិក្សានឹងធ្វើឱ្យវាកាន់តែងាយស្រួលនិងមានសុវត្ថិភាពសម្រាប់គ្រូក្នុងការរៀបចំនិងតាមដានសកម្មភាពសម្រាប់កុមារតូចៗ។ | <br>Private outdoor space at the back of the classroom with private entrance |

## ២.៣ ទីធ្លាខាងក្រៅ

ស្ថិតក្នុងបរិយាកាសខាងក្រៅដែលរៀបចំបានល្អគួរតែផ្តល់នូវកន្លែងសិក្សាដែលកុមារអាចធ្វើសកម្មភាពយ៉ាងសកម្មបាន និងអភិវឌ្ឍជំនាញរាងកាយ ក៏ដូចជាទំនុកចិត្ត។ កន្លែងបែបនេះអាចជំរុញការអភិវឌ្ឍន៍នៃកិច្ចសហការ ជំនាញសង្គម ភាពច្នៃប្រឌិត និងអាកប្បកិរិយាវិជ្ជមានបាន។ ទាំងអស់នេះអាចសម្រេចបានដោយការរៀបចំប្លង់អោយបានត្រឹមត្រូវតាមតម្រូវការ ការជ្រើសរើសឧបករណ៍ត្រឹមត្រូវសម្រាប់ការលេង និងដោយការផ្សព្វផ្សាយប្រភេទផ្សេងៗនៃសកម្មភាព ដែលរួមមានការលេង (ការលេងដោយសេរី និមិត្តសញ្ញា ឬរូបតំណាង) បទពិសោធន៍អារម្មណ៍ ការប្រើប្រាស់សម្ភារៈពិតៗ ការអាន ឬតន្ត្រីនៅក្រៅបរិវេន សាលា។ ដើម្បីសម្រេចបាននូវកម្រិតនៃការរំញោចនេះ ខណៈពេលដែលធ្វើការរចនាបរិវេនខាងក្រៅសាលា សាលារៀនត្រូវពិចារណាលើធាតុដូចខាងក្រោម៖

I. ភាពគតិដែលនៅជិតគ្នា
II. ការបែងចែក
III. គន្លឹះសុវត្ថិភាព
IV. គោលបំណងនៃគន្លឹះសុវត្ថិភាព

**I. ភាវគតិដែលនៅជិតគ្នា៖** សំដៅទៅលើភាពជិតនៃទីធ្លាលេងខាងក្រៅ និងថ្នាក់រៀន ដើម្បីឱ្យមានភាពងាយស្រួលក្នុងធ្វើដំណើរចូលទៅកាន់ទីធ្លាខាងក្រៅ ដែលអនុញ្ញាតឱ្យគ្រូអាចតាមដានសិស្សបានយ៉ាងងាយស្រួល។សាលាមត្តេយ្យត្រូវបានលើកទឹកចិត្តឱ្យរៀបចំកន្លែងបែបនេះនៅខាងក្រោយអាគារសម្រាប់គោលបំណងនេះបន្ថែមពីលើទីធ្លាខាងមុខ។ កន្លែងទំនេរនៅខាងក្រោយថ្នាក់រៀនជាធម្មតាមិនមានការរៀបចំទេ ហើយជារឿយៗ ពោរពេញដោយសម្រាម។សាលារៀនអាចបំប្លែងលំហនេះទៅជា

កន្លែងដែលមានមុខងារច្រើនជាងមុន ដែលអាចឱ្យសិស្សមត្តេយ្យសិក្សាអាចសម្រាក អាននិងធ្វើសកម្មភាពជាក្រុមបានដោយហេតុនេះអាចឱ្យទីធ្លាលេងក្រៅជាកន្លែងបន្ថែមសម្រាប់ខាងក្នុងថ្នាក់រៀន។នេះក៏នឹងអនុញ្ញាតឱ្យសាលារៀនប្រើប្រាស់ទីធ្លាឱ្យបានល្អបំផុតផងដែរ។



*រូបភាពទី៩ ឧទាហរណ៍នៃកន្លែងទំនេរនៅខាងក្រោយថ្នាក់រៀន - សាលា NGS*

II. **ការបែងចែក៖** លំហរខាងក្រៅដែលបានរចនាគួរតែត្រូវបានបម្រុងទុកសម្រាប់តែសិស្សមត្តេយ្យសិក្សាប៉ុណ្ណោះ ដែលតម្រូវឱ្យមានការប្រើប្រាស់របាំងការពារដូចជា របងជាដើម។ នៅពេលដែលមិនអាចសម្រេចបាននូវការញែកចេញពីគ្នារវាងកន្លែងលេងសម្រាប់កុមារតូចនៅមត្តេយ្យសិក្សាគឺដោយសារតែកន្លែងលេងរបស់កុមារតូចមានតែមួយគត់នៅក្នុងបរិវេណសាលាឬដោយសារតែកន្លែងទំនេរមានកំណត់ និងមិនអាចបែងចែកជាពីរតំបន់ដាច់ដោយឡែកពីគ្នាបាន វាត្រូវបានគេផ្តល់អនុសាសន៍ឱ្យលើកកម្ពស់ការចែករំលែកកន្លែងដែលមាននៅសល់ដោយធានាថា សិស្សមត្តេយ្យសិក្សាអាចចូលទៅកាន់តំបន់នោះ និងចូលទៅកាន់ឧបករណ៍ទាំងនោះដូចដែលសិស្សបឋមសិក្សាដែរ។ ព្យាយាមរៀបចំទីធ្លាខាងក្រោយសាលាជាតំបន់ឯកទេសសម្រាប់សិស្សមត្តេយ្យសិក្សា ដើម្បីឱ្យពួកគេអាចលេង ឬអានបានដោយសេរី ដោយបង្កភាពងាយស្រួលដល់គ្រូក្នុងការត្រួតពិនិត្យ។

III. **សុវត្ថិភាព៖** នៅក្រោមគោលការណ៍ណែនាំនេះ សាលារៀនគួរតែធានាថាទីធ្លាខាងក្រៅត្រូវនៅឆ្ងាយ ឬមានសុវត្ថិភាពត្រឹមត្រូវពីផ្លូវធំ និងស្រះទឹកដែលជ្រៅ។ ច្រកទ្វារគួរតែត្រូវបានបិទក្នុងអំឡុងពេលលេង ជៀសវាងកុមារតូចចាកចេញពីបរិវេណដោយមិនដឹងខ្លួន។ ពិនិត្យមើលថាកន្លែងទំនេរមិនមានវត្ថុមុតស្រួច រុក្ខជាតិដែលបង្កគ្រោះថ្នាក់ និងសម្ភារៈ ឬឧបករណ៍ដែលគេបោះចោល។ ធុងសម្រាមគួរតែមាន។ ឧបករណ៍សម្រាប់លេង និងរៀនត្រូវសមស្របនឹងអាយុ ទំហំកុមារ និងការលូតលាស់មួយដែលសមស្រប។

IV. **គោលបំណងនៃទីធ្លា៖** ការបញ្ជាក់ពីគោលបំណងនៃទីធ្លាសាលាអាចសម្រេចបានដោយជ្រើសរើសឧបករណ៍សម្រាប់កន្លែងលេងរបស់កុមារដោយប្រុងប្រយ័ត្ន ចាប់ផ្តើមដោយសំណួរ៖ *"តើយើងចង់ឱ្យសិស្សធ្វើអ្វី និងរៀននៅបរិវេនខាងក្រៅដែរឬទេ ?"* គោលបំណងដែលអាចមានរួមមានដូចខាងក្រោម៖

- អភិវឌ្ឍសមត្ថភាពរបស់កុមារក្នុងការប្រើប្រាស់រាងកាយ ដោយជ្រើសរើសឧបករណ៍ និងសកម្មភាពដែលត្រឹមត្រូវ។
- លើកទឹកចិត្តការលេងដោយសេរី
- រំញោចអារម្មណ៍ (ដោយផ្តល់ឧបករណ៍ចម្រុះពណ៌ រួមទាំងកណ្តឹង និងជួងជាដើម ល។)

- ស្វែងយល់ពីផ្នែកខាងក្រៅ និងធ្វើសកម្មភាពបុគ្គល និងជាក្រុម

## ២.៣.១ ការណែនាំលម្អិតសម្រាប់ឧបករណ៍ និងសម្ភារៈសិក្សា

| ក. ឧបករណ៍លេង | **គោលដៅចម្បង:** ជំនាញក្នុងការប្រើប្រាស់រាងកាយដែលមិនសមរម្យ/ល្អ និង ជំនាញសង្គម-អារម្មណ៍ |
|---|---|

- ដាក់បញ្ចូលឧបករណ៍លេងដូចជា ទោង ប្រអប់រំអិល ឧបករណ៍តោងឡើងជាដើម។ ជាឯកសារយោង សូមជ្រើសរើសជាតុកន្លែងលេងរបស់កុមារពី ២ ទៅ ៤។ ត្រូវប្រាកដថាឧបករណ៍មានទំហំសមស្របនឹងកុមារ ហើយសម្ភារៈមានសុវត្ថិភាព និងប្រើប្រាស់បានយូរដោយគ្មានជ្រុងមុតស្រួច។ ទាំងនេះគឺជាឧទាហរណ៍នៃឧបករណ៍ដើម្បី**លើកកម្ពស់*តុល្យភាព និងការសម្របសម្រួល***





ប្រភព៖ shorturl.at/xJY16 និង Odom Garden in Phnom Penh, by Native Landscape design.

- *ពិចារណាទៅលើឧបករណ៍ពហុមុខងារ*ដែលអនុញ្ញាតឱ្យកុមារអភិវឌ្ឍជំនាញក្នុងការប្រើប្រាស់រាងកាយដែលមានទាំងល្អ និងមិនល្អ ដូចជាការឡើងលើ និងចុះតាមជណ្តើរ តុល្យភាព ចលនាសម្របសម្រួល។ល។ពិចារណាបញ្ចូលជាតុទាំងនេះនៅក្នុងរចនាសម្ព័ន្ធខាងក្រៅ ទាក់ទងនឹងភ្នំ ឬការរំអិលលេងបែបធម្មជាតិ ឬ ផ្ទះតូចមួយដែលកុមារអាចឡើងបាន ប្រើសមត្ថភាពរបស់កុមារក្នុងការប្រើប្រាស់អវៈយវៈ និងមានភាពច្នៃប្រឌិត។






| | | |
|---|---|---|
| សួនច្បារឧត្តម *រៀបចំឡើងដោយការរចនាទេសភាពដើមកំណើតសម្រាប់ដំណោះស្រាយការរស់នៅទីក្រុង។* | | សួនច្បារឧត្តម *រៀបចំឡើងដោយការរចនាទេសភាពដើមកំណើតសម្រាប់ដំណោះស្រាយការរស់នៅទីក្រុង។* |

ជាទូទៅ មានលើកទឹកចិត្តឱ្យមានការលេងសកម្មជាងមុន ដូចជាការរត់ ការលោត និងការលោតរំលងក្នុងកន្លែងទំនេរជាដើម។ តែត្រូវប្រាកដថាមានកន្លែងគ្រប់គ្រាន់នៅក្នុងបរិវេនមត្តេយ្យសិក្សា។

**ខ.សម្ភារៈ** **គោលដៅចម្បង៖** ជំនាញក្នុងការប្រើប្រាស់អាវៈយវៈ ជំនាញយល់ដឹង ការអភិវឌ្ឍន៍ភាសា ជំនាញសង្គម-អារម្មណ៍។



*រូបភាពទី១០ ឧទាហរណ៍នៃវត្ថុធាតុដើមធម្មជាតិ៖ ថ្ម និងឈើ*

**វត្ថុធាតុដើមធម្មជាតិ។** ពិចារណារួមបញ្ចូលវត្ថុប្រចាំថ្ងៃក្នុងចំណោមសម្ភារៈសិក្សាដូចជា បាល់ ស្លាបព្រា ឬវត្ថុធាតុដើមធម្មជាតិ (ឧ. បន្ទះឈើ ឬរាងផ្សេងទៀតដែលលើកទឹកចិត្តដល់ការលេងជានិមិត្តសញ្ញាដែលអាចជារបស់ប្រើទាំងក្នុងនិងក្រៅបរិវេនសាលា)។



*រូបភាពទី១២ ឧទាហរណ៍តន្ត្រីដែលធ្វើឡើងពីសម្ភារៈកែច្នៃ*

**ភ្ជាប់អារម្មណ៍ផ្សេងៗគ្នា។** បង្កើតកន្លែងដែលកុមារអាចជួបរឿងដោយប្រើអារម្មណ៍ផ្សេងៗ (ឧ. ដី ទឹក សំឡេង វាយនភាព និងតន្ត្រី)។



*រូបភាពទី១១ ឧទាហរណ៍នៃការប្រើប្រាស់ដីសម្រាប់លេង។*

**លើកកម្ពស់បរិវេនខាងក្រៅជាកន្លែងសិក្សាដើម្បីលើកកម្ពស់ជំនាញសង្គម-អារម្មណ៍និងជំនាញក្នុងការយល់ដឹង**

ក. រចនាឱ្យមានកន្លែងដែលគ្រូអាចអានដល់សិស្ស
ខ.ធានាថាមានកន្លែងទំនេរដើម្បីអនុញ្ញាតឱ្យលេងដោយសេរី
គ.បង្កើតកន្លែងមួយដែលកុមារអាចធ្វើសកម្មភាពផ្សេងៗបាន
ឃ.កំណត់កន្លែងអង្គុយខ្លះទុកសម្រាប់ក្មេងប្រើប្រាស់ដើម្បីធ្វើកិច្ចការ ឬអានបាន (ឧ. កៅអីតូចៗ ជាពិសេសនៅចន្លោះខាងក្រោយថ្នាក់រៀនឬគ្រាន់តែប្រើកន្លែងអង្គុយដែលធន់នឹងសំណើម និងទឹកភ្លៀង)



*រូបភាពទី១៣ មជ្ឈមណ្ឌលសហគមន៍ថុន មុន ខេត្តតាកែវ គឺជាឧទាហរណ៍ដ៏អស្ចារ្យនៃការរៀបចំទីធ្លាដ៏សាមញ្ញ និងប្រកបដោយភាពច្នៃប្រឌិត។ ប្រភព: shorturl.at/lpwBW*

ង. បង្កើតសួនផ្កាជាមួយសិស្ស៖ សួនផ្កាផ្តល់ជូននូវសកម្មភាពជាច្រើនដែលអាចកំណត់គោលដៅជាច្រើននៃការរៀនសូត្រ ការអភិវឌ្ឍ និងជំរុញដល់ជំនាញទន់។

## បញ្ជីត្រួតពិនិត្យបរិស្ថានសិក្សា

ការពណ៌នា។ ប្រើបញ្ជីត្រួតពិនិត្យនេះដើម្បីជានាថាបរិយាកាសសាលារបស់អ្នកទាំងក្នុង និងក្រៅត្រូវគ្នានឹងលក្ខណៈវិនិច្ឆ័យរបស់សាលាមត្តេយ្យជំនាន់ថ្មី NGPS ជាអប្បបរមាដែលបានកំណត់។ សូមធ្វើឱ្យប្រាកដថា អ្នកមានបំណងចង់មានធាតុចូលទាំងអស់ ១00% នៅក្នុងថ្នាក់រៀនរបស់អ្នក។

| | លក្ខណៈវិនិច្ឆ័យ | ចាស/បាទ | ទេ |
|---|---|---|---|
| ១ | មិនមានសម្ភារៈមុតស្រួច ធ្ងន់ ឬគ្រោះថ្នាក់នៅក្នុងថ្នាក់រៀនទេ។ | | |
| ២ | មានកន្លែងអនាម័យដែលមានទឹកស្អាតសម្រាប់ទទួលទាន។ | | |
| ៣ | ថ្នាក់រៀនត្រូវបានបែងចែកទៅជាតំបន់សិក្សាផ្សេងៗគ្នា (ឧ. កន្លែងអាន កន្លែងប្រជុំ កន្លែងមើលទូរទស្សន៍ កន្លែងរៀនលេខ។ល។)។ | | |
| ៤ | ថ្នាក់រៀនផ្តល់នូវការរៀបចំកន្លែងអង្គុយផ្សេងៗគ្នា យ៉ាងហោចណាស់មាន ២ ឬច្រើនជាងនេះ។ | | |
| ៥ | គ្រឿងសង្ហារឹម បង្គន់ និងបង្ហួចមានទំហំសមស្រប និងកុមារ និងងាយស្រួលចូលប្រើប្រាស់។ | | |
| ៦ | មានផ្លូវចូលជាក់លាក់ទៅកាន់ទីធ្លាខាងក្រៅពីកន្លែងរៀនខាងក្នុង។ | | |
| ៧ | សម្ភារៈសិក្សាត្រូវបានបង្ហាញតាមរបៀបដែលកុមារអាចមើលឃើញបានយ៉ាងងាយ និងងាយស្រួលយកតាមខ្លួន។ | | |
| ៨ | មានពណ៌លេចធ្លោតែមួយគត់នៅក្នុងការរចនាថ្នាក់រៀន។ | | |
| ៩ | ជញ្ជាំងថ្នាក់រៀនបង្ហាញផលិតផលកុមារ មិនត្រឹមតែសម្ភារៈរចនារបស់គ្រូប៉ុណ្ណោះទេ។ | | |
| ១០ | កុមារមានកន្លែងសុវត្ថិភាពសម្រាប់រត់លេងដោយសេរីនៅខាងក្រៅ។ | | |
| សរុប | | | |

## ជំពូកទី ៣. យុទ្ធសាស្ត្រសិក្សា

សកលភាវូបនីយកម្មពិភពលោកថ្មីនេះគឺការអប់រំតាមបែបឌីជីថលនិងទំនាក់ទំនងសង្គមដែលតម្រូវឱ្យមានកំណែទម្រង់ថ្មីនៃការអប់រំដើម្បីសម្របខ្លួនទៅនឹងតម្រូវការថ្មីទាំងផ្នែកធនធានមនុស្សនិងសេដ្ឋកិច្ច។




*រូបភាព3.1: សាលាមត្តេយ្យជំនាន់ថ្មី (NGPS) 5 យុទ្ធសាស្ត្រសិក្សា*

ក្នុងបរិបទនេះ សាលាមត្តេយ្យជំនាន់ថ្មី (NGPS) ផ្តោតជាពិសេសលើយុទ្ធសាស្ត្រអប់រំចំនួនប្រាំ ដោយយើងមានការជឿជាក់ថា យុទ្ធសាស្ត្រទាំងនេះអាចគាំទ្រកុមារឱ្យក្លាយជាពលរដ្ឋសកម្ម និងចូលរួមបានកាន់តែប្រសើរនាពេលអនាគត ពោលគឺ៖

១. ការសិក្សាបែបសហការ
២. សេចក្តីណែនាំអំពីរបៀបរៀនខុសៗគ្នា
៣. ការដាក់បញ្ចូល ICT នៅក្នុងថ្នាក់រៀន
៤. គម្រោង និងការសិក្សាផ្អែកលើបញ្ហា ការសិក្សាបែបផ្អែកលើគម្រោង ផ្សារភ្ជាប់ពិភពពិតកម្មនឹងដំណើរការសិក្សា
៥. ការសិក្សាតាមរយៈការលេងល្បែង

កុមារនឹងអនុវត្តការសិក្សាតាមបែបសកម្មនិងការសហការគ្នាដូចជាជំនាញគិតកម្រិតខ្ពស់ដោយចូលរួមសកម្មភាពដែលនឹងតម្រូវឱ្យកុមារវិភាគព័ត៌មាន វាយតម្លៃនិងធ្វើការសម្រេចចិត្តឬបង្កើតគំនិតនិងបង្កើតផលិតផលថ្មី។នេះមានន័យថា គ្រូបង្រៀននឹងរៀនលើកឡើងអំពីសកម្មភាពដែលមានឥទ្ធិពលលើការអភិវឌ្ឍ និងការអនុវត្តក្រុមជំនាញទន់ ដែលសាលាជំនាន់ថ្មី (NGS) ចាត់ទុកថាជាយុទ្ធសាស្ត្រសម្រាប់ការកសាងមូលដ្ឋានគ្រឹះនៃសមត្ថភាពដែលនឹងនាំកុមារឱ្យក្លាយជាពលរដ្ឋកម្ពុជាដែលមានទំនួលខុសត្រូវ និងសកម្ម។

ជាលម្អិត សាលាជំនាន់ថ្មី (NGS) នឹងកំណត់គោលដៅសរុបនៃជំនាញទន់ចំនួន ៧ ដែលត្រូវបានដាក់ជាក្រុមស្ថិតនៅក្រោមជំនាញសំខាន់ៗចំនួន ៣។ ការអភិវឌ្ឍជំនាញបែបនេះត្រូវបានផ្សារភ្ជាប់យ៉ាងតឹងរ៉ឹងទៅនឹងការប្រើប្រាស់យុទ្ធសាស្ត្រទាំង ៥ ឱ្យបានសមស្របដូចដែលបានរៀបរាប់ខាងលើ។ ជាការពិត នៅពេលដែលគ្រូធ្វើការរចនា និងលើកឡើងនូវសកម្មភាពក្នុងថ្នាក់រៀន ពួកគេនឹងត្រូវលើកឡើងពីសកម្មភាពដែលនឹងអនុញ្ញាតឱ្យកុមារអនុវត្តជំនាញបែបនេះបាន។ ជាឧទាហរណ៍ កុមារនឹងមិនអាចបញ្ចេញគំនិតរបស់ពួកគេឱ្យបានច្បាស់លាស់ទេ ប្រសិនបើពួកគេមិនត្រូវបានសុំឱ្យពន្យល់ពីគំនិតរបស់ពួកគេឱ្យបានខ្លាំងៗឬដោយការចែករំលែកគំនិតជាមួយមិត្តភក្តិរបស់ពួកគេ។ ទាំងនេះជាជំនាញទន់ដែលគ្រូគួរធ្វើការពិចារណា៖

| មុខជំនាញ | គោលដៅជំនាញទន់ |
| --- | --- |
| ការទំនាក់ទំនងនិងការងារជាក្រុម | 1. ការទំនាក់ទំនង<br>2. ការសិក្សាបែបសហការ |
| ការវិភាគ និងការច្នៃប្រឌិត | 3. ការត្រិះរិះពិចារណា<br>4. ការដោះស្រាយបញ្ហា<br>5. ការច្នៃប្រឌិត |
| កុមារ គ្រួសារ និងសហគមន៍ | 6. ការគ្រប់គ្រងខ្លួនឯង<br>7. ការយល់ចិត្ត |

តារាងខាងក្រោមពិពណ៌នាអំពីជំនាញទន់នីមួយៗ យ៉ាងលម្អិត ជាមួយនឹងឧទាហរណ៍ជាក់លាក់នៃសកម្មភាពដែលគ្រូអាចដាក់បញ្ចូលនៅពេលធ្វើផែនការ។ការពន្យល់ទាំងនេះឆ្លុះបញ្ចាំងពីអ្វីដែលត្រូវបានសង្ខេបនៅក្នុងតារាងខាងលើ

| គោលដៅជំនាញទន់ | និយមន័យ[14] |
|---|---|
| ការទំនាក់ទំនង | ការប្រាស្រ័យទាក់ទងគ្នា ឬអាចប្រាស្រ័យទាក់ទងគ្នា ពាក់ព័ន្ធនឹងការចែករំលែកអត្ថន័យ តាមរយៈការផ្លាស់ប្តូរព័ត៌មាន និងការយល់ដឹងជារួម។ វាកើតឡើងនៅក្នុងបរិបទនៃទំនាក់ទំនងសង្គម។ ការប្រាស្រ័យទាក់ទងអាចជាការប្រាស្រ័យទាក់ទងផ្ទាល់មាត់ សរសេរ និងមិនមែនពាក្យសំដី ហើយវាមានសារៈសំខាន់នៅក្នុងដំណើរការសិក្សាទាំងអស់។ |
| កិច្ចសហការ | កិច្ចសហប្រតិបត្តិការ គឺជាទង្វើ ឬដំណើរការនៃការធ្វើការរួមគ្នា ដើម្បីសម្រេចបាននូវគោលបំណងរួម ឬផលប្រយោជន៍ទៅវិញទៅមក ទាំងសម្រាប់បុគ្គលម្នាក់ៗដែលសហការគ្នា ឬធ្វើសកម្មភាពដោយសហការគ្នា (Tyler, 2011)។ |
| ការត្រិះរិះពិចារណា | ការត្រិះរិះពិចារណា គឺជាដំណើរការផ្លូវចិត្តដ៏ស្មុគស្មាញមួយដែលអាចអនុវត្តទៅបានជាសាកល និងជាប់ពាក់ព័ន្ធទៅនឹងជំនាញជាច្រើន៖ ការញែកការពិតចេញពីគំនិត ការទទួលស្គាល់ការសន្មត ការសួរអំពីសុពលភាពនៃភស្តុតាង ការចោទសួរសំណួរ ការផ្ទៀងផ្ទាត់ព័ត៌មាន ការស្តាប់ ការសង្កេត និងការយល់ដឹងពីទស្សនៈជាច្រើនទៀត (Lai, 2011) ។ |
| ការដោះស្រាយបញ្ហា | អ្នកកដោះស្រាយបញ្ហាមានសមត្ថភាពក្នុងការ 'គិតតាមរយៈជំហានៗ ដែលដឹកនាំចេញពីស្ថានភាពនៃសាច់រឿងទៅកាន់គោលដៅដែលចង់បាន។ វាទាមទារឱ្យអ្នកដោះស្រាយកំណត់បញ្ហា រៀបចំផែនការអនុវត្តដំណោះស្រាយ និងតាមដាន និងវាយតម្លៃវឌ្ឍនភាពពេញមួយសកម្មភាព។ |
| ភាពច្នៃប្រឌិត | វាជាសមត្ថភាពក្នុងការបង្កើត បញ្ជាក់ ឬអនុវត្តគំនិតច្នៃប្រឌិត បច្ចេកទេស និងទស្សនវិស័យ (Ferrari et al. 2009) នៅក្នុងបរិយាកាសសហការ/សាលារៀន។ |
| ការគ្រប់គ្រងខ្លួនឯង | ជំនាញស្នូលសម្រាប់ជីវិត ការគ្រប់គ្រងខ្លួនឯង ឬទាំងការគ្រប់គ្រងខ្លួនឯង និង 'ធ្វើការគ្រប់គ្រងខ្លួនឯង' គឺជាសមត្ថភាពរបស់បុគ្គលក្នុងការគ្រប់គ្រង និងត្រួតពិនិត្យអាកប្បកិរិយា ចិត្ត អារម្មណ៍ និងកម្លាំងជំរុញរបស់ពួកគេ។ |
| ការយល់ចិត្ត | ការយល់ចិត្តគឺជា "សមត្ថភាពដើម្បីយល់ពីអារម្មណ៍របស់អ្នកដទៃ ហើយធ្វើឲ្យពួកគេមានបទពិសោធន៍ឡើងវិញដោយខ្លួនឯង" (Salovey and Mayer, 1990) ខណៈពេលដែលមិនដែលត្រូវបានគេវិនិច្ឆ័យ។ |

[14] DCD/MoEYS (2019)។ កម្មវិធីសិក្សាជំនាញជីវិតថ្នាក់តំបន់ ចាប់ពីថ្នាក់ទី៤ ដល់ទី៦ "តារាងសង្ខេប៖ ជំនាញសម្រាប់ការសិក្សា និងសកម្មភាព" (យូនីសេហ្វ)

| ៣.១ ការសិក្សាបែបសហការ<br>**គោលដៅចម្បងជំនាញទន់** | ការសិក្សាបែបសហការ ការដោះស្រាយបញ្ហា ការទំនាក់ទំនង ការច្នៃប្រឌិត ការយល់ចិត្ត។   |
|---|---|

យុទ្ធសាស្ត្រសិក្សាតាមបែបសហការការគឺផ្អែកលើគំនិតដែលថាការរៀនអាចកើតឡើងតាមរយៈការសហការជាមួយអ្នកដទៃ និងបញ្ជាក់ថាកុមារសហការគ្នាដើម្បីដោះស្រាយកិច្ចការមួយ។

KAPE គឺជាអ្នកជំរុញទីមួយនៃយុទ្ធសាស្ត្រសិក្សានេះ ដើម្បីជំរុញឱ្យមានការចូលរួមនៅក្នុងថ្នាក់រៀនតាមរយៈការលើកទឹកចិត្តឱ្យមានអន្តរកម្មរវាងសិស្ស។

យុទ្ធសាស្ត្រសិក្សាតាមបែបសហការការនិង/ឬសហការគ្នា អាចត្រូវបានប្រើក្នុងការបង្រៀនមុខវិជ្ជាណាមួយ។

### ៣.១.១ តួនាទីរបស់គ្រូ

គ្រូបង្រៀនគឺជាគន្លឹះក្នុងការអនុវត្តការសិក្សារួមគ្នាតាមរយៈការណែនាំ និងសម្របសម្រួលការងាររបស់កុមារជា ក្រុម។ ជាទូទៅ ដើម្បីលើកកម្ពស់ការសិក្សារួមគ្នា គ្រូបង្រៀននឹងត្រូវៈ

- បង្កើតបរិយាកាសមានសុវត្ថិភាព និងផាសុកភាព ដែលអនុញ្ញាតឱ្យសិស្សមានអារម្មណ៍ថាមានសេរីភាពក្នុងការបញ្ចេញមតិ
- ផ្តល់ការងារច្បាស់លាស់ដល់កុមារ
- ជំរុញឱ្យធ្វើការងារជាក្រុមក្នុងថ្នាក់រៀន។ ទំហំនៃក្រុមនឹងអាស្រ័យលើកត្តាជាច្រើន រួមទាំងប្រភេទនៃសកម្មភាព ទំហំថ្នាក់រៀន និងចំនួនសិស្សសរុប។ ការងារជាក្រុមអាចកើតឡើងក្នុងទម្រង់ជាច្រើនដូចជា ធ្វើការជាគូ ក៏ដូចជាក្រុមតូច និងមធ្យម (ចំនួនអតិបរមានៃសមាជិកក្នុងក្រុមមិនគួរលើសពី ៥ ឬ ៦)។
- លើកទឹកចិត្តឱ្យមានការពិភាក្សា ការចែករំលែកគំនិត ការសហការ និងការគាំទ្រគ្នាទៅវិញទៅមក ដើម្បីជំរុញឱ្យមាន**ការពឹងពាក់គ្នាទៅវិញទៅមកលក្ខណៈវិជ្ជមាន**រវាងកុមារ។

ទោះជាយ៉ាងណាក៏ដោយ មុននឹងលើកឡើងនូសកម្មភាពជាក្រុមសម្រាប់សិស្សមុនចូលសាលា គ្រូត្រូវធានាថាកុមារអាចចូលរួមការងារជាក្រុម និងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងនោះ។

អាស្រ័យដូចបានរៀបរាប់ជូនខាងលើ គ្រូអាចណែនាំកុមារឱ្យចូលរួមរៀនដោយសហការដោយលើកឡើងនូវសកម្មភាពសាមញ្ញមួយចំនួនដូចជាៈ

- **ការសន្ទនាជាក្រុម៖** ធ្វើឱ្យកុមារស៊ាំនឹងការនិយាយ និងចែករំលែកគំនិតរបស់ពួកគេជាមួយមិត្តភ័ក្តិផ្សេងទៀត ដូចដែលបានពន្យល់នៅក្នុងការណែនាំរបស់គ្រូ។
- **សហការក្នុងការលេងជាក្រុម៖** លើកយកហ្គេមដែលតម្រូវឱ្យកុមារសហការគ្នា។ ឧទាហរណ៍ ការប្រមាញ់កំណប់ ល្បែងផ្គុំរូបសាមញ្ញៗ សិល្បៈសហការ ហ្គេមលោតផ័ត្រយោង
- **ហ្គេម**ដែលផ្តោតលើការលើកកម្ពស់ដល់ជំនាញស្តាប់ ដូចជាឱ្យកុមារនិយាយជាមួយគ្នាទៅវិញទៅមក ដែលពួកគេត្រូវនិយាយឡើងវិញនូវអ្វីដែលមិត្តភក្តិរបស់ពួកគេបាននិយាយពីមុន ឬលេងហ្គេម "ខ្សឹបខ្សៀវចិន"។



សិល្បៈក្នុងការសហការ។ កុមារអាចជ្រើសរើសប្រធានបទសម្រាប់រូបភាពមួយ។ គ្រូជួយសម្រួលដោយផ្តល់ក្រដាស និងគូល័រពណ៌។ បំបែកកុមារជាក្រុមដែលពួកគេអាចពិចារណាអំពីទិដ្ឋភាពផ្សេងៗនៃរូបភាព។ គ្រូគួរតែអនុញ្ញាតឱ្យមានការរកវិធីធ្វើដោយខ្លួនឯងឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ប៉ុន្តែគ្រូនឹងជួយអន្តរាគមន៍ប្រសិនបើចាំបាច់ ដើម្បីជួយដោះស្រាយបញ្ហា។
<u>ជំនួយ និងការណែនាំ៖</u> គ្រូនឹងផ្តល់ការណែនាំដើម្បីធានាថាកុមារកំពុងចែករំលែកគំនិត និងកំណត់កិច្ចការសម្រាប់ធ្វើ។ ប្រសិនបើសិស្សម្នាក់សុំគូរពណ៌ខៀវ ហើយសិស្សម្នាក់ទៀតសុំប្រើពណ៌ក្រហមក្នុងតំបន់តែមួយ គ្រូអាចនឹងសួរថា "តើនឹងមានអ្វីកើតឡើងប្រសិនបើយើងលាយពណ៌ទាំងពីរចូលគ្នា?"។ សម្របសម្រួលការសន្ទនា និងជួយកុមារដោះស្រាយបញ្ហា។ សកម្មភាពនេះជួយបង្រៀនកុមារឱ្យចេះប្រាស្រ័យទាក់ទងគ្នា និងនិយាយតាម រយៈអ្វីដែលពួកគេនឹងធ្វើ ដើម្បីបញ្ចប់កិច្ចការ។ *ប្រភព៖*Edutopia.org.

**ឧទាហរណ៍មួយចំនួននៃយុទ្ធសាស្ត្រសិក្សាក្នុងកិច្ចសហប្រតិបត្តិការដើម្បីប្រើប្រាស់ក្នុងថ្នាក់រៀន**[15]

| **ឈ្មោះសកម្មភាព** | **គោលបំណងនៃសកម្មភាព** | **ពិពណ៌នាអំពសកម្មភាព** |
|---|---|---|
| ជុំរ៉ូប៊ីន( Round Robin ) | បង្កើតគំនិតថ្មីៗ *(ភាពច្នៃប្រឌិត)* | កុមារម្នាក់ៗនឹងប្តូរវេនឆ្លើយសំណួរមួយ។ ជាឧទាហរណ៍ គ្រូចង់ស្វែងរកពាក្យដែលចាប់ផ្តើមដោយ "ក" ហើយនឹងសួរកុមារម្តងមួយៗ ឱ្យគិតអំពីពាក្យមួយ ហើយចែករំលែកជាមួយក្រុមរបស់ពួកគេ។ កុមារនឹងត្រូវគោរពវេនរបស់ពួកគេ។ |
| កម្រងសំណួរ - ការដោះដូរ ( Quiz-Quiz-Trade ) | បង្កើតគំនិតថ្មីៗ។ ការស្តាប់។ *ការសន្ទនាដោយផ្ទាល់មាត់។* | កុមារម្នាក់ៗនឹងធ្វើការជាគូ៖ កូនសិស្សម្នាក់នឹងសួរសំណួរមួយ ហើយម្នាក់ទៀតនឹងឆ្លើយ។ បន្ទាប់មក ពួកគេនឹងផ្លាស់ប្តូរវេនសម្រាប់សួរ និងឆ្លើយសំណួរ។ |

[15] ការមើលថែកុមារតូចនៅថ្នាក់មតេយ្យសិក្សា, កម្មវិធីសិក្សាសម្រាប់សាលាមត្តេយ្យក្នុងប្រទេសសិង្ហបុរី, ការណែនាំអំពីអ្នកអប់រំ (2013) ។ ក្រសួងអប់រំសិង្ហបុរី

| | | |
|---|---|---|
| គិត-គូរ-ចែករំលែក (Think-Pair-Share) | បង្កើតគំនិតថ្មីៗ។ ស្តាប់ ធ្វើការឆ្លុះបញ្ចាំង *ដោះស្រាយបញ្ហា។* | គ្រូនឹងសួរសំណួរមួយឱ្យកុមារគិត។ កុមារនឹងមានពេលមួយនាទីដើម្បីគិតតែម្នាក់ឯង ហើយបន្ទាប់មកនឹងធ្វើការជាគូដើម្បីព្យាយាមឆ្លើយ។<br>ជាឧទាហរណ៍ គ្រូអាចប្រើបច្ចេកទេសនេះ ដើម្បីធ្វើឱ្យកុមារឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់លាក់នៃរឿងដែលពួកគេកំពុងស្តាប់ ដើម្បីពិនិត្យមើលការយល់ដឹងរបស់ពួកគេ ឬធ្វើការទស្សន៍ទាយ។ |
| ការផ្តុំលេខរួមគ្នា (Numbered Heads Together) | បង្កើតគំនិតថ្មីៗ។ សហការ និងចែករំលែក។<br>(ការច្នៃប្រឌិត & កិច្ចសហការ) | គ្រូនឹងរៀបចំកុមារជាក្រុមតូចៗ។ សមាជិកនីមួយៗនៃក្រុមនឹងទទួលបានលេខមួយ។ នៅពេលគ្រូហៅទៅលេខនោះ កុមារទាំងអស់ដែលមានលេខនោះនឹងត្រូវបង្កើតក្រុមជាមួយគ្នា ដើម្បីព្យាយាមឆ្លើយសំណួរដែលគ្រូសួរ។ ពួកគេនឹងពិភាក្សាជាមួយគ្នា ហើយបន្ទាប់មកត្រឡប់ទៅក្រុមដំបូងវិញ ដើម្បីចែករំលែកចម្លើយ។ |
| ដើរក្នុងបន្ទប់បែបសិល្បៈ (Gallery Walk) | អភិវឌ្ឍជំនាញថ្មីៗ (ការឆ្លុះបញ្ចាំង ផ្តល់ជំនួយ ចែករំលែកយោបល់ *ការយល់ចិត្ត*) | ស្នាដៃរបស់កុមារនឹងត្រូវដាក់តាំងនៅលើជញ្ជាំង ឬនៅលើតុសម្រាប់ដាក់តាំង។ បន្ទាប់មក កុមារនឹងដើរជុំវិញ ហើយកុមារម្នាក់ៗនឹងពន្យល់ពីការងាររបស់ពួកគេ។ កុមារផ្សេងទៀតអាចផ្តល់យោបល់លើការងាររបស់មិត្តរបស់ពួកគេបានផងដែរ។ |

## ការឆ្លុះបញ្ចាំងដើម្បីគាំទ្រដល់ការទទួលបានការសិក្សា និងជំនាញសង្គម

ជាផ្នែកមួយនៃដំណើរការសិក្សា គ្រូត្រូវបានលើកទឹកចិត្តឱ្យសន្សំពេលវេលានៅចុងបញ្ចប់នៃសកម្មភាព ដើម្បីឆ្លុះបញ្ចាំងជាមួយកុមារអំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ រំឮកពីអារម្មណ៍របស់ពួកគេ អ្វីដែលពួកគេចូលចិត្តបំផុត និងមូលហេតុ ឬអ្វីដែលពួកគេអាចធ្វើបានប្រសើរជាងមុននៅពេលក្រោយ។ ប្រភេទនៃការអនុវត្តសំណួរទាំងនេះនឹងពង្រឹងចំណេះដឹង និងជំនាញដែលទទួលបានក្នុងអំឡុងពេលធ្វើសកម្មភាព។

សំណួរឧទាហរណ៍៖

| សំណួរសម្រាប់ | សំណួរឧទាហរណ៍ |
|---|---|
| ដំណើរការសិក្សា, ការរៀនដើម្បីរៀន | • តើអ្នកបានជួបប្រទះនឹងបញ្ហាអ្វីខ្លះក្នុងអំឡុងពេលធ្វើសកម្មភាពនេះ? តើអ្នកបានដោះស្រាយវាដោយរបៀបណា?<br>• តើអ្នកចូលចិត្តអ្វីជាងគេ? ហេតុអ្វី? |

| | |
|---|---|
| | • តើអ្នកអាចធ្វើយ៉ាងណាបន្តទៀតដើម្បីឲ្យបានកាន់តែប្រសើរជាងនេះនៅពេលក្រោយ? <br> • តើយើងបានរៀនអ្វីខ្លះពីសកម្មភាពនេះ? |
| ការប្រៀបធៀបគំនិតរបស់អ្នកដទៃ | • ហេតុអ្វីបានជាអ្នកគិតថាមិត្តភក្តិរបស់អ្នកគិតដូច្នេះ? <br> • ហេតុអ្វីបានជាអ្នកគិត.....? <br> • តើអ្នកឃើញភាពស្រដៀងគ្នាជាមួយ.....? <br> • តើអ្នកឃើញភាពខុសគ្នារវាងគំនិតរបស់អ្នក និង គំនិតរបស់......ទេ? |
| ការបង្ហាញពីអារម្មណ៍ | • តើអ្នកមានអារម្មណ៍យ៉ាងណាក្នុងអំឡុងពេលធ្វើសកម្មភាព? <br> • តើអ្នកចូលចិត្តអ្វីអំពីសកម្មភាពនេះ? <br> • តើអ្នកធ្លាប់មានអារម្មណ៍...? |
| កិច្ចសហប្រតិបត្តិការ ទំនាក់ទំនងវិជ្ជមាន | • តើអ្នកចូលចិត្តអ្វីអំពីការងារជាក្រុម? តើអ្នកចូលចិត្តធ្វើការជាមួយគ្នាទេ? ហេតុអ្វី? <br> • តើអ្នកអាចរៀបរាប់ពីបញ្ហាមួយដែលអ្នកបានជួបប្រទះពេលធ្វើការជាក្រុមបានទេ? <br> • តើអ្នកបានសុំជំនួយពីមិត្តភ័ក្តិរបស់អ្នកក្នុងពេលកំពុងធ្វើសកម្មភាពដែរឬទេ? <br> • តើអ្នកបានជួយមិត្តភក្តិរបស់អ្នកណាម្នាក់ក្នុងអំឡុងពេលសកម្មភាពដែរឬទេ? |

## ៣.២ សេចក្តីណែនាំពីរបៀបរៀនប្លែកៗគ្នា

| | |
|---|---|
| **គោលដៅចម្បងសម្រាប់ជំនាញទន់** | ការគ្រប់គ្រងខ្លួនឯង ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការទំនាក់ទំនង។ |




កុមាររៀនតាមរបៀបខុសៗគ្នានិងតាមវិធីខុសៗគ្នា ហើយវាត្រូវបានគេបង្ហាញថាកុមាររៀនបានប្រសើរជាងមុននៅក្នុងសាលា នៅពេលដែលរបៀបនៃការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានគេទទួលស្គាល់ និងគាំទ្រ[16]។ អ្នកខ្លះរៀនបានប្រសើរដោយការស្តាប់ចម្រៀង អ្នកខ្លះទៀតរៀនបានប្រសើរ

[16] Howard Gardner's (1983), ក្របនៃចិត្តៈ ទ្រឹស្តីពហុនៃភាពវៃឆ្លាត

ដោយមើលរូបភាព ហើយអ្នកខ្លះទៀតនឹងរៀនបានកាន់តែប្រសើរដោយការគូររូបឬចូលរួមយ៉ាងសកម្ម ក្នុងការងារក្រុម។

ជំហានដំបូងក្នុងការយល់ដឹងកាន់តែច្បាស់អំពីយុទ្ធសាស្ត្រសិក្សានេះគឺត្រូវស្វែងយល់អំពីរបៀបរៀន របស់កុមារម្នាក់ៗ ជាពិសេសក្នុងអំឡុងពេលសប្ដាហ៍ដំបូងនៃការចូលរៀន ហើយបន្ទាប់មកដើម្បីចាប់ផ្ដើមលើកយកបទពិសោធន៍សិក្សាផ្សេងៗដែលត្រូវនឹងតម្រូវការរបស់កុមារ។
គំរូសាលាមត្តេយ្យជំនាន់ថ្មី (NGPS) នឹងផ្ដោតលើរចនាបថសិក្សាសំខាន់ៗ ចំនួន ៣៖
១. ការមើលឃើញ
២. ការស្ដាប់
៣. ចលនាវិញ្ញាណ/ចលនារាងកាយ
នៅពេលដែលរៀបចំកិច្ចតែងការបង្រៀន គ្រូបង្រៀនគួរតែធ្វើសកម្មភាពដែលអនុញ្ញាតឱ្យកុមាររៀន តាមរបៀបរៀនខុសៗគ្នា។ របៀបរៀនដែលលេចធ្លោជាងគេរបស់ពួកគេគឺជារបៀបរៀនដែលពួកគេចូលចិត្តប៉ុន្តែមិនចាំបាច់យកតែមួយគត់នោះទេ។

ជាឧទាហរណ៍នៅពេលបង្រៀនអំពីអារម្មណ៍ គ្រូអាចប្រើបណ្ណរូបភាពដើម្បីសង្ខេបពីអារម្មណ៍សំខាន់ៗ អំពីវិធីរៀន (តាមការមើល) សួរសំណួរ (តាមរយៈសម្លេង) ឬរៀបចំការសម្ដែងបែបសាមញ្ញដើម្បីធ្វើឱ្យកុមារឆ្លុះបញ្ចាំងពីអារម្មណ៍ខុសៗគ្នា (តាមរយៈចលនារាងកាយ) ។

| ប្រភេទអ្នកសិក្សា | បរិយាយ | សកម្មភាពដែលត្រូវបានណែនាំ |
|---|---|---|
| អ្នកសិក្សាដោយការមើល  | សម្រាប់អ្នកសិក្សាប្រភេទនេះ វានឹងកាន់តែងាយស្រួលក្នុងការចងចាំព័ត៌មាន នៅពេលដែលត្រូវបានបង្រៀនតាមរយៈ ការបង្ហាញជាមួយរូបភាព វីដេអូ ផ្ទាំងរូបភាព ឬក្រាហ្វិក។ ជារឿយៗអ្នកសិក្សាដោយការមើល ពួកគេនឹងស្គាល់លេខ និងអក្សរបានល្អជាងមិត្តភក្តិរបស់ពួកគេដែលចូលចិត្តរបៀបសិក្សាផ្សេងពីនេះ។ | ○ ប្រើរូបភាព ផ្ទាំងរូបភាព វីដេអូ និងរូបភាពផ្សេងទៀត ដើម្បីជួយកុមារឱ្យមើលឃើញព័ត៌មានដែលពួកគេកំពុងរៀននៅក្នុងថ្នាក់។<br>○ ធ្វើឱ្យពួកគេសង្កេតមើលពីស្ថានភាពជីវិតពិត។<br>○ ប្រើប្រាស់ស្ទីគ័រ ឬពណ៌ដើម្បីរៀបចំ និងសម្ភារៈដែលជាប់ពាក់ព័ន្ធ។ ប្រើក្រដាសកាតតូចៗ (flash cards)។ គូររូបភាពឬគំនូរជីវចលនៃគំនិតផ្សេងៗដែលបានបំផុសឡើង។<br>○ នៅពេលបញ្ជូនព័ត៌មាន សូមប្រើក្តារខៀន ឬទូរទស្សន៍ ឆ្លាតវៃ ឬឧបករណ៍ ICT បន្ថែមដែលមាននៅក្នុងថ្នាក់រៀន តាមដែលអាចធ្វើទៅបាន។ |
| អ្នកសិក្សាដោយការ  ស្តាប់ | អ្នកសិក្សាប្រភេទនេះយល់កាន់តែច្បាស់អំពីព័ត៌មានតាមរយៈការស្តាប់។ ពួកគេអាចនឹងចងចាំ ក៏ដូចជាយល់អំពីគោលគំនិតថ្មីៗបានប្រសើរជាងមុន នៅពេលដែលពួកគេស្តាប់ ឬនិយាយរឿងមួយដោយខ្លួនឯង។ | ○ ប្រើបទចម្រៀង និងសំឡេងក្នុងការរៀន (ឧទាហរណ៍ រួមគ្នាទះដៃចំពោះសកម្មភាពណាមួយ) ឱ្យកុមារនិយាយខ្លាំងៗ ធ្វើការអញ្ជើញមនុស្សពីខាងក្រៅសាលាឱ្យមកនិយាយបង្ហាញនៅសាលា។<br>○ ឱ្យសិស្សចូលរួមក្នុងការសន្ទនាអំពីប្រធានបទណាមួយដែលជាប់ពាក់ព័ន្ធ។<br>○ សួរសិស្សអំពីសម្ភារៈដែលពួកគេកំពុងរៀន។<br>○ ឱ្យកុមារធ្វើការសង្ខេបផ្ទាល់មាត់។ អានសម្ភារៈសិក្សាឱ្យពួកគេឱ្យឮៗ។ |
| អ្នកសិក្សាដោយចលនាវិញ្ញាណ  | អ្នកសិក្សាប្រភេទនេះរៀនបានល្អបំផុតដោយការរៀបចំគ្រប់គ្រងវត្ថុ និងចូលរួមក្នុងការធ្វើសកម្មភាពនានា។ | ○ ប្រើសម្ភារៈពិតៗដើម្បីបង្រៀន។<br>○ ប្រើប្លុកគំរូដើម្បីធ្វើផ្នែកក្នុងនៃគោលគំនិតគណិតវិទ្យាថ្មីៗ។<br>○ ប្រើសម្ភារៈដែលមានរាងជាអក្សរដែលពួកគេអាចលេងជាមួយបានដើម្បីរៀនអក្ខរក្រម។<br>○ ជួយសម្រួលដល់ការលេងជានិមិត្តសញ្ញា (ដូចជាការលេងបែបដើរតួ) ហើយអនុញ្ញាតឱ្យកុមាររុករកកន្លែងទំនេរៗ និងអាចប៉ះពាល់សម្ភារៈបាន។ |

| | | |
|---|---|---|
| | | ○ ផ្តល់ល្បែងសិក្សាប្រភេទផ្សេងៗគ្នា និងអនុញ្ញាតឱ្យកុមារដើរជុំវិញបន្ទប់នៅពេលពួកគេត្រូវការ។ |

### ៣.៣ ការដាក់បញ្ចូល ICT នៅក្នុងថ្នាក់រៀន

| | |
|---|---|
| **គោលដៅជំនាញទន់ចម្បង** | ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការទំនាក់ទំនង ការច្នៃប្រឌិត ការសហការ។ |

បច្ចេកវិទ្យាកាន់តែទូលំទូលាយដែលធ្វើឱ្យយើងមានភាពងាយស្រួលក្នុងការចូលទៅរកធនធានសិក្សាដ៏ច្រើនសន្ធឹកសន្ធាប់ ដែលវានឹងពិបាកក្នុងការស្វែងរកធនធានសិក្សាប្រសិនបើគ្មានបច្ចេកវិទ្យា។ ជាឧទាហរណ៍ នៅពេលនិយាយអំពីការរៀនអក្សរ និងលេខ ឬការអនុវត្តជំនាញនៃការយល់ដឹង ឬជំនាញសង្គម ទូរទស្សន៍ឆ្លាតវៃ និងថេបប្លេតដែលមានធនធាន e-learning ត្រឹមត្រូវ ពិតជាអាចផ្តល់នូវការគាំទ្រយ៉ាងខ្លាំងសម្រាប់ការរៀនប្រកបដោយប្រសិទ្ធភាព និងមានភាពងាយស្រួល ក៏ដូចជារីករាយក្នុងការប្រើប្រាស់ផងដែរ។ ជាទូទៅ ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) មានទាំងមុខងារមើលឃើញដោយភ្នែក និងសូរសព្ទ ដែលអាចជួយកុមារឱ្យទទួលបានរបៀបនៃការសិក្សាខុសៗគ្នា និងលើកកម្ពស់ការលេង ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការរៀនសូត្ររបស់កុមារតូចៗ។

នៅក្នុងប្រទេសកម្ពុជា មានមនុស្សជាង ១៥ លាននាក់ បានប្រើប្រាស់អ៊ីនធឺណេត ហើយមានការតាមដានតាមទូរសព្ទដៃច្រើនជាង ២០ លាន ក្នុងនោះ មានការអប់រំបែបឌីជីថលកំពុងទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងផងដែរ[17]។

ដោយមើលឃើញបែបនេះហើយ ទើបកម្មវិធីសាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ក៏បានខិតខំប្រឹងប្រែងដោយអស់ពីលទ្ធដើម្បីដាក់បញ្ចូលការរៀនតាមទូរសព្ទ ដែលជួនកាលវាត្រូវបានគេស្គាល់ថាជា m-learning ជាយុទ្ធសាស្ត្រសិក្សាបន្ថែម និងមានប្រសិទ្ធភាពដែលនឹងជួយគាំទ្រដល់កុមារក្នុងការទទួលបានចំណេះដឹងមុនពេលចាប់ផ្តើមរៀនអក្សរ និងជំនាញលេខ។ ទោះយ៉ាងណាក៏ដោយ m-learning ក៏មានប្រសិទ្ធភាពខ្ពស់ក្នុងការគាំទ្រដល់ការអភិវឌ្ឍជំនាញផ្សេងទៀតដូចជា កិច្ចសហ

17 https://www.trc.gov.kh/mobile-phone-subcribers/

ប្រតិបត្តិការ ការច្នៃប្រឌិត ការគិតត្រិះរិះ ឬជំនាញដោះស្រាយបញ្ហាជាដើម។ មានសម្ភារៈសិក្សា m-learning ជាច្រើនប្រភេទដែលអាចត្រូវបានប្រើដើម្បីដាក់បញ្ចូលទៅក្នុងការសិក្សាបែបប្រពៃណី (ឧ. សៀវភៅសិក្សា) ទៅក្នុងកន្លែងសិក្សាបែបទំនើបកម្ម។ ក្នុងការសម្រេចបាននូវសមតុល្យនេះរវាងសម្ភារៈសិក្សាបែបប្រពៃណី និងទំនើបកម្ម វាពិតជាមានសារៈសំខាន់ណាស់ក្នុងការពិចារណាដោយប្រុងប្រយ័ត្នចំពោះសម្ភារៈឌីជីថលដែលមានស្រាប់ និងរបៀបដែលតភ្ជាប់សម្ភារៈទាំងនោះទៅនឹងការជួយគាំទ្រដល់កម្មវិធីសិក្សាបែបប្រពៃណី។

**មូលដ្ឋានទិន្នន័យរបស់ M-LEARNING**

សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នឹងប្រើប្រាស់កម្មវិធី ហ្គេម និងវីដេអូដែលមានជាភាសាខ្មែរដោយមិនគិតថ្លៃ។ ក្នុងករណីណាក៏ដោយ ធនធានឌីជីថលថ្មីកំពុងត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ហើយសៀវភៅណែនាំនេះអាចផ្តល់ការណែនាំអំពីការកំណត់អត្តសញ្ញាណធនធានទាំងនោះ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព។

កម្មវិធី សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ដំបូងនឹងបង្កើតមូលដ្ឋានទិន្នន័យនេះជាមួយនឹងសម្ភារៈឌីជីថល និងកម្មវិធីដែលគ្រូនឹងអាចប្រើប្រាស់បានដោយមិនចាំបាច់មានបណ្តាញអ៊ីនធឺណេត (ដោយសារសាលារដ្ឋភាគច្រើនមិនមានអ៊ីនធឺណេត)។ បន្ទាប់មក កម្មវិធីនឹងអភិវឌ្ឍសមត្ថភាពរបស់អ្នកសិក្សាឱ្យរៀនពីរបៀបធ្វើបច្ចុប្បន្នភាពទៅលើមូលដ្ឋានទិន្នន័យរបស់ពួកគេដោយកំណត់អត្តសញ្ញាណធនធានថ្មី និងធនធានដែលពាក់ព័ន្ធដោយខ្លួនឯង។

ប្រភេទនៃ**សម្ភារៈឌីជីថល**ដែលមាននាពេលបច្ចុប្បន្ននេះរួមមានដូចខាងក្រោម៖

- *កម្មវិធីសិក្សា* - កម្មវិធីសិក្សាជាភាសាខ្មែរភាគច្រើនត្រូវបានរចនាឡើងសម្រាប់សិស្សថ្នាក់បឋមសិក្សា ហើយផ្តោតលើការជំរុញអក្ខរកម្ម និងជំនាញលេខ (សូមមើលតារាងខាងក្រោម)។ សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នឹងណែនាំគ្រូបង្រៀនឱ្យសម្របតាមសម្ភារៈទាំងនោះទៅនឹងកម្មវិធីសិក្សារបស់មត្តេយ្យសិក្សា។ កម្មវិធីថ្នាក់ដំបូងទាំងនេះ ជាទូទៅលើកឡើងនូវសកម្មភាពដែលរួមមានការនិទានរឿងអន្តរកម្មអំពីប្រធានបទដែលពាក់ព័ន្ធនឹងសង្គមផ្សេងៗគ្នា និងបញ្ហាប្រឈមប្រចាំថ្ងៃ ព្រមទាំងល្បែងអក្ខរក្រម និងគណិត ដើម្បីគាំទ្រដល់ការអភិវឌ្ឍជំនាញអក្សរសាស្ត្រ និងគណិតវិទ្យា។ កម្មវិធីដែលមានលក្ខណៈសមស្របទាំងអស់នេះនឹងត្រូវបានផ្ទុកនៅលើថេប្លេតរបស់គ្រូ ដូច្នេះពួកគាត់អាចប្រើប្រាស់វាដោយគ្មានអ៊ីនធឺណេតបាន។
- *ធនធាននៃមូលដ្ឋានទិន្នន័យ*ដែលមានផ្ទុករូបភាព រូបភាព និងវីដេអូដែលអាចគាំទ្រការបង្រៀនមេរៀនផ្សេងៗ ពីកម្មវិធីសិក្សាក៏នឹងត្រូវបានផ្តល់ជូនផងដែរ។

| | | | |
|---|---|---|---|
| **អានខ្មែរ - Aan Khmer** (កម្មវិធីរៀនអាន សម្រាប់ថ្នាក់ទី១)<br> | សៀវភៅឆ្លាតវៃ-smart books (កម្មវិធីរៀនអាន សម្រាប់ថ្នាក់ទី២ & ៣)<br><br> | **សរសេរខ្មែរ - Sorse Khmer** (កម្មវិធីរៀនសរសេរសម្រាប់ថ្នាក់ទី ១ &<br><br>២) | **តោះអាន-Let's Read** (រឿងនិទានសម្រាប់ថ្នាក់ទី១ ដល់ ទី៦)<br><br> |

*តារាងទី២ ឧទាហរណ៍នៃកម្មវិធីដែលប្រើសម្រាប់បឋមសិក្សាដែលមាតិការបស់ពួកគេអាចត្រូវបានកែសម្រួលដោយផ្នែកសម្រាប់បឋមសិក្សា*

## ឧបករណ៍

ថ្នាក់រៀន សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នឹងត្រូវបានបំពាក់ដោយទូរទស្សន៍ឆ្លាតវៃ និងថេបប្លេតសម្រាប់គ្រូបង្រៀន។ គ្រូបង្រៀននឹងត្រូវបានបណ្តុះបណ្តាលឱ្យប្រើថេបប្លេត និងភ្ជាប់វាទៅទូរទស្សន៍ ដើម្បីផ្តល់ខ្លឹមសារ និងសកម្មភាពការងារសម្រាប់កុមារតូចៗ។ ថេបប្លេតបន្ថែមនឹងមាននៅក្នុងបណ្ណាល័យសាលាបឋមសិក្សា ដើម្បីខ្ចីសម្រាប់ហ្គេមជាក្រុមជាមួយកុមារតូចៗ។

## ការប្រើប្រាស់ ICT ដើម្បីពង្រឹងទំនាក់ទំនង និងការចែករំលែក៖ គ្រូបង្រៀន និងមាតាបិតា សិស្ស

ជាចុងក្រោយ ICT ផ្តល់នូវឧបករណ៍ដ៏មានតម្លៃសម្រាប់គ្រូបង្រៀន និងមាតាបិតាក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីធ្វើការបង្ហាញពីសមិទ្ធផលរបស់សិស្ស និងគាំទ្រសិស្សឱ្យរៀននៅផ្ទះបន្ថែម។ ទោះបីជាមាតាបិតាទាំងអស់មិនអាចចូលប្រើអ៊ីនធឺណេតបានក៏ដោយ ប៉ុន្តែនិន្នាការបង្ហាញពីរបៀបដែលភាគរយនៃអ្នកប្រើប្រាស់អ៊ីនធឺណេត និងម្ចាស់ទូរសព្ទស្មាតហ្វូនកំពុងកើនឡើងជារៀងរាល់ឆ្នាំ។ ដូច្នេះ គ្រូបង្រៀនត្រូវពិចារណាបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាចល័តសម្រាប់ការរៀននៅតាមមតេយ្យសិក្សា។ ជាឧទាហរណ៍ គ្រូៗ កំពុងតែបង្កើនទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយឪពុកម្តាយរបស់សិស្សតាមរយៈ ហ្វេសប៊ុក តេឡេក្រាម និងបណ្តាញសង្គមផ្សេងៗទៀត ដើម្បីបង្ហាញពីលទ្ធផលនៃសកម្មភាពសិក្សារបស់សិស្សតាមរយៈការប្រើប្រាស់រូបភាព វីដេអូ និងកំណែអេឡិចត្រូនិកនៃសម្ភារៈសិក្សាសម្រាប់ប្រើប្រាស់បន្ថែមនៅផ្ទះ។ គ្រូបង្រៀនក៏កំពុងប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គមផ្សេងទៀតផងដែរ ដើម្បីទំនាក់ទំនងគ្នាទៅវិញទៅមក ចែករំលែកការអនុវត្តដែលល្អៗ និងរួមចំណែកដល់ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs)។ លើសពីនេះ សាលារៀនមួយចំនួនកំពុងរៀបចំបណ្ណាល័

យជាមួយនឹងសេវា m-learning និងថេបប្លេត (ឧ. សាលា TRAC) ដែលគ្រូសារអាចខ្ចីយកទៅប្រើប្រាស់នៅតាមផ្ទះបាន។ គំរូបែបនេះផ្តល់នូវបទពិសោធន៍ជាក់ស្តែងមួយ ដើម្បីពង្រីកការអនុវត្តបែបនេះទៅកាន់បរិបទនៃការសិក្សាសម្រាប់ថ្នាក់មត្តេយ្យ។

## ៣.៤ ការសិក្សាដោយផ្អែកលើគម្រោង

| | |
|---|---|
| **គោលដៅជំនាញទន់ចម្បង** | ការដោះស្រាយបញ្ហាទាំងអស់ ការគិតបែបត្រិះរិះ ការសហការ ការទំនាក់ទំនង ការគ្រប់គ្រងខ្លួនឯង ការច្នៃប្រឌិត ការយល់ចិត្ត។ |

*Project-based learning connects students to the real world and prepares students to accept and cope with challenges of everyday life*

អ្នកសរសេរកម្មវិធីសាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) ជឿថាកុមារគឺជាអ្នកសិក្សាសកម្ម និងចង់ដឹង ចង់ឃើញ ដែលអាចបង្កើតចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេបាន។ វិធីល្អបំផុតមួយដើម្បីអនុវត្តគោលគំនិតនេះក្នុងការបង្រៀន គឺសំដៅដល់ **ការរៀនដោយផ្អែកតាមគម្រោង (PBL)។**

លក្ខណៈសំខាន់នៃ ការសិក្សាដោយផ្អែកលើគម្រោង (PBL) គឺការបង្កើតសកម្មភាពដែលកុមារចូលរួមក្នុងការស៊ើបអង្កេតទៅលើប្រធានបទមួយ ឬបញ្ហាពីពិភពពិតដែលពួកគេចាប់អារម្មណ៍។ បន្ទាប់មក ពួកគេនឹងបង្កើតផលិតផលណាមួយ ជាមួយនឹងចំណេះដឹងដែលពួកគេរៀនពីប្រភពផ្សេងៗគ្នា (ឧ. ទូរទស្សន៍ឆ្លាតវៃ, ថេបប្លេត ។ល។)។ ជាធម្មតា ការសិក្សាដោយផ្អែកលើគម្រោង (PBL) ត្រូវការពេលវេលាច្រើនជាងគម្រោងសាមញ្ញ។ គម្រោងបែបនេះអាចមានរយៈពេលពី ១ខែ ទៅ ១ឆមាស ឬពេញ ១ឆ្នាំសិក្សា។ កុមារនឹងត្រូវការពេលវេលាដើម្បីព្យាយាមឆ្លើយសំណួរស្មុគស្មាញ ដែលទាមទារឱ្យមានការធ្វើច្រើនជាជាងការមើលវីដេអូ ឬសួរសំណួរមួយចំនួនដើម្បីដោះស្រាយ។

គោលដៅចម្បងរបស់ការសិក្សាដោយផ្អែកលើគម្រោង (PBL) គឺសម្រាប់ឱ្យកុមាររៀនពីរបៀបទទួលបាន និងវិភាគព័ត៌មាន ដើម្បីយល់កាន់តែច្បាស់អំពីស្ថានភាពជីវិតប្រចាំថ្ងៃ។ បន្ទាប់មក ពួកគេអាចប្រើប្រាស់ព័ត៌មានបែបនេះ ដើម្បីដោះស្រាយបញ្ហាប្រចាំថ្ងៃ ដែលពួកគេជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ (ឧទាហរណ៍ តាមរយៈការគិតពិចារណា និងការដោះស្រាយបញ្ហា)។

**ជំហានដើម្បីប្រើប្រាស់របៀបរៀនដោយផ្អែកលើគម្រោងនៅក្នុងថ្នាក់រៀន**

នៅពេលយើងនិយាយអំពីការរៀនដោយផ្អែកតាមគម្រោង យើងសំដៅទៅលើសកម្មភាពទាំងឡាយណាដែលកុមារធ្វើការដោយសហការគ្នាជាមួយគ្រូ និងកុមារៗ ដូចគ្នាទៅវិញទៅមក។ គ្រូគួរណែនាំកុមារតាមជំហានដូចខាងក្រោម៖



In example:

topic: "Plants growing in the classroom"

Main subject: Science, but lined with children literacy, numeracy and social.

Driving question: How can we take care of plants in the classroom?

១. ***ជ្រើសរើសប្រធានបទ។*** ប្រធានបទគឺជាអត្ថបទ ឬបញ្ហាដែលជះឥទ្ធិពលលើ

កុមារ ហើយពួកគេចាប់អារម្មណ៍នៅក្នុងការស្វែងយល់។ ដោយផ្អែកលើការសន្ទនាជាមួយកុមារ គ្រូបង្រៀនអាចជ្រើសរើសប្រធានបទដែលភ្ជាប់ជាមួយមុខវិជ្ជាមួយ ឬច្រើន ហើយបង្កើតបាននូវសំណួរចម្បងដែលកុមារនឹងព្យាយាមឆ្លើយ។

**ចំណាំ៖** ប្រធានបទអាចជាលទ្ធផលនៃការសន្ទនាជាមួយកុមារ ដែលក្នុងនោះគ្រូកំណត់ប្រធានបទយកប្រធានបទមួយដែលពួកគេមិនសូវស្គាល់ ប៉ុន្តែពួកគេចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែម។ ឧទាហរណ៍ ប្រសិនបើគ្រូបង្រៀននិយាយពាក្យ 'គិលានុបដ្ឋាយិកា' ហើយបន្ទាប់មករកឃើញថាកុមារមិនដឹងថាពាក្យ គិលានុបដ្ឋាយិកាធ្វើអ្វី វាអាចក្លាយជាប្រធានបទថ្មីមួយបានផងដែរ។ សំណួរជុំវិញអាចលើកឡើងថា 'តើគិលានុបដ្ឋាយិកាធ្វើអ្វីដើម្បីជួយដល់ភូមិយើង?'

*២. កុមារទទួលបានព័ត៌មានដែលពួកគេត្រូវការ ខណៈពេលដែលមានការណែនាំ និងគាំទ្រពីគ្រូ។* សម្រាប់សាលា មត្តេយ្យទាំងឡាយ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដើម្បីទទួលបានប្រភពព័ត៌មាន។

ឧទាហរណ៍មួយចំនួននៃប្រភពព័ត៌មានដែលគ្រូអាចប្រើបានយ៉ាងងាយស្រួលដើម្បីផ្សព្វផ្សាយការសិក្សាដោយផ្អែកលើគម្រោង (PBL) រួមមានដូចខាងក្រោម៖

- ដំណើរកំសាន្ត ដើរជុំវិញសាលា ដើម្បីឱ្យសិស្សសង្កេតដោយផ្ទាល់នូវអ្វីដែលពួកគេចាប់អារម្មណ៍
- ការអញ្ជើញបុគ្គលដែលមានធនធានចំនេះដឹងដផ្សេងៗឱ្យនិយាយជាមួយកុមារ (ឧ. សមាជិកសហគមន៍/មាតាបិតា/អាជ្ញាធរមូលដ្ឋាន។ល។)
- អាចជាគ្រូផ្សេងៗទៀត ឬនាយកសាលា
- វីដេអូ សៀវភៅ រូបភាព សម្លេង នៅក្នុងបណ្ណាល័យ និងក្នុងថ្នាក់រៀន។

**ការរៀបចំការប្រជុំជាមួយវាគ្មិន**

**មុនការប្រជុំ**

- គ្រូទាក់ទងវាគ្មិននៅក្នុងស្រុកជាមុន ហើយកំណត់កាលវិភាគឱ្យបានច្បាស់លាស់។
- ធានាឱ្យមានការយល់ព្រមពីនាយកសាលាជាមុន
- រំលឹកវាគ្មិនអំពីកាលបរិច្ឆេទនាពេលខាងមុខ ដើម្បីប្រាកដថាបុគ្គលនោះនឹងមក។

**រៀបចំសិស្សមុននឹងការមកដល់របស់វាគ្មិន**

- ប្រាប់កុមារអំពីវាគ្មិនដែលនឹងជួបពួកគេ (ឈ្មោះ អាយុ ភេទ ប្រវត្តិរូប បទពិសោធន៍ និងហេតុផលដែលអ្នកជ្រើសរើសគាត់សម្រាប់ការបណ្តុះបណ្តាល)។

- សុំឱ្យកុមារគិតអំពីសំណួរដែលពួកគេចង់សួរវាគ្មិនដែលនឹងនិយាយអំពីប្រធានបទមុនពេលមេរៀនចាប់ផ្តើម។

**តើអ្នកណាអាចក្លាយជាធនធានមនុស្សក្នុងស្រុកសម្រាប់កុមារ?**

- បុគ្គលណាក៏បានដែលនៅក្នុង ឬក្រៅសាលាដែលមានជំនាញលើប្រធានបទដែលកុមារកំពុងស៊ើបអង្កេត ដូចជាគ្រូបង្រៀន កុមារចាស់ បុគ្គលិកឃុំ ប៉ូលីស កសិករ បុគ្គលិកធនាគារ សិប្បករ។ល។
- សមាជិក NGO និង CBO ដែលធ្វើការលើប្រធានបទដែលនិស្សិតកំពុងស៊ើបអង្កេត។
- សមាជិកសហគមន៍ដែលមានបទពិសោធន៍ទាក់ទងនឹងប្រធានបទមួយចំនួន (រួមទាំងអនាម័យ និងសុខភាព ការបោះឆ្នោតឃុំ/សង្កាត់។ល។)។

**ចងចាំ៖** នៅចុងបញ្ចប់នៃកិច្ចប្រជុំ សូមផ្ញើលិខិតថ្លែងអំណរគុណដល់វាគ្មិន ដែលបានចូលមកចែករំលែកចំណេះដឹង!

**ប្រភព៖** គោលការណ៍ណែនាំស្តីពីការអនុវត្តជំនាញជីវិតក្នុងស្រុកសម្រាប់គ្រូបង្រៀន និងការគ្រប់គ្រងសាលារៀន, DCD, MoEYS, 2020។

៣. ***កុមារធ្វើបទង្ហាញពីអ្វីដែលពួកគេបានរៀន។*** ផ្នែកចុងក្រោយនៃដំណើរការ ការសិក្សាដោយផ្អែកលើគម្រោង (PBL) នេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាអនុញ្ញាតឱ្យសិស្សពង្រឹងការសិក្សាដែលទទួលបានក្នុងអំឡុងពេលស៊ើបអង្កេត។ កុមារអាចសង្ខេប និងបង្ហាញនូវអ្វីដែលពួកគេបានរៀនតាមវិធីផ្សេងៗគ្នា ដូចជា បង្កើតផ្ទាំងព័ត៌មានជាមួយរូបភាព រៀបចំការតាំងពិពណ៌ (គំនូរ) ការបង្ហាញការលេង ច្រៀងចម្រៀង ឬធ្វើបទបង្ហាញដោយការនិយាយ។ គ្រូនឹងផ្តល់ការណែនាំអំពីទម្រង់បទបង្ហាញដោយផ្អែកលើសមត្ថភាព ចំណាប់អារម្មណ៍ ពេលវេលា និងធនធានដែលមាន។

**ឧទាហរណ៍នៃសមិទ្ធផលចុងក្រោយ**

**អ្វីខ្លះ៖**

- រៀបចំការតាំងពិព័រណ៍នៅក្នុងទីធ្លាសាលាជាមួយនឹងគំនូរដែលធ្វើឡើងដោយកុមារលើប្រធានបទផ្សេងៗដែលកុមារបានស៊ើបអង្កេត។
- កុមារអាចបង្កើតផ្ទាំងរូបភាពដែលពួកគេគូរ ឬពាក្យដែលពួកគេសង្ខេបពីអ្វីដែលពួកគេបានរៀន បន្ទាប់មកពួកគេអាចបង្ហាញដល់កុមារដែលមានវ័យច្រើនជាង ឪពុកម្តាយ ឬសហគមន៍។
- រៀបចំការល្បែងលេង

**ពេលណា។** សកម្មភាពអាចកើតឡើងនៅថ្ងៃពិសេស (ឧ. ទិវាកុមារ) ឬនៅចុងបញ្ចប់នៃឆ្នាំសិក្សានីមួយៗ នៅពេលដែលឪពុកម្តាយត្រូវបានអញ្ជើញឱ្យចូលរួម ដើម្បីមើលអ្វីដែលកូនៗ របស់ពួកគាត់បានរៀន។

## ៣.៥ ការរៀនតាមរយៈការលេងល្បែង

| | |
|---|---|
| **គោលដៅជំនាញទន់ចម្បង** | ទាំងអស់។ ការដោះស្រាយបញ្ហា ការគិតត្រិះរិះ កិច្ចសហប្រតិបត្តិការ ការទំនាក់ទំនង ការគ្រប់គ្រងខ្លួនឯង ការច្នៃប្រឌិត ការយល់ចិត្ត។ |

ការលេងគឺជាឧបករណ៍ដ៏មានអានុភាពមួយសម្រាប់ការសិក្សា។ ក្មេងៗ ចូលចិត្តលេង ហើយនៅពេលដែលពួកគេលេង ពួកគេសកម្ម និងចូលរួមក្នុងកិច្ចការនេះ ដោយប្រើពេលវេលាភាគច្រើនក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ ការសិក្សាជាច្រើនបានបង្ហាញពីរបៀបនៃការរៀនតាមរយៈការលេង ជាឧទាហរណ៍ជាមួយនឹងល្បែងផ្គុំរូប និងសម្ភារៈសំណង់ ត្រូវបានរកឃើញថាជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពខ្ពស់ក្នុងការលើកកម្ពស់ការអភិវឌ្ឍរបស់កុមារតូច[18]។

គ្រូត្រូវលើកទឹកចិត្តឱ្យមានការលេងប្រភេទផ្សេងៗគ្នាដោយកំណត់រកពេលវេលា និងទីកន្លែងសម្រាប់ការលេងនីមួយៗ។ យើងអាចកំណត់ប្រភេទនៃការលេងផ្សេងៗគ្នាដូចជា៖



*រូបភាពទី៦ ល្បែងចងចាំកាត*

- **ការលេងបែបរូបសាស្ត្រ៖** មានលំហាត់ប្រាណ និងអត្ថប្រយោជន៍សម្រាប់សុខភាព អភិវឌ្ឍសមត្ថភាពរបស់កុមារក្នុងការប្រើប្រាស់រាងកាយទាំងផ្នែកតូច និងធំ។
- **លេងជាមួយវត្ថុ៖** លើកទឹកចិត្តឱ្យចេះរៀបចំ (សមត្ថភាពរបស់កុមារក្នុងការប្រើប្រាស់រាងកាយផ្នែកធំ) លើកទឹកចិត្តឱ្យលេងជានិមិត្តសញ្ញា ប៉ុន្តែក៏មានយុទ្ធសាស្ត្រដោះស្រាយបញ្ហា និងហេតុផលផងដែរ។
- **ការលេងធ្វើពុត៖** វាអាចកើតឡើងក្នុងអំឡុងពេលការដើរតួជាឧទាហរណ៍ កុមារធ្វើពុតជាធ្វើម្ហូប លក់ ឬទិញរបស់នៅផ្សារ។ ការសិក្សាថ្មីៗ បង្ហាញពីរបៀបដែលការលេងប្រភេទនេះអាចមានឥទ្ធិពលលើការអភិវឌ្ឍភាសា និងជំនាញអារម្មណ៍សង្គម។

ប្រភេទនៃការលេងដែលបានរាយបញ្ជីទាំងអស់ខាងលើនេះ អាចត្រូវបានកំណត់ឡើងដោយសេរី ឬក៏រចនាឡើងដោយចេតនាជាមួយនឹងរចនាសម្ព័ន្ធមួយចំនួនពីគ្រូ។ របៀបលេងទាំងពីរមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍរបស់កុមារ។

**<u>អ្វីដែលគ្រូអាចធ្វើដើម្បីលើកកម្ពស់ 'ការលេង'</u>**

[18] Stephanie Wall, Ineke Litjens and Miho Taguma (2015), ការអប់រំ និងការថែទាំកុមារតូច, PEDAGOGY review, England. OECD.

- ការកំណត់គោលដៅសិក្សាឱ្យបានច្បាស់លាស់ មុននឹងលើកឡើងនូវសកម្មភាពលេង ឬសម្ភារៈដែលត្រូវរៀបចំ
- ជ្រើសរើសសម្ភារៈលេងដោយមានគោលបំណង
- រៀបចំកន្លែងលេង (ឧ. កន្លែងខាងក្នុង និង/ឬក្រៅទីធ្លា)
- តាមដានអាកប្បកិរិយារបស់កុមារនៅពេលពួកគេលេង ដើម្បីជូនដំណឹងអំពីសកម្មភាពបន្ទាប់
- ណែនាំកុមារក្នុងការប្រើប្រាស់សម្ភារៈនៅពេលចាំបាច់។

សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នឹងផ្តោតជាពិសេសទៅលើការប្រើប្រាស់ការលេងដែលមានគោលបំណងដើម្បីពង្រឹងការអភិវឌ្ឍការយល់ដឹង ភាសា និងអក្ខរកម្ម។ តាមពិតយើងអាចពង្រឹងជំនាញនៃការយល់ដឹងជាច្រើនតាមរយៈការលេងដូចជា ការលើកកម្ពស់ការតម្រៀប និងការចាត់ថ្នាក់ការវែកញែកបែបសាមញ្ញៗ និងការដោះស្រាយបញ្ហា (ឧទាហរណ៍៖ ជាមួយនឹងល្បែងផ្គុំរូប) ការរៀនស្គាល់អំពីរូបរាងផ្សេងៗ និងការប្រៀបធៀបទំហំ ឬការពង្រឹងការចងចាំជាមួយនឹងហ្គេមចងចាំដែលអនុញ្ញាតឱ្យកុមារធ្វើ បង្កើតជំនាញគិត និងការផ្តោតអារម្មណ៍របស់ពួកគេ (ឧទាហរណ៍ សូមមើលរូបទី១៤)។

ផ្នែកអភិវឌ្ឍន៍ផ្សេងៗទៀត ជាពិសេសការអភិវឌ្ឍរាងកាយ និងអារម្មណ៍សង្គម នឹងត្រូវបានគេកំណត់គោលដៅតាមរយៈការលេងផងដែរ។ ទាំងអស់នេះអាចត្រូវបានធ្វើដោយបង្ហាញពីរបៀបដែលការលេងរួមចំណែកដល់ការអភិវឌ្ឍកុមារទាំងមូល។ តាមរយៈការលេង កុមារនឹងរៀនចែករំលែក ធ្វើការចរចា (ឧទាហរណ៍ ប្រើប្រដាប់ប្រដាក្មេងលេងធម្មតា ឬចូលរួមក្នុងហ្គេមជាដើម) ឬពង្រឹងការគ្រប់គ្រងខ្លួនឯងដែលនឹងនាំទៅដល់ការចេះគ្រប់គ្រងស្ថានការណ៍តានតឹងក្នុងជីវិតបាន។

**ការយល់ដឹង៖ កាលវិភាគ និងទម្លាប់**

| | |
|---|---|
| **គោលដៅជំនាញទន់ចម្បង** | ការគ្រប់គ្រងខ្លួនឯង |




យុទ្ធសាស្ត្របង្រៀនទាំងអស់នឹងត្រូវបានបញ្ចូលក្នុងកាលវិភាគនៃសកម្មភាពដែលបានកំណត់។ ការមានកាលវិភាគរៀបចំ និងការកំណត់ទម្លាប់ច្បាស់លាស់នឹងជួយគ្រូ ព្រមទាំងកុមារឱ្យចេះត្រៀមខ្លួន និងឆ្លើយតប។ ក្នុងពេលជាមួយគ្នានេះដែរ វានឹងជួយពួកគេឱ្យមានអារម្មណ៍ថាមានសុវត្ថិភាព និងគ្រប់គ្រងលើអ្វីដែលកើតឡើងបន្ទាប់បាន ក៏ដូចជាអ្វីដែលពួកគេត្រូវធ្វើ ដើម្បីត្រៀមខ្លួនផងដែរ។

ជាឧទាហរណ៍ ប្រសិនបើការនិទានរឿងគឺជាសកម្មភាពដែលនឹងកើតឡើងក្នុងពេលឆាប់ៗនេះ កុមារត្រូវរៀបចំ និងសម្អាត (ទម្លាប់) បន្ទប់ ហើយទៅអង្គុយនៅកណ្តាលបន្ទប់រួចជាស្រេច។

*កាលវិភាគប្រចាំថ្ងៃដ៏ល្អមួយ* ជាធម្មតាត្រូវលើកឡើងនូវប្រភេទសកម្មភាពផ្សេងៗគ្នា ដែលរួមមានពេលស្ងប់ស្ងាត់ និងសកម្មភាពឆ្លាស់គ្នា សកម្មភាពជាក្រុមធំ និងតូច ក៏ដូចជាសកម្មភាពដឹកនាំដោយកុមារ និងដឹកនាំដោយគ្រូ។ ទាំងអស់នេះវាមានប្រយោជន៍ក្នុងការបង្ហាញកាលវិភាគឱ្យកុមារមើល ដោយប្រើរូបភាពនៅជាប់នឹងសកម្មភាព ដើម្បីជួយសម្រួលដល់ការយល់ដឹងឱ្យបានកាន់តែប្រសើរឡើង។ គ្រូអាចបង្ហាញកាលវិភាគនៅលើទូរទស្សន៍ឆ្លាតវៃ ឬបោះពុម្ពវានៅលើក្រដាសក៏បាន។

| **ឧទាហរណ៍នៃទម្លាប់ប្រចាំថ្ងៃ** | **ឧទាហរណ៍នៃកាលវិភាគប្រចាំថ្ងៃ** |
|---|---|
| • ពេលវេលាក្នុងការមកដល់<br>• ព្យួរកាបូបសិស្សពេលចូលរៀន<br>• ពេលវេលាសម្អាត<br>• ម៉ោងសម្អាតបន្ទប់ទឹក<br>• ពេលវេលាសម្រាក/ការតម្រង់ជួរ<br>• ការលាងដៃមុន និងក្រោយពេលប្រើប្រាស់បង្គន់<br>• ការចេញទៅផ្ទះ<br><br>ទម្លាប់តំណាងឱ្យជំហានក្នុងអំឡុងពេលនៃកាលវិភាគដែលត្រូវបានធ្វើម្តងហើយម្តងទៀតជារៀងរាល់ថ្ងៃ ហើយជាញឹកញាប់ក្នុងការកំណត់លក្ខណៈនៃការផ្លាស់ប្តូររវាងសកម្មភាពនីមួយៗ។ | • ការប្រជុំពេលព្រឹក<br>• ពេលវេលាក្រុមតូច ឬធំទាក់ទងនឹងប្រធានបទមួយ<br>• ពេលវេលាសម្រាប់អាហារសម្រន់<br>• ម៉ោងសម្រាប់ក្រៅទីធ្លា<br>• ពេលវេលារឿងនិទាន<br>• ពេលលេងដោយសេរី<br>• ពេលវេលាឆ្លុះបញ្ចាំង<br><br>កាលវិភាគពិពណ៌នាអំពីសកម្មភាពសំខាន់ៗក្នុងមួយថ្ងៃ។ |

សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS) នឹងផ្តល់នូវការយកចិត្តទុកដាក់ទាំងទម្លាប់ និងកាលវិភាគប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន ដើម្បីធានាបានថាមានពេលវេលាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវដើម្បីរៀបចំប្រភេទសកម្មភាពផ្សេងៗ ដូចជាការងារជាក្រុម ការនិទានរឿង ការលេងដោយសេរី និងរៀបចំការលេង និងការឆ្លុះបញ្ចាំងពីសកម្មភាពប្រចាំថ្ងៃ។ ទម្លាប់នឹងលើកកម្ពស់៖ ឥរិយាបថដែលមានប្រយោជន៍ ដូចជាការលាងដៃស្វ័យភាព (អាចធ្វើសកម្មភាពសាមញ្ញៗដោយខ្លួនឯង ដូចជាពាក់ស្បែកជើង ឬសម្អាតដៃ) និងការគ្រប់គ្រងខ្លួនឯង (ឧ. ទទួលខុសត្រូវក្នុងការដាក់សម្ភារៈត្រឡប់ទៅកន្លែងដើមវិញនៅពេលដែលសកម្មភាពត្រូវបានបញ្ចប់)។

## ៣.៦ ការអភិវឌ្ឍជំនាញទន់ និងការរៀបចំកិច្ចតែងបង្រៀន

តារាងសង្ខេបខាងក្រោមរៀបរាប់អំពីរបៀបដែលយើងអាចភ្ជាប់ការប្រើប្រាស់យុទ្ធសាស្ត្រទាំង ៥ ដែលបានបរិយាយពីមុនមក និងទម្លាប់ក្នុងការបង្រៀនប្រចាំថ្ងៃ ដើម្បីជំរុញឱ្យកុមារការទទួលបានជំនាញទន់។

| **មុខជំនាញនិងគោលដៅជំនាញទន់ចម្បង** | | **អ្វីដែលគ្រូអាចធ្វើបាន** |
|---|---|---|
| ការទំនាក់ទំនង និងការងារជាក្រុម (៤.២) | ទំនាក់ទំនង | **យុទ្ធសាស្ត្រសំខាន់ៗ៖ ទាំងអស់ ៥។**<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>• បង្កើតបរិយាកាសដែលមានផាសុកភាពក្នុងថ្នាក់រៀន<br>• ចាប់ផ្តើមថ្នាក់ជាមួយនឹងសំណួរមួយ<br>• សួរកុមារនូវគំនិតរបស់ពួកគេ<br>• សុំឱ្យកុមារឆ្លុះបញ្ចាំងពីអារម្មណ៍របស់ពួកគេ<br>• សុំឱ្យកុមារពណ៌នាអំពីគំនិតរបស់ពួកគេដល់មិត្តក្នុងថ្នាក់<br>• ប្រើប្រាស់ការសាកសួរ<br>• លើកកម្ពស់សកម្មភាពដែលកុមារបង្ហាញលទ្ធផលនៃគម្រោងរបស់ពួកគេទៅកាន់ឪពុកម្តាយ/មិត្តភ័ក្តិផ្សេងទៀត (ជាលទ្ធផលនៃការសិក្សាផ្អែកលើគម្រោង)<br>• អញ្ជើញវាគ្មិនឱ្យនិយាយជាមួយកុមារនៅសាលា<br>• បង្រៀនកុមារឱ្យក្លាយជាអ្នកស្តាប់ដ៏ល្អ |
| | សហប្រតិបត្តការ | **យុទ្ធសាស្ត្រសំខាន់ៗ៖** ការរៀនសហការ ការរៀនតាមរយៈការលេង ការរៀនតាមរយៈគម្រោង។<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>• លើកទឹកចិត្តសកម្មភាពជាគូ និងក្រុមតូច<br>• ប្រើបច្ចេកទេសសិក្សាដោយការសហការ<br>• ឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍នៃការធ្វើការងារជាក្រុម<br>• ធ្វើការឆ្លុះបញ្ចាំងដោយការគិតជាមួយកុមារអំពីបញ្ហាដែលពួកគេជួបប្រទះពេលធ្វើការជាក្រុម |
| ការវិភាគ និងការច្នៃប្រឌិត (៤.៣) | ការត្រិះរិះពិចារណា | **យុទ្ធសាស្ត្រសំខាន់ៗ៖** ការរៀនបែបសហការ ការរៀនតាមរយៈការលេង ការរៀនតាមរយៈគម្រោង។<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>ប្រើការសាកសួរតាមរបៀបដែលធ្វើឲ្យកុមារធ្វើដូចខាងក្រោម៖ |

| | | |
|---|---|---|
| | | • ប្រៀបធៀបអ្វីដែលពួកគេដឹង និងអ្វីដែលពួកគេរៀនថ្មីៗ។<br>• ធ្វើការទស្សន៍ទាយសាមញ្ញៗអំពីអ្វីដែលអាចនឹងកើតឡើងបន្ទាប់ (ឧ. នៅក្នុងរឿង) ហើយហេតុអ្វី (ឧទាហរណ៍ ពេលកំពុងអានរឿង ឬប្រធានបទផ្សេងទៀត សូមសួរសំណួរខាងក្រោម៖ តើមានអ្វីកើតឡើងប្រសិនបើ....? តើអ្នកគិតថានឹងមានអ្វីកើតឡើងបន្ទាប់....?តើអ្នកគិតថានឹងមានអ្វីកើតឡើងប្រសិនបើអ្នកមិន.....?)<br>ប្រើយុទ្ធសាស្ត្រសិក្សាដោយការសហការ និងផ្អែកលើគម្រោង ដែលកុមារនឹងត្រូវការវិភាគព័ត៌មានដែលបានពីអ្នកដទៃ ដែលកុមារអាចពន្យល់ពីគំនិត ឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ ចាត់ក្រុមសម្រាប់ព័ត៌មាននោះ។ល។<br>ប្រើសម្ភារៈបង្រៀនដែលលើកកម្ពស់សកម្មភាពដូចជា ហេតុផលសមរម្យ ការចងចាំ ការដាក់ជាក្រុម និងការផ្ទៀងផ្ទាត់។ |
| | ការដោះស្រាយបញ្ហា | **យុទ្ធសាស្ត្រសំខាន់ៗ៖** ការរៀនបែបសហការ ការរៀនតាមរយៈការលេង ការរៀនតាមរយៈគម្រោង។<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>• ប្រើសាច់រឿងលំដាប់នៃព្រឹត្តិការណ៍ និងបញ្ហាក្នុងជីវិតពិត<br>• សុំឱ្យកុមារគិតអំពីដំណោះស្រាយ<br>• បង្រៀនកុមារឱ្យចេះស្វែងរកព័ត៌មាន<br>• បង្រៀនកុមារឱ្យដឹងថាមានដំណោះស្រាយជាច្រើនដែលអាចកើតមានចំពោះបញ្ហាមួយ<br>• ចាត់ចែងកិច្ចការសាមញ្ញៗ ដល់កុមារដែលពួកគេត្រូវដោះស្រាយជាក្រុម (ការសិក្សាដោយសហការ និងផ្អែកលើគម្រោង) |
| | ការច្នៃប្រឌិត | **យុទ្ធសាស្ត្រសំខាន់ៗ៖** ការរៀនតាមរយៈការលេង ការរៀនតាមរយៈគម្រោង។<br>អ្វីដែលគ្រូអាចធ្វើ៖<br>• គាំទ្រគំនិតថ្មីៗ<br>• គាំទ្រការច្នៃប្រឌិត ឧទាហរណ៍ កុំកំណត់ពណ៌ដែលត្រូវប្រើក្នុងអំឡុងពេលធ្វើសកម្មភាពលើគម្រោង ជាជាងអនុញ្ញាតឱ្យកុមារជ្រើសរើសពួកគេដោយខ្លួនឯង។<br>• លើកកម្ពស់ការលេងស្ទីលដោយសេរី និងលើកទឹកចិត្តឱ្យមានការលេងជានិមិត្តរូប និងរូបតំណាង |

| | | |
|---|---|---|
| | | • ធ្វើឱ្យកុមារទទួលបានបទពិសោធន៍ពីប្រភេទផ្សេងៗ នៃការសិក្សា និងវិធីច្នៃប្រឌិតក្នុងការបង្ហាញឱ្យមានគំនិត និងអារម្មណ៍របស់ពួកគេ (ឧ. ការគូររូប ការលេងដើរតួនាទី តន្ត្រី ការធ្វើបទបង្ហាញ ការច្រៀង ។ល។) |
| ផ្ទាល់ខ្លួន គ្រួសារ និងសហគមន៍ (៤.៧) | ការគ្រប់គ្រងខ្លួនឯង | **យុទ្ធសាស្ត្រសំខាន់ៗ៖ ទាំងអស់ ៥។**<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>• ណែនាំអំពីទម្លាប់ក្នុងកាលវិភាគប្រចាំថ្ងៃដែលលើកកម្ពស់ចំពោះស្វ័យភាព<br>• លើកទឹកចិត្តកុមារឱ្យចេះបង្ហាញ និងទប់ទល់នឹងអារម្មណ៍របស់ពួកគេ<br>• លើកទឹកចិត្តកុមារឱ្យមានការគោរពចំពោះមិត្តភក្តិដទៃទៀត<br>• លើកទឹកចិត្តកុមារឱ្យប្រើសម្ភារៈទាំងអស់ឱ្យបានត្រឹមត្រូវ |
| | ការយល់ចិត្ត | **យុទ្ធសាស្ត្រសំខាន់ៗ៖ ទាំងអស់៥។**<br>**អ្វីដែលគ្រូអាចធ្វើ៖**<br>• លើកកម្ពស់អន្តរកម្មវិជ្ជមាន និងគូសបញ្ជាក់អំពីអត្ថប្រយោជន៍របស់ពួកវា<br>• លើកកម្ពស់សាមគ្គីភាពក្នុងថ្នាក់រៀន<br>• សុំឱ្យកុមារជួយគ្នាទៅវិញទៅមក និងធ្វើជាគំរូសម្រាប់កុមារដទៃ<br>• លើកទឹកចិត្តកុមារឱ្យចែករំលែកអារម្មណ៍ និងរៀនយល់ពីរបៀបដែលសកម្មភាពរបស់ពួកគេអាចបង្ហាញពីការទទួលខុសត្រូវចំពោះភាពមិនសប្បាយចិត្ត ឬសុភមង្គលរបស់អ្នកដទៃ |

## បញ្ជីសម្រាប់ពិនិត្យបរិយាកាសសិក្សា

**ការពិពណ៌នា។** ប្រើបញ្ជីត្រួតពិនិត្យនេះដូចដែលបានផ្តល់ជូនខាងក្រោម ដើម្បីជានាថាអ្នកកំពុងអនុវត្ត យុទ្ធសាស្ត្រសិក្សាដែលផ្តោតលើកុមារតូច និងការសិក្សាបែបសហការ ដែលលើកកម្ពស់ការចូលរួមរបស់កុមារ។ អ្នកត្រូវប្រាកដថាអ្នកមានគោលដៅ ១០០% នៃចំណុចដែលបានពិពណ៌នានៅក្នុងថ្នាក់រៀនរបស់អ្នក។

| | លក្ខណៈវិនិច្ឆ័យ | បាទ/ចាស | ទេ |
|---|---|---|---|
| ១ | ខ្ញុំរៀបចំឱ្យមានផែនការសកម្មភាពជាក្រុមនៅក្នុងថ្នាក់រៀន ដែលតម្រូវឱ្យកុមារសហការគ្នា | | |
| ២ | ខ្ញុំដឹងច្បាស់អំពីទម្រង់នៃការរៀនរបស់កុមារម្នាក់ៗ ហើយខ្ញុំសម្របខ្លួនទៅតាមដំណើរការសិក្សា | | |
| ៣ | ខ្ញុំប្រើ 'ការលេង' ដើម្បីបង្រៀនពីព័ត៌មានទៅលើប្រធានបទមួយ | | |
| ៤ | នៅក្នុងមេរៀនរបស់ខ្ញុំ ខ្ញុំបានលើកឱ្យមានរបៀបនៃការសិក្សាជាច្រើនប្រភេទ (ការសិក្សាដោយការមើល, ការស្តាប់, កាយវិការ) | | |
| ៥ | ខ្ញុំរៀបចំឱ្យមានសកម្មភាពរៀននៅខាងក្រៅទីធ្លាសាលា | | |
| ៦ | ខ្ញុំបញ្ចូលការប្រើទូរទស្សន៍ឆ្លាតវៃ ទៅក្នុងការបង្រៀនរបស់ខ្ញុំ | | |
| ៧ | ខ្ញុំដាក់បញ្ចូលទម្លាប់ជាច្រើនក្នុងកាលវិភាគប្រចាំថ្ងៃ | | |
| ៨ | ខ្ញុំរៀបចំឱ្យមានសកម្មភាពគម្រោងជាមួយកុមារអំឡុងពេលឆមាស | | |
| ៩ | ខ្ញុំលើកទឹកចិត្តឱ្យមានការពិភាក្សា ការចែករំលែកគំនិត ការសហការ និងការគាំទ្រគ្នាទៅវិញទៅមក | | |
| ១០ | ទុកពេល ៥-១០នាទី នៅចុងបញ្ចប់នៃថ្នាក់ ឬសម្រាប់ការធ្វើសកម្មភាពដើម្បីឆ្លុះបញ្ចាំងជាមួយកុមារអំពីអ្វីដែលពួកគេបានរៀន | | |
| សរុប | | | |

# ជំពូកទី ៤. ការវាយតម្លៃ

នៅក្នុងNGPSការវាយតម្លៃត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ដំណើរការបង្រៀននិងរៀន។នេះមានន័យថាគ្រូនឹងត្រូវតាមដានការអភិវឌ្ឍរបស់កុមារនៅសាលារៀនដើម្បីផ្តល់ព័ត៌មានត្រលប់និងកែលម្អការបង្រៀននិងផែនការបង្រៀនឱ្យបានប្រសើរជាងមុន។ហើយវាក៏នឹងមានលទ្ធភាពក្នុងការកំណត់បញ្ហាដែលអាចកើតមានដូច្នេះពួកគេអាចដោះស្រាយបញ្ហាទាំងនេះបានទាន់ពេលវេលា។ដូច្នេះកម្មវិធីរបស់យើងនឹងផ្តោតសំខាន់ទៅលើការវាយតម្លៃជាដំណាក់ដែលផ្តល់ពត៌មានត្រលប់ដល់ផែនការបង្រៀនដែលផ្ទុយពីការវាយតម្លៃសរុបដែលត្រូវបានរៀបរាប់ជារបាយការណ៍លទ្ធផលចុងក្រោយនៃលទ្ធផលសិក្សាដែលបានកំណត់ក្នុងឆ្នាំ។

**តើអ្វីទៅជាការវាយតម្លៃដំណាក់?**

ការវាយតម្លៃជាដំណាក់សំដៅទៅលើវិធីសាស្រ្តជាច្រើនដែលគ្រូប្រើដើម្បីធ្វើការវាយតម្លៃ  ការយល់ដឹងរបស់កុមារ តម្រូវការសិក្សានិងដំណើរការសិក្សាក្នុងមេរៀនឬវគ្គសិក្សា។

គ្រូនឹងរៀបរាប់និងចងក្រងឯកសារអំពីដំណើរការអភិវឌ្ឍន៍នៃការលូតលាស់របស់កុមារ ដើម្បីជៀសវាងការធ្វើចំណាត់ថ្នាក់ឬដាក់ស្លាកលើការសម្តែងចេញខាងក្រៅរបស់កុមារព្រោះដូចដែលបានបញ្ជាក់រួចមកហើយសកម្មភាពវាយតម្លៃត្រូវបានបង្កើតឡើងដើម្បីគាំទ្រនិងលើកទឹកចិត្តដល់ការអភិវឌ្ឍនិងការចង់ចេះចង់ដឹងរបស់កុមារ។ប្រសិនបើការដាក់ពិន្ទុណាមួយត្រូវបានប្រើវាគួរតែគាំទ្រដល់ការយល់ដឹងរបស់ឪពុកម្តាយនិងគ្រូបង្រៀនអំពីតម្រូវការសិក្សាជាក់លាក់របស់កុមារនិងអ្វីដែលត្រូវធ្វើដើម្បីកែលម្អការរៀនរបស់កុមារ។

## ៤.១.មូលហេតុដែលសាលាមត្តេយ្យជំនាន់ថ្មី បង្កើតការវាយតម្លៃនេះឡើង

ដូចបានកំណត់សម្គាល់ខាងលើគោលបំណងនៃការវាយតម្លៃដំណាក់ដែលបានអនុវត្តនៅក្នុងសាលាមត្តេយ្យជំនាន់ថ្មី( NGPS )គឺដើម្បីទទួលបានព័ត៌មានត្រលប់ដែលអាចកែលម្អការរៀបចំផែនការបង្រៀនឱ្យបានប្រសើរជាងមុន។

**ជាពិសេសគ្រូនឹងធ្វើការវាយតម្លៃជាបន្តបន្ទាប់ក្នុងគោលបំណង៖**

| **រយៈពេល** | **កិច្ចការវាយតម្លៃ** |
|---|---|
| **វាយតម្លៃដើមឆ្នាំ** | • ស្វែងយល់ពីកម្រិតនៃការយល់ដឹងរបស់កុមារម្នាក់ៗ របៀបរៀន ឧបសគ្គ និងចំណុចខ្លាំង។ |
| **ការវាយតម្លៃក្នុងកំឡុងពេលបង្រៀន** | • កែលម្អសកម្មភាពក្នុងផែនការបង្រៀនឱ្យកាន់តែប្រសើរឡើង<br>• សម្របដំណើរការបង្រៀនទៅនឹងតម្រូវការសិក្សារបស់កុមារដែលបានសង្កេតឃើញដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃក្នុងកំឡុងពេលបង្រៀន<br>• កំណត់បញ្ហាថ្មីៗដែលកើតឡើងដោយមិនបានគ្រោងទុកដែលត្រូវការឆ្លើយតបភ្លាមៗពីសាលារៀន។ |

## ៤.២. អ្វីទៅជាការវាយតម្លៃ

មាតិកានៃការវាយតម្លៃនៅក្នុងសាលាមត្តេយ្យជំនាន់ថ្មី(NGPS)ផ្តោតទៅលើទាំង " ចំណេះដឹង" និង" ជំនាញ" ដែលត្រូវបានគេស្គាល់ថាជាសមត្ថភាព។មានជាការសង្ខេបដូចខាងក្រោមនេះ៖

| **តើពួកយើងវាយតម្លៃអ្វី** | |
|---|---|
| **ចំណេះដឹង** | • ព័ត៌មានដែលទទួលបានក្នុងដំណើរការសិក្សាក៏ដូចជាការអនុវត្ត |
| **សមត្ថភាព (ចំណេះដឹង + ជំនាញ + ឥរិយាបថ)** | • សមត្ថភាពក្នុងការធ្វើអ្វីមួយឱ្យបានល្អ។ ជាពិសេសសាលាមត្តេយ្យជំនាន់ថ្មី NGPS នឹងពិនិត្យមើលលើជំនាញទន់និងឥរិយាបថផ្ទាល់ខ្លួនដែលទាក់ទងនឹងក្រុមនៃសមត្ថភាពដែលកំណត់ដោយក្រសួងអប់រំយុវជននិងកីឡា។ |

### ៤.២.១. សមត្ថភាពចាំបាច់សំខាន់ៗ

កុមារនៅកម្រិតមត្តេយ្យកំពុងតែធ្វើការពិសោធន៍ជាបន្តបន្ទាប់ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេការសម្របសម្រួលរាងកាយការប្រើប្រាស់ភាសានិងសមត្ថភាពរស់នៅក្នុងសង្គម។ពួកគេចាប់ផ្តើមមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយមិត្តភក្តិបន្ថែមទៀត នៅពេលពួកគេចាប់ផ្តើមរៀនធ្វើការជាក្រុ

ម។ការទទួលបានជំនាញរួមជាមួយនឹងបទពិសោធន៍និងចំណេះដឹងថ្មីៗនឹងជួយឱ្យកុមារអាចកសាងជំនាញកាន់តែប្រសើរជាងមុនបន្ថែមទៀត។នេះបញ្ជាក់ថាកុមារចាប់ផ្តើមយល់ដឹងអំពីច្បាប់ជាមូលដ្ឋានដែលទាក់ទងនឹងការសហការ(ដែលរួមបញ្ចូលទាំងជំនាញគ្រប់គ្រងខ្លួនឯង)ក៏ដូចជាជំនាញទំនាក់ទំនងដែលកាន់តែទំនើបជាពិសេសការប្រាស្រ័យទាក់ទងដោយពាក្យសំដីនិងមិនមែនជាពាក្យសំដី។ការទទួលបានជំនាញទំនាក់ទំនងទាំងនេះអាចត្រូវបានពន្លឿនដោយបង្កើនវាក្យសព្ទរបស់កុមារនិងលើកទឹកចិត្តពួកគេឱ្យអនុវត្តការសន្ទនាជាមួយមនុស្សផ្សេងៗទៀតបាន។ ដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រូបង្រៀនក្នុងការលើកកម្ពស់និងតាមដានការទទួលបានជំនាញបែបនេះដោយសង្កេតមើលអាកប្បកិរិយានិងសកម្មភាពជាក់លាក់ដែលភ្ជាប់ទៅនឹងសមត្ថភាពចាំបាច់សំខាន់ៗ។

**សមត្ថភាពទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖**

| **សមត្ថភាពចាំបាច់** | **ការរំពឹងទុករបស់សាលាមត្តេយ្យជំនាន់ថ្មី(NGPS)សម្រាប់មត្តេយ្យ កម្រិតខ្ពស់** |
|---|---|
| **ការទំនាក់ទំនងនិងការងារជាក្រុម (៤.៤)** | កុមារអាចបង្ហាញយ៉ាងងាយក្នុងទម្រង់ជាពាក្យសំដីនូវយោបល់និង តម្រូវការជាក់លាក់ក៏ដូចជាជជែកអំពីស្ថានភាពផ្សេងៗ។ កុមារអាចចូលរួមជាក្រុម។ |
| **ការវិភាគនិងការច្នៃប្រឌិត (៤.៥)** | កុមារអាចអនុវត្តហេតុផលជាក់លាក់សាមញ្ញដូចជាការប្រៀបធៀបនិងព្យាករណ៍ព្រឹត្តិការណ៍និងដោះស្រាយបញ្ហាសាមញ្ញ។ កុមារអាចបង្ហាញគំនិតនិងអារម្មណ៍តាមរបៀបច្នៃប្រឌិត។ |
| **ទំនាក់ទំនងរវាងកុមារគ្រួសារនិងសហគមន៍ (៤.៧)** | កុមារអាចមានឥរិយាបទស្វ័យភាពនិងទទួលខុសត្រូវចំពោះការប្រើប្រាស់សម្ភារៈនៅក្នុងថ្នាក់រៀន។ កុមារស្គាល់និងយល់ពីអារម្មណ៍របស់អ្នកដទៃ។ |

តារាងទី ៤ បញ្ជីសមត្ថភាពចាំបាច់និងនិយមន័យ

សាលាមត្តេយ្យជំនាន់ថ្មី(NGPS)បានសម្រេចដោយផ្តោតលើសមត្ថភាពសំខាន់ៗ៣ដែលដកចេញពីសមត្ថភាពសរុបចំនួន៨ពីព្រោះសមត្ថភាពខ្លះត្រូវបានវាស់វែងដោយឧបករណ៍ MoEYSរួចហើយ (ឧទាហរណ៍អក្សរនិងលេខ)ឬវាសមស្របសម្រាប់សិស្សធំៗ(ឧ. សមត្ថភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា ឬសហគ្រិនភាព)។ជាចុងក្រោយសមត្ថភាព"៤.៦"ការអនុវត្ត ចំណេះដឹងនិងជំនាញ"មិនត្រូវបានរាប់បញ្ចូលក្នុងរចនាសម្ព័ន្ធខាងលើទេពីព្រោះសាលាមត្តេយ្យជំនាន់ថ្មី(NGPS)ពិចារណាថាជំនាញទាំង

នេះត្រូវបានដាក់បញ្ចូលក្នុងជំនាញផ្សេងដែលបានលើកឡើងរួចហើយ។ពេលអនាគតវាចាំបាច់ណាស់ក្នុងការធានាថាឧបករណ៍ វាយតម្លៃទាំងអស់ឆ្លើយតបទៅនឹងរចនាសម្ព័ន្ធដែលផ្អែកលើសមត្ថភាពនិងមានភាពចុះសម្រុងគ្នារវាងកម្រិតនៃការសិក្សា។

ប្រភេទនៃសកម្មភាពឬអាកប្បកិរិយាដែលត្រូវបានត្រួតពិនិត្យសម្រាប់សមត្ថភាពនីមួយៗនឹងសមស្របទៅនឹងអាយុរបស់កុមារហើយនឹងបង្ហាញពីភាពពាក់ព័ន្ធខ្ពស់ទៅនឹងយុទ្ធសាស្ត្របង្រៀនដែលបានស្នើឡើងនៅក្នុងសៀវភៅណែនាំនេះ។ក្នុងន័យនេះសមត្ថភាពនីមួយៗនឹងត្រូវបានធ្វើប្រតិបត្តិការទាក់ទងនឹងឥរិយាបថនិងសកម្មភាពជាក់លាក់។

ដូចដែលបានបញ្ជាក់រួចហើយនៅក្នុងជំពូកទី១សាលាមត្តេយ្យជំនាន់ថ្មី(NGPS) នឹងធ្វើការសង្កត់ធ្ងន់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍនិងការតាមដានលើជំនាញទន់។សកម្មភាពប្រតិបត្តិការដែលបង្ហាញពីភាពប៉ិនប្រសប់នៃសមត្ថភាពជាក់លាក់ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| សមត្ថភាពនិងគោលដៅជំនាញទន់ | | អ្វីដែលគ្រូនឹងតាមដាននៅមត្តេយ្យសិក្សា |
|---|---|---|
| 1. ការរិះគិតនិងការច្នៃប្រឌិត | ការត្រិះរិះពិចារណា | គ្រូបង្រៀននឹងសង្កេតមើលថាតើកុមារអាចដាក់វត្ថុជាក្រុមនិងកំណត់ទំនាក់ទំនងជាក់លាក់រវាងវត្ថុនិងព្រឹត្តិការណ៍ដោយធ្វើការប្រៀបធៀបឬស្រង់សម្មតិកម្មនិងធ្វើការសន្និដ្ឋានសាមញ្ញ ៗ ។ |
| | ការដោះស្រាយបញ្ហា | គ្រូនឹងសង្កេតមើលសមត្ថភាពរបស់កុមារក្នុងការរៀបចំព្រឹត្តិការណ៍តាមពេលវេលាកំណត់ អនុវត្តយុទ្ធសាស្ត្រដោះស្រាយបញ្ហាសាមញ្ញដើម្បីដោះស្រាយជម្លោះដើម្បីដោះស្រាយការងារប្រចាំថ្ងៃរួមទាំងការប្រើប្រាស់ល្បែងសិក្សានិងសម្ភារៈថ្មីៗនិងការបំពេញភារកិច្ចថ្មីដែលបានកំណត់ជាបុគ្គលឬជាក្រុម។ |
| | ការច្នៃប្រឌិត | គ្រូនឹងសង្កេតមើលថាតើសិស្សអាចបង្ហាញគំនិតនិងអារម្មណ៍បានល្អកម្រិតណាដោយប្រើបច្ចេកទេសច្នៃប្រឌិតដូចជាការគូររូបឬច្រៀង រាំក៏ដូចជាការប្រើការលេងជានិមិត្តរូបនិងជារូបតំណាង។ |
| 2. ការ ទំនា | ការទំនាក់ទំនង | គ្រូនឹងសង្កេតមើលកុមារនិយាយគ្នាជាមួយមិត្តភក្តិនិងជាមួយមនុស្សធំផ្សេងទៀត។ គ្រូនឹងពិនិត្យមើលថា |

| | | |
|---|---|---|
| | | តើពួកគេអាចបង្ហាញគំនិតរបស់ពួកគេបានច្បាស់លាស់និងស្តាប់អ្នកដទៃដែរឬទេ។ |
| | ការសិក្សាបែបសហការ | គ្រូនឹងសង្កេតមើលកុមារលេងជាដៃគូរក៏ដូចជាក្រុមតូចនិងក្រុមមធ្យមដែលព្យាយាមវាយតម្លៃថាតើពួកគេមានទំនាក់ទំនងគ្នានៅក្នុងក្រុមយ៉ាងដូចម្តេច ( ឧទាហរណ៍ប្រសិនបើពួកគេចូលរួមក្នុងសកម្មភាពឬពួកគេមិនចូលរួមក្នុងក្រុម )និងថាតើពួកគេគោរពសមាជិកដទៃទៀតក្នុងក្រុមដែរឬទេ។ |
| ៣. ទំនាក់ទំនងរវាងកុមារ គ្រួសារនិងសហគមន៍ | ការគ្រប់គ្រងខ្លួនឯង | គ្រូបង្រៀននឹងសង្កេតមើលកុមារនៅក្នុងថ្នាក់រៀន ដើម្បីកំណត់សមត្ថភាពរបស់ពួកគេក្នុងការធ្វើសកម្មភាពនិងទម្លាប់ស្វ័យភាពនិងរបៀបដែលពួកគេថែរក្សានិងទុកដាក់សម្ភារដែលពាក់ព័ន្ធត្រូវតាមទីកន្លែងដោយរបៀបណា។ |
| | ការយល់ចិត្ត | គ្រូនឹងសង្កេតអំពីអន្តរកម្មរវាងមិត្តភក្តិនិងរបៀបដែលពួកគេថែរក្សាគ្នាទៅវិញទៅមក។ឧទាហរណ៍ប្រសិនបើពួកគេបង្ហាញពីការយល់ដឹងអំពីអារម្មណ៍របស់អ្នកដទៃ ហើយប្រសិនបើពួកគេសម្របខ្លួនឬប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិនៅពេលដែលមិត្តភក្តិបង្ហាញពីអារម្មណ៍ក្រៀមក្រំ /ខកចិត្តឬកំពុងប្រឈមមុខនឹងបញ្ហា( ឧទាហរណ៍ប្រសិនបើពួកគេ ត្រូវការជំនួយ ប្រសិនបើពួកគេស្នើសុំគ្រូឱ្យជួយ<br>ប្រសិនបើពួកគេមិនអើពើនឹងអ្នកដទៃ។ ល។ ) ។ |

*តារាងទី ៥ សមត្ថភាពនិងគោលដៅជំនាញទន់៖ អ្វីដែលគ្រូនឹងតាមដាន*

ចំពោះជំនាញទន់នីមួយៗNGPSនឹងបង្កើតកញ្ចប់ដែលជួយសម្រួលដល់គ្រូបង្រៀនក្នុងការសង្កេតសកម្មភាពឬអាកប្បកិរិយារបស់កុមារ។ធាតុទាំងនេះនឹងត្រូវបានដាក់ជាក្រុមជាមួយគ្នា ដែលជួយសម្រួលដល់ការសង្កេតជាប្រព័ន្ធ ( សូមមើលខាងក្រោម ) ។ ឧបករណ៍នេះនឹងក្លាយជាផ្នែកមួយនៃទម្រង់វាយតម្លៃ ៣ ដែល NGPS នឹងប្រើ។

### 4.3 របៀបវាយតម្លៃ

ក្នុងកម្មវិធីសាលាមត្តេយ្យជំនាន់ថ្មីយុទ្ធសាស្ត្រមួយចំនួននឹងត្រូវបានប្រើដើម្បីជួយសម្រួលដល់ការវាយតម្លៃជាបន្តបន្ទាប់នៃដំណើរការរៀនរបស់កុមារ។

វិធីសាស្ត្រវាយតម្លៃសមស្របនឹងមានដូចខាងក្រោម៖

I. សង្កេតនិងកត់ត្រាអាកប្បកិរិយារបស់កុមារម្នាក់ៗ
II. ការសន្ទនាជាក្រុមនិងបុគ្គល

III. ការវាយតម្លៃជាផ្លូវការដោយការធ្វើតេស្តតាមលក្ខណៈបុគ្គលតាមកាលកំណត់ (ឧបករណ៍របស់ក្រសួងអប់រំយុវជននិងកីឡា)

#### 4.3.1. ការសង្កេត

ពេលនៅសាលារៀនគ្រូបង្រៀននឹងចំណាយពេលច្រើនដើម្បីសង្កេតមើលកុមារ ។ គ្រូបង្រៀននឹងសង្កេតមើលកុមារនៅពេលកុមារកំពុងបំពេញកិច្ចការជាបុគ្គលនិងជាមួយមិត្តភក្តិនៅក្នុងថ្នាក់រៀន (ដើម្បីគាំទ្រកុមារនៅពេលពួកគេត្រូវការជំនួយពីគ្រូ)ប៉ុន្តែគ្រូបង្រៀនក៏នឹងត្រូវធ្វើការសង្កេតម្តងម្កាលដែរនៅពេលដែលកុមារកំពុងលេងនៅខាងក្រៅថ្នាក់ដើម្បីធានាថាកុមារមានសុវត្ថិភាពនិងលេងដោយគោរពគ្នាទៅវិញទៅ មក។

ដំណើរការនៃការសង្កេតអនុញ្ញាតឱ្យគ្រូប្រមូលព័ត៌មានអំពីទិដ្ឋភាពសំខាន់ៗនៃការអភិវឌ្ឍការយល់ដឹងនិងអាកប្បកិរិយារបស់កុមាររួមមានដូចខាងក្រោមៈ

- **ការយល់ដឹង៖** ស្វែងយល់អំពីការយល់ដឹងតាមកម្រិតយល់ដឹងរបស់កុមារម្នាក់ៗនិងការអនុវត្ត

ចំណេះដឹងទាំងនោះនៅក្នុងថ្នាក់រៀននិងក្នុងកិច្ចការប្រចាំថ្ងៃទាំងនៅសាលារៀននិងនៅផ្ទះ។

- **សមត្ថភាព(ចំណេះដឹងជំនាញនិងឥរិយាបថ)៖** សង្កេតមើលជំនាញនិងឥរិយាបថរបស់កុមារនៅ

ពេលពួកគេអនុវត្តកិច្ចការប្រចាំថ្ងៃនៅក្នុងសាលារៀន (ឧទាហរណ៍ការនិយាយនិងការសហការជាមួយមិត្តភក្តិ ការយកចិត្តទុកដាក់ចំពោះមិត្តភក្តិ អាចប្រើប្រាស់ជំនាញមូលដ្ឋានហេតុនិងផលជាក់លាក់ ការច្នៃប្រឌិត ការទទួលខុសត្រូវនិងការគោរពគ្នាទៅវិញទៅមក។ ល។)

ការសង្កេតក៏នឹងជួយគ្រូឱ្យកំណត់បញ្ហាអាកប្បកិរិយាដែលអាចកើតមាន ហើយកំណត់គោលដៅភ្លាមៗ។

ការសង្កេតអាចមានទម្រង់ដូចខាងក្រោមដែលបានពិពណ៌នានៅក្នុងតារាងខាងក្រោម៖

| ល.រ | **ប្រភេទ** | **ការពិពណ៌នា** | **ឧបករណ៍** |
|---|---|---|---|
| **1** | ជាប្រព័ន្ធ | នេះអាស្រ័យតាមផែនការសកម្មភាពសង្កេតដែលបានគ្រោងទុក។ជាធម្មតាការសង្កេតបែបនេះគឺជាផ្នែកមួយនៃដំណើរការបង្រៀនដើម្បីគាំទ្រដល់កុមារក្នុងដំណើរការរៀនរបស់កុមារហើយជាធម្មតាវា | •ឧបករណ៍វាយតម្លៃនិងកំណត់ត្រាក្រៅផ្លូវការ<br>•កំណត់ចំណាំ |

| | | | |
|---|---|---|---|
| | | អាស្រ័យលើការប្រើប្រាស់ឧបករណ៍និងទម្រង់ជាក់លាក់។ | បន្តបន្ទាប់<br>• ទម្រង់វាយតម្លៃសមត្ថភាពផ្លូវការ |
| **2** | ម្តងម្កាល | គ្រូបង្រៀនអាចសង្កេតមើលអាកប្បកិរិយាគួរឱ្យចាប់អារម្មណ៍នៅក្រៅម៉ោងបង្រៀនខណៈពេលដែលឧទាហរណ៍មើលកុមារលេងនៅពេលពួកគេកំពុងរង់ចាំឪពុកម្តាយរបស់ពួកគេមកយក។គ្រូបង្រៀនគួរកត់ចំណាំអំពីអាកប្បកិរិយាពាក់ព័ន្ធណាមួយដែលទាក់ទងនឹងកុមារម្នាក់ៗ។ | • ការសង្កេតក្រៅផ្លូវការ<br>• កំណត់ចំណាំបន្តបន្ទាប់ |

*តារាងទី ៦ ប្រភេទផ្សេងៗនៃគំរូទម្រង់សង្កេត*

**ទម្រង់និងឧបករណ៍សង្កេតសមត្ថភាពសិស្ស**

គ្រូបង្រៀននឹងប្រើទម្រង់ជាក់លាក់មួយដើម្បីតាមដានអាកប្បកិរិយានិងសកម្មភាពដែលងាយស្រួលក្នុងការសង្កេតនៅក្នុងបរិស្ថានសាលារៀន។អាកប្បកិរិយាទាំងនេះគួរតែត្រូវបានទទួលយកជាទូទៅទាក់ទងទៅនឹងទំនួលខុសត្រូវរបស់គ្រូបង្រៀនក្នុងការជួយគាំទ្រមួយផ្នែកនៃការបង្រៀនរបស់ពួកគេ។ព័ត៌មាននេះគួរតែបំពេញបន្ថែមនូវទិន្នន័យដែលប្រមូលបានដោយប្រើប្រាស់ឧបករណ៍ផ្លូវការដែលផ្តល់ដោយក្រសួង

អប់រំយុវជននិងកីឡាដែលតាមដានការអភិវឌ្ឍរបស់កុមារក្នុងវិស័យសំខាន់ៗចំនួន ៥(ចំណេះដឹងសង្គមអារម្មណ៍ ភាសានិងអក្ខរកម សុខុមាលភាពរាងកាយនិងសុខភាព វប្បធម៌និងសីលធម៌) និងត្រូវបានធ្វើតេស្ត ៣ ដងក្នុងមួយឆ្នាំ។តាមរយៈការបូកសរុបលទ្ធផលបញ្ចូលនៃការធ្វើតេស្តផ្លូវការនេះជាមួយនឹងការសង្កេតជាបន្តបន្ទាប់នៃសមត្ថភាពដែលពាក់ព័ន្ធសម្រាប់មត្តេយ្យវានឹងទទួលបានគំនិតទូលំទូលាយនៃការអភិវឌ្ឍរបស់កុមារ។ទម្រង់វាយតម្លៃ បញ្ចូលគ្នានេះក៏នឹងបង្កើតជាចំណុច**ចាប់ផ្តើមសម្រាប់តាមដានដំណើរការរៀនរបស់កុមារ ដោយផ្អែកលើសមត្ថភាពមូលដ្ឋាន**ដែលឆ្លុះបញ្ចាំងពីការរចនានៃកម្មវិធីសិក្សាថ្មីសម្រាប់គ្រប់កម្រិតនៃការអប់រំដោយផ្តើមចេញពីថ្នាក់មត្តេយ្យ។លទ្ធផលនៃការសង្កេតនឹងត្រូវរាប់បញ្ចូលជាទម្រង់របាយការណ៍ដែលត្រូវបានប្រើប្រាស់ដោយក្រសួងអប់រំយុវជននិងកីឡាហើយនឹងអនុវត្តតាមពេលវេលាកំណត់ដោយចាប់ផ្តើមពីការអនុវត្តន៍ដំបូង ។

**ខាងក្រោមនេះយើងបង្ហាញពីរបៀបដែលរបាយការណ៍សង្កេតអាចត្រូវបានរាយការណ៍៖**

| សមត្ថភាព | កម្រិត | យោបល់គ្រូ |
|---|---|---|
| **4.4 ការទំនាក់ទំនងនិងការងារជាក្រុម**<br>កុមារអាចនិយាយដោយផ្ទាល់មាត់នូវតម្រូវការក៏ដូចជាមតិយោបល់និងការពិពណ៌នាអំពីស្ថានភាពជាក់លាក់ណា | ☐ ខ្សោយ<br>☐ មធ្យម | ដារ៉ាអាចបង្ហាញពីតម្រូវការរបស់គាត់បានយ៉ាងងាយ |

| | | |
|---|---|---|
| មួយបានយ៉ាងងាយ។កុមារអាចចូលរួមក្រុមដោយគោរពមិត្តភក្តិ។ | ☐ ល្អបង្គួរ<br>☐ ខ្លាំង | ស្រួលដោយនិយាយយ៉ាងច្បាស់។ |
| **4.5 ការវិភាគនិងការច្នៃប្រឌិត**<br><br>កុមារអាចអនុវត្តហេតុផលជាក់លាក់សាមញ្ញៗដូចជាការប្រៀបធៀបនិងព្យាករណ៍ព្រឹត្តិការណ៍និងដោះស្រាយបញ្ហាសាមញ្ញ។ កុមារអាចបង្ហាញគំនិតនិងអារម្មណ៍តាមរបៀបច្នៃប្រឌិត។ | ☐ ខ្សោយ<br>☐ មធ្យម<br>☐ ល្អបង្គួរ<br>☐ ខ្លាំង | ដារ៉ាបង្ហាញពីគំនិតច្នៃប្រឌិតក្នុងសកម្មភាពប្រចាំថ្ងៃហើយគាត់ពូកែពន្យល់ព្រឹត្តិការណ៍។ |
| **4.7 កុមារ គ្រួសារនិងការអភិវឌ្ឍសង្គម**<br>កុមារមានអាកប្បកិរិយាស្វយ័តភាពនិងទទួលខុសត្រូវចំពោះការប្រើប្រាស់សម្ភារៈនៅក្នុងថ្នាក់រៀន។កុមារស្គាល់និងយល់ពីអារម្មណ៍របស់អ្នកដទៃ។ | ☐ ខ្សោយ<br>☐ មធ្យម<br>☐ ល្អបង្គួរ<br>☐ ខ្លាំង | ដារ៉ាបង្ហាញពីគំនិតច្នៃប្រឌិតក្នុងសកម្មភាពប្រចាំថ្ងៃហើយគាត់ពូកែពន្យល់ព្រឹត្តិការណ៍។ |

*តារាងទី ៧ ឧទាហរណ៍អំពីរបៀបបូកសរុបលទ្ធផលសង្កេតសមត្ថភាពក្នុងទម្រង់របស់* MoEYS

កម្រិត: កម្មវិធីសាលាមត្តេយ្យជំនាន់ថ្មីបានរៀបចំរចនាទម្រង់វាយតម្លៃដែលបង្ហាញពីកម្រិតលទ្ធផលសម្រាប់សមត្ថភាពគោលដៅជំនាញទន់ដែលពាក់ព័ន្ធ។ឯកសារនេះនឹងណែនាំគ្រូបង្រៀនឱ្យត្រួតពិនិត្យនិងវាយតម្លៃលើសមត្ថភាពដែលទទួលបានជាបណ្តើរ ៗដោយផ្តល់នូវស្តង់ដារសំខាន់ៗសម្រាប់វាស់កម្រិតនីមួយៗពី ១ (ខ្សោយ) ដល់ ៤ (ខ្លាំង) (សូមមើលឧបសម្ព័ន្ធ ៤.២ " លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃសមត្ថភាព") ។គ្រូនឹងអាចវាយតម្លៃកុមារបានដោយគ្រាន់តែសង្កេតមើលកុមារញឹកញាប់ប៉ុណ្ណោះ។

## របៀបប្រើទម្រង់សង្កេត

គ្រូនឹងប្រើទម្រង់សង្កេតនេះសម្រាប់សង្កេតកុមារម្នាក់ៗ។ NGPSនឹងបញ្ចូលតេស្តនេះក្នុងថែបប្លេតនិងបណ្តុះបណ្តាលគ្រូបង្រៀនឱ្យប្រើប្រាស់តាមថែបប្លេតដែលពួកគេទទួលពីគម្រោង។

- **ភាពញឹកញាប់:** គ្រូបង្រៀនគួរតែសង្កេតមើលកុមារជាប្រព័ន្ធម្នាក់ៗឱ្យបាន ២-៣ ដងក្នុងមួយឆមាសដើម្បីធានាថាពួកគេអាចសង្កេតនិងបញ្ជាក់ពីការប្រព្រឹត្តដដែលៗរបស់កុមារ។ជាមួយនឹងការសង្កេតម្តងម្កាលនៃជីវភាពប្រចាំថ្ងៃនឹងអនុញ្ញាតឱ្យគ្រូបង្រៀនកំណត់កម្រិតនៃសមត្ថភាពជាក់លាក់ដែលត្រូវបានអភិវឌ្ឍន៍។

- **របៀបប្រើទម្រង់សង្កេត :** (សូមមើលឧទាហរណ៍ខាងក្រោម)៖ ក្រៅពីចំណុចនីមួយៗដែលត្រូវសង្កេតគឺមានក្រឡាទទេដែលគ្រូអាចសរសេរកំណត់ចំណាំរបស់គាត់បាន។កំណត់ចំណាំនេះភាគច្រើនរួមមានការរាយការណ៍អំពីអាកប្បកិរិយាជាក់លាក់ដែលបង្ហាញដោយកុមារ។ របាយការណ៍នេះក៏អាចសរសេរជាទម្រង់នៃការពិពណ៌នាជារឿងរ៉ាវសង្ខេប។ឧបសម្ព័ន្ធនេះគឺជារឿងរ៉ាវអំពីអាកប្បកិរិយារបស់កុមារដែលផ្តល់នូវសារៈសំខាន់ដល់ការអភិវឌ្ឍរបស់កុមារ (សូមមើលឧបសម្ព័ន្ធ ៤.១ សម្រាប់ទម្រង់សង្កេតពេញលេញ) ។

| ការទំនាក់ទំនងនិងការងារជាក្រុម | កំណត់ត្រាឆមាសទី១ |
|---|---|
| (ការទំនាក់ទំនង) កុមារអាចនិយាយដោយផ្ទាល់មាត់នូវតម្រូវការក៏ដូចជាមតិយោបល់និងការពិពណ៌នាអំពីស្ថានភាពជាក់លាក់ណាមួយបានយ៉ាងងាយ។ | ០៨.១២.២០<br>ថ្ងៃនេះដារ៉ាបានពន្យល់ទៅកាន់ថ្នាក់រៀនរបស់គាត់អំពីសារៈសំខាន់នៃការដុសធ្មេញជារៀងរាល់ថ្ងៃ<br>០៩.០២.២១<br>ដារ៉ានៅថ្ងៃនេះបានរៀបរាប់ប្រាប់មិត្តភក្តិទាំងអស់ពីរបៀបដែលគ្រួសាររបស់គាត់តែងតែប្រារព្ធពិធីភ្ជុំបិណ្ឌ។. |

↑ ចំណុចដែលត្រូវសង្កេត

↑ **ប្រអប់ទទេដើម្បីបំពេញជាមួយកំណត់សំគាល់របស់គ្រូ**
គ្រូបង្រៀនអាចសរសេរកំណត់សំគាល់ដែលពិពណ៌នាអំពីអាកប្បកិរិយាដែលបានសង្កេតនិងកាលបរិច្ឆេទនៃការសង្កេតកុមារ។

## ឧទាហរណ៍នៃរឿងរ៉ាវសង្ខេបការសង្កេតអាកប្បកិរិយារបស់កុមារ

របាយការណ៍កុមារគួរតែពិពណ៌នាអំពីការចូលរួមរបស់កុមារនៅក្នុងសកម្មភាពជាក់លាក់មួយពីដើមដល់ចប់។ វាត្រូវបានសរសេរជាប្រយោគអតីតកាល។វាអាចរួមបញ្ចូលអន្តរាគមន៍របស់គ្រូដើម្បីជួយណែនាំនិងពិពណ៌នាអំពីការឆ្លើយតបរបស់កុមារ។ ឧទាហរណ៍ របាយការណ៍មួយចំនួននៃអាកប្បកិរិយារបស់កុមារដែលផ្តល់ឱ្យដូចខាងក្រោម៖

សង្កេតការយល់ចិត្ត៖ " ផល្លាបានអញ្ជើញរដ្ឋាមកអង្គុយក្បែរនាងព្រោះនាងឃើញរដ្ឋាយំ។ រដ្ឋាមិនចង់មកទេដូច្នេះផល្លាបានប្រាប់ឱ្យគ្រូជួយ ហើយផល្លាបានចែករំលែកឱ្យល្បែងសិក្សានាងខ្លះឱ្យទៅឱ្យរដ្ឋា" ។

សង្កេតមើលការសហការ៖ ដារ៉ាមិនចូលរួមក្នុងការងារជាក្រុមទេថ្ងៃនេះ។ដារ៉ាគេចវេសតាំងពីដំបូងមកគាត់មិនបានជួយធ្វើកិច្ចការក្រុមដែលបានកំណត់ទេ។នៅពេលគ្រូសួរថាហេតុអ្វីបានជាគាត់មិនចូលរួម

គាត់ពន្យល់ថាគាត់មិនដឹងពីរបៀបធ្វើកិច្ចការក្រុមដូច្នេះគ្រូបានជួយគាត់ដោយសួរមិត្តភក្តិក្នុងក្រុមជួយពន្យល់កិច្ចការដែលត្រូវធ្វើក្នុងក្រុម" ។

សង្កេតមើលការទំនាក់ទំនង៖ ក្នុងអំឡុងពេលអញ្ជើញប៉ូលីសទៅសាលារៀនសុភាមើលទៅមានការចាប់អារម្មណ៍យ៉ាងខ្លាំងហើយកំពុងស្តាប់ដោយយកចិត្តទុកដាក់។ នៅចុងបញ្ចប់នៃកិច្ចប្រជុំគាត់ក៏បានសួរសំណួរ " ឬសុភាបានពន្យល់ដល់មិត្តភក្តិរបស់គាត់ថាហេតុអ្វីបានជាគាត់មិនសប្បាយចិត្តនៅថ្ងៃនេះ។ មូលហេតុគឺថាគាត់មិនអាចរកឃើញប្រដាប់ក្មេងលេងដែលគាត់ចូលចិត្តមុនពេលមកសាលារៀន" (ជំនាញទំនាក់ទំនងនិងការគ្រប់គ្រងខ្លួនឯង/និយាយអំពីអារម្មណ៍) ។

**សំណួរនាំផ្លូវក្នុងទម្រង់សង្កេតកុមារ**

តារាងខាងក្រោមរួមបញ្ចូលនូវសំណួរមួយចំនួនដែលអាចណែនាំគ្រូបង្រៀនក្នុងកំឡុងពេលសង្កេតមើលជំនាញទន់នីមួយៗតាមសមត្ថភាពដែលពាក់ព័ន្ធ។

| សមត្ថភាពគោលដៅ | ជំនាញទន់ដែលពាក់ព័ន្ធ | យោបល់នៃការឆ្លុះបញ្ចាំងរបស់គ្រូ |
|---|---|---|
| **4.4 ការទំនាក់ទំនងនិងការងារជាក្រុម**<br>កុមារអាចនិយាយដោយផ្ទាល់មាត់នូវតម្រូវការងាយៗក៏ដូចជាបង្ហាញមតិយោបល់និងការពិពណ៌នាអំពីស្ថានភាពជាក់លាក់។ កុមារអាចចូលរួមក្រុមដោយគោរពមិត្តភក្តិ។ | **ការទំនាក់ទំនង** | ▪ តើកុមារសួរសំណួរដែរឬទេ? តើអ្នកយល់សំណួរដែលកុមារកំពុងសួរដែរឬទេ? តើកុមារដទៃទៀតយល់សំណួរដែរឬទេ?<br>▪ តើកុមារស្តាប់គ្រូនិងមិត្តភក្តិដែរឬទេ?<br>▪ តើកុមារអាចបង្ហាញពីគំនិតរបស់គាត់ដោយងាយស្រួលនិងច្បាស់លាស់ដែរឬទេ? |
